# ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ដោយសារគម្រោង

គម្រោងលេខ៖ 53240-003

ខែតុលា ឆ្នាំ២០២២

# គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញ ខ្សែប្រវាក់តម្លៃសត្វ (ប្រទេសកម្ពុជា)

**រៀបចំដោយ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានជំនួយពីទីប្រឹក្សាជំនួយផ្នែកបច្ចេកទេសដំណាក់កាលចាប់ផ្តើម ក្រោមការណែនាំ និងការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

**អត្រាប្តូរប្រាក់រូបិយប័ណ្ណមានតម្លៃស្មើ**[1]
(គិត្រឹមថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០២២)

| | | |
|---|---|---|
| ឯកតារូបិយប័ណ្ណ | – | រៀល (ខ្មែរ) |
| ១.០ រៀល | = | ០.០០០២៤ ដុល្លារអាមេរិក |
| ១.០ ដុល្លារអាមេរិក | = | ៤,១៣៧ រៀល |

## ពាក្យបំប្រួញ

| | | |
|---|---|---|
| ADB | – | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AP | – | ប្រជាជនដែលរងផលប៉ះពាល់ |
| BRP | – | ផែនការតាំងទីលំនៅថ្មីជាមូលដ្ឋាន |
| CAO | – | ការិយាល័យរដ្ឋបាលសុរិយោដី |
| DCZ | – | តំបន់គ្រប់គ្រងជំងឺ |
| DDR | – | របាយការណ៍ស្តីពីការអនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយ |
| DIMDM | | នាយកដ្ឋានតសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ |
| DKLBM | – | ផ្សារលក់មានទារស់ដូនកែវ |
| DMS | – | ការអង្កេតវាស់វែងលម្អិត |
| DP | – | អ្នកដែលត្រូវផ្លាស់ទី |
| DRP | – | ផែនការដោះស្រាយផលប៉ះពាល់លម្អិត |
| EMP | – | ផែនការគ្រប់គ្រងបរិស្ថាន |
| FGD | – | ការពិភាក្សាជាក្រុម |
| FMD | – | ជំងឺអុតក្តាម |
| GDR | – | អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ |
| GMS | – | មហាអនុតំបន់ទន្លេមេគង្គ |
| GRM | – | យន្តការដោះស្រាយបណ្តឹងតវ៉ា (ឬបណ្តឹងសាទុក្ខ) |
| IRP | – | កម្មវិធីស្តារប្រាក់ចំណូលឡើងវិញ |
| IRC | – | គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ |
| IOL | – | សារពើភ័ណ្ឌនៃការខាតបង់ |
| MAFF | – | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

[1] https://www.nbc.org.kh/english/

| | | |
|---|---|---|
| MEF | – | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| PGRC | – | គណៈកម្មការពិនិត្យ និងដោះស្រាយបណ្តឹងថ្នាក់ខេត្ត |
| PV | – | ព្រៃវែង |
| QC | – | មណ្ឌលចត្តាឡីស័ក |
| RD2 | – | នាយកដ្ឋានតាំងទីលំនៅថ្មី ទី២ |
| RCS | – | ការសិក្សាតម្លៃជំនួស |
| RGC | – | រាជរដ្ឋាភិបាលកម្ពុជា |
| RF | – | ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ដោយសារគម្រោង |
| ROW | – | សិទ្ធិសាធារណៈ (ប្រើប្រាស់ដីចំណីផ្លូវ) |
| SES | – | ការស្ទង់មតិផ្នែកសេដ្ឋកិច្ចសង្គម |
| SOP | – | នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា |
| SPS | – | សេចក្តីថ្លែងគោលនយោបាយការពារ (ADB ឆ្នាំ២០០៩) |
| TWG | – | ក្រុមការងារផ្នែកបច្ចេកទេស |
| VAHW | – | ភ្នាក់ងារសុខភាពសត្វភូមិ |

# សន្ទានុក្រម

| សព្ទបច្ចេកទេស | | និយមន័យ |
|---|---|---|
| អ្នករងផលប៉ះពាល់ | – | នៅក្នុងបរិបទនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត អ្នកដែលរងផលប៉ះពាល់ គឺជាអ្នកដែលត្រូវបានបំផ្លាស់ទីលំនៅ (ការផ្លាស់ទីលំនៅ ការបាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជម្រក) និង/ឬ ការផ្លាស់ទីលំនៅជាលក្ខណៈសេដ្ឋកិច្ច (ការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ ការទទួលបានទ្រព្យសកម្ម ប្រភពចំណូល ឬមធ្យោបាយនៃការចិញ្ចឹមជីវិត) ដែលជាលទ្ធផលនៃ (១). ការទទួលបានដីដោយមិនស្ម័គ្រចិត្ត ឬ (២). ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬលើការចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលបានកំណត់ដោយស្របច្បាប់។ (ADB SPS ឆ្នាំ២០០៩)។<br>អ្នកដែលរងផលប៉ះពាល់ (Affected persons) ក៏ត្រូវបានគេហៅសំដៅចំពោះអ្នកដែលត្រូវផ្លាស់ទីផងដែរ (Displaced persons)។ |
| ការទូទាត់សំណង | – | សំដៅលើការទូទាត់ជាសាច់ប្រាក់ ឬជាសន្តានចិត្តសម្រាប់ទ្រព្យសកម្ម ឬធនធានដែលត្រូវទទួលបាន ឬដែលរងផលប៉ះពាល់ដោយសារគម្រោង នៅពេលទ្រព្យសកម្មត្រូវជំនួស។ រាល់ការទូទាត់សំណងទាំងអស់ គឺផ្អែកលើគោលការណ៍តម្លៃជំនួស ដែលជាវិធីសាស្ត្រវាយតម្លៃទ្រព្យសកម្មដើម្បីជំនួសការខាតបង់តាមអត្រាទីផ្សារបច្ចុប្បន្ន បូករួមទាំងថ្លៃចំណាយលើប្រតិបត្តិការនានាដូចជា ថ្លៃរដ្ឋបាល ពន្ធ ការចុះបញ្ជី និងថ្លៃចេញប័ណ្ណកម្មសិទ្ធិជាដើម។ |
| ការពិគ្រោះយោបល់ | – | គឺជាដំណើរការមួយដែល (១). ចាប់ផ្តើមពីដំបូងក្នុងដំណាក់កាលរៀបចំគម្រោង ហើយត្រូវបានអនុវត្តនៅជំណាក់កាលផ្សេងៗគ្នានៃគម្រោង និងលទ្ធកម្មដីធ្លី និងវដ្តនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត, (២). ផ្តល់ការលាតត្រដាងទាន់ពេលវេលានូវព័ត៌មានដែលពាក់ព័ន្ធ និងគ្រប់គ្រាន់ជាភាសាខ្មែរ ដែលអាចយល់បាន និងងាយស្រួលដល់អ្នកដែលត្រូវផ្លាស់ទី, (៣). ធ្វើឡើងក្នុងបរិយាកាសដែលគ្មានការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ដោយគិតពីបទដ្ឋានវប្បធម៌, និង (៤). ដែលឆ្លើយតបទៅនឹងយេនឌ័រប្រកបដោយបរិយាប័ន្ន និងសម្របតាមតម្រូវការនៃក្រុមដែលបាត់បង់ឱកាស និងក្រុមដែលងាយរងគ្រោះ, អាចពិចារណាលើការបញ្ចូលនូវទស្សនៈពាក់ព័ន្ធទាំងអស់របស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតទៅក្នុងការសម្រេចចិត្ត ដូចជាការរចនាគម្រោង វិធានការកាត់បន្ថយ និងបញ្ហានៃការអនុវត្ត។ |

**របៀងនៃផលប៉ះពាល់** – គឺជាតំបន់ដែលត្រូវបានទាមទារដោយគម្រោង ឬដោយតម្រូវការដើម្បីរក្សាទុកជាទីតាំងសម្រាប់ប្រើប្រាស់នាពេលអនាគតសម្រាប់ការសាងសង់ ឬសម្រាប់ការជួសជុល និងការថែទាំនៃវិស័យសាធារណការ។

**កាលបរិច្ឆេទឱសានវាទ** – សម្រាប់គម្រោងនេះ (១). ប្រសិនបើអនុគម្រោងត្រូវបានរៀបចំដោយផ្អែកលើការសិក្សាសមិទ្ធិលទ្ធភាព នោះកាលបរិច្ឆេទឱសានវាទគឺជាកាលបរិច្ឆេទចាប់ផ្តើមនៃកិច្ចប្រជុំពិគ្រោះយោបល់លើកដំបូងជាមួយអ្នកដែលត្រូវផ្លាស់ទីក្នុងអំឡុងពេលជំរឿន, និង (២). ប្រសិនបើអនុគម្រោងត្រូវបានរៀបចំដោយផ្អែកលើការរចនាប្លង់វិស្វកម្មលម្អិត នោះកាលបរិច្ឆេទឱសានវាទគឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមការអង្កេតដោយវាស់វែងលម្អិត។ វាក៏ជាកាលបរិច្ឆេទដែលបង្កើតសិទ្ធិទទួលបានសំណង និងជំនួយសម្រាប់ការតាំងទីលំនៅថ្មីសម្រាប់អ្នកដែលត្រូវផ្លាស់ទី។ សម្រាប់តែអ្នកដែលត្រូវផ្លាស់ទី ដែលធ្លាប់មានជាកម្មសិទ្ធិកាន់កាប់ ឬរស់នៅលើដីដែលត្រូវដកហូតដោយគម្រោងគិតត្រឹមកាលបរិច្ឆេទនេះទាំងនោះទេ ដែលនឹងមានសិទ្ធិទទួលបានសំណង និងជំនួយសម្រាប់ការតាំងទីលំនៅថ្មី ស្របតាមម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន (Entitlement Matrix) ដែលបានបញ្ជាក់នៅក្នុងផែនការបែងចែកដី និងការតាំងទីលំនៅជាថ្មី។

**ការអង្កេតវាស់វែងលម្អិត** – ដោយមានជំនួយពីការរចនាប្លង់វិស្វកម្មលម្អិត សកម្មភាពនេះពាក់ព័ន្ធនឹងការបញ្ចប់សារពើភ័ណ្ឌនៃការខាតបង់ (IOL) ការវាស់វែងនៃការខាតបង់ ការស្ទង់មតិសេដ្ឋកិច្ចសង្គម ១០០% និងជំរឿនអ្នកដែលត្រូវផ្លាស់ទី ១០០%។

**គ្រួសារដែលត្រូវផ្លាស់ទី** – គ្រួសារណាក៏ដោយដែលរងផលប៉ះពាល់ដោយផ្ទាល់ជាលក្ខណៈរូបវន្ត និង/ឬជាលក្ខណៈសេដ្ឋកិច្ច ដោយសារតែការបែងចែកដីដី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ គ្រួសារ មានន័យថាមនុស្សទាំងអស់ដែលរស់នៅ និងហូបចុករួមគ្នាជាកោសិកាសង្គមតែមួយ។

**អ្នកដែលត្រូវផ្លាស់ទី** – នៅក្នុងបរិបទនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត អ្នកដែលត្រូវផ្លាស់ទី គឺជាអ្នកដែលត្រូវផ្លាស់ទីជាលក្ខណៈរូបវន្ត (ការផ្លាស់ទីលំនៅ ការបាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជម្រក) និង/ឬ ការផ្លាស់ទីជាលក្ខណៈសេដ្ឋកិច្ច (ការបាត់បង់ដីធ្លី ទ្រព្យសកម្មសិទ្ធិទទួលបានទ្រព្យសកម្ម ប្រភពចំណូល ឬមធ្យោបាយនៃការចិញ្ចឹមជីវិត។) ដែលជាលទ្ធផលនៃ (១). ការទទួលបានដីដោយមិនស្ម័គ្រចិត្ត ឬ (២). ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬលើការចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលបានកំណត់ដោយស្របច្បាប់។

| | | |
|---|---|---|
| **ការបាត់បង់ធនធានសេដ្ឋកិច្ច** | – | សំដៅលើការបាត់បង់ដីធ្លី ទ្រព្យសកម្ម លទ្ធភាពទទួលបានទ្រព្យសកម្ម ប្រភពចំណូល ឬមធ្យោបាយនៃការចិញ្ចឹមជីវិត ដោយសារតែ (១). ការទទួលបានដីដោយមិនស្ម័គ្រចិត្ត ឬ (២). ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬលើការចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលបានកំណត់ដោយស្របច្បាប់។ |
| **លទ្ធភាពទទួលបាន** | – | សំដៅលើមនុស្សណាម្នាក់ ឬនីតិបុគ្គលណាមួយ គ្រួសារ ក្រុមហ៊ុន ស្ថាប័នរដ្ឋ ឬឯកជន ដែលបានតាំងលំនៅក្នុងតំបន់គម្រោងមុនកាលបរិច្ឆេទឱសានវាទ ដែល (១). បាត់បង់ទីជម្រក, (២). បាត់បង់ទ្រព្យសកម្ម ឬលទ្ធភាពទទួលបានទ្រព្យសកម្មទាំងនោះជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន, ឬ (៣). បាត់បង់ប្រភពចំណូល ឬមធ្យោបាយនៃការចិញ្ចឹមជីវិតដោយមិនគិតពីការផ្លាស់ប្តូរទីលំនៅ នឹងមានសិទ្ធិទទួលបានសំណង និង/ឬជំនួយ។ |
| **សិទ្ធិទទួលបាន** | – | សំដៅលើវិធានការជាច្រើនដែលរួមមាន ការផ្តល់សំណង ការគាំទ្រលើការស្តារប្រាក់ចំណូលឡើងវិញ ជំនួយផ្ទេរ ការគាំទ្រលើការផ្លាស់ទី។ល។ អាស្រ័យលើប្រភេទ និងភាពធ្ងន់ធ្ងរនៃការខាតបង់របស់អ្នកដែលត្រូវផ្លាស់ទី ដើម្បីស្តារមូលដ្ឋានសេដ្ឋកិច្ច និងសង្គមរបស់ពួកគេឡើងវិញ។ |
| **ការស្តារប្រាក់ចំណូលឡើងវិញ** | – | សំដៅលើការបង្កើតឡើងវិញនូវមុខរបរចិញ្ចឹមជីវភាព ប្រកបដោយផលិតភាពរបស់អ្នកដែលត្រូវផ្លាស់ទី ដើម្បីអាចបង្កើតប្រាក់ចំណូលឱ្យបានក្នុងកម្រិតស្មើនឹង ឬប្រសិនបើអាចធ្វើទៅបាន ឱ្យបានប្រសើរជាងប្រាក់ចំណូលដែលពួកគេធ្លាប់រកបាន មុនការតាំងទីលំនៅជាថ្មី ឬមុនវត្តមានគម្រោង។ |
| **ជនជាតិដើមភាគតិច** | | បើយោងតាមគោលការណ៍ ADB-SPS ឆ្នាំ២០០៩ ពាក្យថា "ជនជាតិដើមភាគតិច" ត្រូវបានប្រើប្រាស់ក្នុងន័យទូទៅដើម្បីសំដៅទៅលើក្រុមប្រជាជន ដែលមានលក្ខណៈខុសប្លែកគេ ក្រុមងាយរងគ្រោះ ក្រុមសង្គម និងវប្បធម៌ ដែលមានបុគ្គលិកលក្ខណៈក្នុងកម្រិតផ្សេងៗគ្នាជាអាទិ៍៖<br>(១). ការកំណត់អត្តសញ្ញាណខ្លួនឯងជាសមាជិករបស់ក្រុមសង្គម និងក្រុមវប្បធម៌ជនជាតិដើមភាគតិចខុសប្លែកពីគេ និងការទទួលស្គាល់អត្តសញ្ញាណនេះពីអ្នកដទៃ។<br>(២). អារម្មណ៍ផ្សារភ្ជាប់ជាសមូហភាពទៅនឹងទីជម្រកដែលមានលក្ខណៈខុសប្លែកគេ ក្នុងភូមិសាស្ត្រ ឬទឹកដីដូនតាក្នុងតំបន់គម្រោង និងធនធានធម្មជាតិនៅក្នុងទីជម្រក និងទឹកដីទាំងនេះ។<br>(៣). ស្ថាប័នវប្បធម៌ទំនៀមទម្លាប់ សេដ្ឋកិច្ច សង្គម ឬនយោបាយ មានលក្ខណៈដាច់ដោយឡែកពីស្ថាប័នរបស់សង្គម និងវប្បធម៌ជារួម។ |

(៤). ភាសាខុសប្លែកពីគ្នា ដែលខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។

**សារពើភ័ណ្ឌនៃការខាតបង់** – គឺជាដំណើរការដែលទ្រព្យសកម្មថេរទាំងអស់ (ឧ. ដីប្រើប្រាស់សម្រាប់សង់លំនៅដ្ឋាន ពាណិជ្ជកម្ម កសិកម្ម រួមទាំងស្រះទឹក អគារលំនៅដ្ឋាន តូប និងហាង រចនាសម្ព័ន្ធបន្ទាប់បន្សំដូចជា របង ផ្នូរ អណ្តូង ដើមឈើដែលមានតម្លៃផ្នែកពាណិជ្ជកម្ម។ល។) និងប្រភពនៃប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិតនៅក្នុងទីតាំងកាន់កាប់ស្របច្បាប់របស់គម្រោង ត្រូវបានកំណត់ វាស់វែង ម្ចាស់របស់ពួកគេបានកំណត់ ទីតាំងពិតប្រាកដរបស់ពួកគេត្រូវបានបញ្ជាក់ និងតម្លៃជំនួសរបស់ពួកគេត្រូវបានគណនា។ លើសពីនេះទៀត ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ចំពោះទ្រព្យសកម្មដែលរងផលប៉ះពាល់ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិត និងសមត្ថភាពផលិតភាពរបស់អ្នកដែលត្រូវផ្លាស់ទី នឹងត្រូវបានកំណត់។

**ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត** – សំដៅលើការដែលអ្នកដែលត្រូវផ្លាស់ទី មិនមានសិទ្ធិបដិសេធចំពោះការបែងចែកដីដោយរដ្ឋ ដែលបណ្តាលឱ្យមានការផ្លាស់ទីលំនៅរបស់ពួកគេ ដែលកើតឡើងនៅពេលដែលដីត្រូវបានទទួលតាមរយៈ (១). ការដកហូតដោយអំណាចអស្សាមិករណ៍របស់រដ្ឋ ឬ (២). ដីត្រូវបានទទួលតាមរយៈដំណោះស្រាយដោយការចរចា នៅពេលដែលតម្លៃត្រូវបានចរចា ហើយការបរាជ័យនឹងនាំឱ្យមានការដកហូត តាមរយៈអំណាចអស្សាមិករណ៍របស់រដ្ឋ។

**លទ្ធកម្មដីធ្លី** – សំដៅលើដំណើរការដែលនីតិបុគ្គល គ្រួសារ ក្រុមហ៊ុន ឬស្ថាប័នឯកជនត្រូវបានបង្ខំដោយភ្នាក់ងាររដ្ឋឱ្យផ្ទេរកម្មសិទ្ធិនៃដីទាំងស្រុង ឬដោយផ្នែកដែលខ្លួនអាស្រ័យផល ឬកាន់កាប់ទៅជាកម្មសិទ្ធិ និងការកាន់កាប់របស់ទីភ្នាក់ងារនោះ សម្រាប់គោលបំណងសាធារណៈជាថ្នូរនឹងសំណងក្នុងតម្លៃជំនួស។

**ដំណោះស្រាយដោយការចរចា** – សំដៅលើការអនុវត្តចំពោះសិទ្ធិដីធ្លី ឬសិទ្ធិប្រើប្រាស់ដីដែលទទួលបាន ឬដែលដាក់កម្រិតតាមរយៈការចរចាជាមួយម្ចាស់អចលនទ្រព្យ ឬអ្នកដែលមានសិទ្ធិស្របច្បាប់លើដីនោះ ហើយប្រសិនបើមិនអាចឈានដល់ដំណោះស្រាយណាមួយទេ នោះនឹងបណ្តាលឱ្យមានការដកហូត ឬនីតិវិធីជាលក្ខណៈកាតព្វកិច្ចផ្សេងទៀត (SPS ឧបសម្ព័ន្ធទី ២ ទំព័រ ៤៨ កថាខណ្ឌ ២៥)។ ដំណោះស្រាយដោយការចរចា ត្រូវបានប្រើដើម្បីបញ្ចៀសការដកហូត និងលុបបំបាត់តម្រូវការនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ រដ្ឋាភិបាលអាចទទួលបានដី និងទ្រព្យសកម្មផ្សេងទៀតតាមរយៈការចរចា ដោយផ្អែកលើការពិគ្រោះប្រកបដោយអត្ថន័យជាមួយអ្នកដែលរងផលប៉ះពាល់ រួមទាំងអ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់។ ដំណោះស្រាយដោយការចរចា នឹងផ្តល់តម្លៃសមរម្យ និងយុត្តិធម៌សម្រាប់ដី និង/ឬទ្រព្យសកម្មផ្សេងទៀត។ រដ្ឋាភិបាលនឹងធានាថាការចរចាទាំងឡាយជាមួយអ្នកដែលត្រូវផ្លាស់ទី

ពិតជាបានដោះស្រាយដោយបើកចំហនូវហានិភ័យនៃភាពមិនស៊ីសង្វាក់គ្នានៃព័ត៌មាន និងអំណាចចរចារបស់ភាគីពាក់ព័ន្ធក្នុងការចរចាសម្រេចបែបនេះ។ សម្រាប់គោលបំណងនេះ រដ្ឋាភិបាលអាចចូលរួមជាមួយភាគីឯករាជ្យពីខាងក្រៅ ដើម្បីចងក្រងឯកសារពីដំណើរការចរចា និងដំណោះស្រាយ។

**ការផ្លាស់ទីជាលក្ខណៈរូបវន្ត** – សំដៅលើការផ្លាស់ទី ការបាត់បង់ដីលំនៅឋាន ឬការបាត់បង់ទីជម្រក ដោយសារតែ (១). ការទទួលបានដីដោយមិនស្ម័គ្រចិត្ត ឬ (២). ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬលើការចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលបានកំណត់ដោយស្របច្បាប់។

**ការផ្លាស់ប្តូរទីតាំង** – សំដៅលើការផ្លាស់ទីជារូបវន្តរបស់អ្នកដែលត្រូវផ្លាស់ទីចេញពីកន្លែងធ្លាប់រស់នៅ និង/ឬអាជីវកម្មមុនវត្តមានគម្រោង។

**តម្លៃជំនួស** – តម្លៃជំនួសពាក់ព័ន្ធនឹងការជំនួសទ្រព្យសកម្ម រួមទាំងដី ក្នុងតម្លៃដែលមានស្រាប់នៅពេលទិញ។ នេះរាប់បញ្ចូលទាំងតម្លៃទីផ្សារសមរម្យ ថ្លៃប្រតិបត្តិការ ការប្រាក់បង្គរ ថ្លៃអន្តរកាល និងការស្តារឡើងវិញ និងការបង់ប្រាក់ដែលអាចអនុវត្តបានផ្សេងទៀត ប្រសិនបើមាន។ ការបញ្ចុះតម្លៃនៃទ្រព្យសកម្ម និងរចនាសម្ព័ន្ធនានា មិនគួរត្រូវបានពិចារណាសម្រាប់តម្លៃជំនួសឡើយ។ នៅកន្លែងដែលមិនមានលក្ខខណ្ឌទីផ្សារសកម្ម តម្លៃនៃការជំនួសគឺស្មើនឹងតម្លៃដឹកជញ្ជូន និងសម្ភារៈសំណង់ តម្លៃពលកម្មសម្រាប់ការសាងសង់ ឬតម្លៃផ្លាស់ប្តូរទីតាំង។ នៅពេលដែលលក្ខខណ្ឌទីផ្សារដីធ្លីឥតមាន ឬស្ថិតក្នុងដំណាក់កាលបង្កើត នោះអ្នកដែលត្រូវផ្លាស់ទី និងប្រជាជនជាម្ចាស់ នឹងត្រូវបានពិគ្រោះយោបល់ជាមួយដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់អំពីប្រតិបត្តិការដីធ្លីថ្មីៗ តម្លៃដីតាមប្រភេទ ប័ណ្ណកម្មសិទ្ធិ ការប្រើប្រាស់ដី គំរូដំណាំ និងផលិតកម្មដំណាំ លទ្ធភាពអាចរកបានដី នៅក្នុងទីតាំងគម្រោង និងនៅក្នុងតំបន់ ក៏ដូចជាព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

**ការសិក្សាតម្លៃជំនួស** – សំដៅលើដំណើរការដែលពាក់ព័ន្ធក្នុងការកំណត់ថ្លៃជំនួសនៃទ្រព្យសកម្ម និងដីដែលរងផលប៉ះពាល់ និងត្រូវអនុវត្តដោយទីប្រឹក្សាជាតិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឯករាជ្យ (ក្រុមហ៊ុន ឬនីតិបុគ្គល) ដែលមានជំនាញចាំបាច់ដើម្បីធ្វើការវាយតម្លៃទ្រព្យសកម្ម។

**ផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោង** – សំដៅលើផែនការសកម្មភាពតាមពេលកំណត់ ដោយមានថវិកា ការកំណត់គោលដៅ និងយុទ្ធសាស្ត្រនៃការតាំងទីលំនៅជាថ្មី ការផ្តល់សិទ្ធិទទួលបានប្រាក់ចំណូល និងយុទ្ធសាស្ត្រ

ស្តារជីវភាពឡើងវិញ ការរៀបចំស្ថាប័ន ក្របខ័ណ្ឌត្រួតពិនិត្យតាមដាន និងរាយការណ៍ ការរៀបចំថវិកា និងកាលវិភាគនៃការអនុវត្ត។

**ផលប៉ះពាល់ធំជាងគេ** – សំដៅលើគ្រួសារដែលត្រូវផ្លាស់ទី ដែលនឹង (១). ខាតបង់ ១០% ឬច្រើនជាងនេះនៃទំហំដីដែលមានផលិតភាពសរុប និង/ឬទ្រព្យសកម្មរបស់ខ្លួន, (២). ត្រូវផ្លាស់ប្តូរទីតាំង, និង/ឬ (៣). ខាតបង់ ១០% ឬច្រើនជាងនេះនៃប្រភពចំណូលសរុបរបស់ខ្លួន ដោយសារគម្រោង។

**ក្រុមងាយរងគ្រោះ**[2] – សំដៅលើក្រុមដែលមានលក្ខណៈខុសប្លែកពីគេក្នុងចំណោមអ្នកដែលត្រូវផ្លាស់ទី ដែលទំនងជារងផលប៉ះពាល់ខ្លាំងជាងអ្នកផ្សេងទៀត ហើយដែលទំនងជាមានសមត្ថភាពតិចតួចបំផុតក្នុងការស្តារជីវភាពរស់នៅឡើងវិញ ឬកែលម្អស្ថានភាពរបស់ពួកគេ ក្នុងនោះរួមមាន (១). គ្រួសារទាំងអស់ដែលរស់នៅក្រោមអត្រាភាពក្រីក្រជាតិដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា, (២). ស្ត្រីជាមេគ្រួសារដែលមានអ្នកនៅក្នុងបន្ទុករស់នៅក្រោមអត្រាភាពក្រីក្រជាតិ, (៣). ជនពិការជាមេគ្រួសារដែលគ្មានមធ្យោបាយគាំទ្រផ្សេងទៀត, (៤). មនុស្សចាស់ជាមេគ្រួសារដែលគ្មានមធ្យោបាយគាំទ្រ, និង (៥). ជនជាតិដើមភាគតិច (ដែលជារឿយៗមានសិទ្ធិកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណី ប៉ុន្តែមិនមានប័ណ្ណកម្មសិទ្ធិផ្លូវការ ឬប្លង់រឹងទេ)។

**អ្នកទិញដោយស្ម័គ្រចិត្ត អ្នកលក់ដោយស្ម័គ្រចិត្ត** – គឺជាដំណើរការដែលរដ្ឋាភិបាលទិញអចលនទ្រព្យពីម្ចាស់ឯកជន ជាមួយនឹងតម្លៃទីផ្សារសមរម្យ ដែលអ្នកលក់ស្ម័គ្រចិត្តយល់ព្រម។ នៅក្នុងការប្រតិបត្តិការទិញលក់នេះ ភាគីទាំងសងខាងមិនស្ថិតនៅក្រោមការបង្ខិតបង្ខំណាមួយឱ្យទិញ ឬលក់ឡើយ ហើយភាគីទាំងពីរមានការយល់ដឹងសមហេតុផលនៃអង្គហេតុដែលពាក់ព័ន្ធ ហើយអំណាចអស្សាមិករណ៍មិនត្រូវបានប្រើឡើយ។

[2] ក្រុមនេះ ត្រូវបានចាត់ថ្នាក់តាមអនុក្រឹត្យលេខ ២៩១ អនក្រ.បក ស្តីពីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដោយការចេញប័ណ្ណក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា។

**ចំណាំ**

នៅក្នុងរបាយការណ៍នេះ "$" សំដៅលើក្រដាសប្រាក់ដុល្លារសហរដ្ឋអាមេរិក

ក្របខ័ណ្ឌគោលនយោបាយលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់នេះ គឺជាឯកសាររបស់ប្រទេសទទួលកម្ចី។ ទស្សនៈដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ ឬបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឡើយ ហើយអាចជាលក្ខណៈបឋម។ សូមអ្នកអាចយកចិត្តទុកដាក់ទៅលើផ្នែក "លក្ខខណ្ឌនៃការប្រើប្រាស់" ចំពោះគេហទំព័រនេះ។

ក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រ ការផ្តល់ហិរញ្ញប្បទានដល់គម្រោងណាមួយរបស់ប្រទេសណាមួយ ឬដោយការជ្រើសរើសទុកជាមុន ឬយោងទៅលើទឹកដី ឬទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយនៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី គ្មានបំណងធ្វើការវិនិច្ឆ័យណាមួយទៅលើស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពផ្សេងទៀតនៃទឹកដី ឬតំបន់ណាមួយ។

# មាតិកា


សេចក្តីសង្ខេប i

I. សេចក្តីផ្តើម 6

ក. ការការពិពណ៌នាគម្រោង 6

II. សន្និធានភាពនៃក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ 12

ក. លទ្ធផលទី ១៖ អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ 12

១. មណ្ឌលត្រួតពិនិត្យសត្វ និងចត្តាឡីស័ក និងតំបន់គ្រប់គ្រងជំងឺទី ១ 12

២. មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ (NVVC) 12

៣. មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC) 13

៤. ផ្សារលក់មាន់ទារស់ដូនកែវ (DKLBM) 13

៥. វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ (NAHPRI) 15

III. គោលបំណង ក្របខ័ណ្ឌគោលនយោបាយ និងសិទ្ធិទទួលបាន 16

ក. កម្មវត្ថុនៃក្របខ័ណ្ឌស្តីពីការបែងចែកដីធ្លី និងការតាំងទីលំនៅជាថ្មី 16

ខ. គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ 16

១. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ 16

២. ច្បាប់ភូមិបាល ឆ្នាំ២០០១ 16

៣. ច្បាប់ស្តីពីអស្សាមិករណ៍ 18

៤. ច្បាប់ជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត 19

៥. គោលនយោបាយដោះស្រាយផលប៉ះពាល់, សេចក្តីថ្លែងគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS-ADB) 21

៦. គោលនយោបាយពាក់ព័ន្ធផ្សេងទៀតរបស់ ADB 23

ឃ.ការប្រៀបធៀបរវាងគោលការណ៍ ADB-SPS (2009) និងច្បាប់ និងបទប្បញ្ញត្តិប្រទេសកម្ពុជា 24

គ. ការពិនិត្យពិច័យលើអនុគម្រោង និងការចាត់ថ្នាក់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត 31

ឃ. លទ្ធភាពទទួលបាន និងសិទ្ធិទទួលបាន 32

១. លទ្ធភាពទទួលបាន 32

២. សិទ្ធិទទួលបាន 33

ង. វិធីសាស្រ្ត និងជម្រើសនៃលទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត 33

១. វិធីសាស្រ្តទិញ-លក់ដោយស្ម័គ្រចិត្ត (WBWS) 34

២. វិធីសាស្រ្តដោះស្រាយដោយការចរចា 35

ច. វិធានការដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់នៃការតាំងទីលំនៅថ្មី 37

IV. ព័ត៌មានសេដ្ឋកិច្ចសង្គម 38

ក. ការវាយតម្លៃហេតុប៉ះពាល់សង្គម 38
ខ. វិធីសាស្រ្តសម្រាប់ការស្ទង់អង្កេតដោយវាស់វែងលម្អិត 39
គ. ការកំណត់ថ្លៃដើមជំនួស 40
ឃ. ការរៀបចំ និងការដាក់បញ្ជូនសេចក្តីព្រាង និងផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) 41
V. **ការពិគ្រោះយោបល់ ការចូលរួម និងការបញ្ចេញព័ត៌មាន** 42
ក. ការពិគ្រោះយោបល់ និងការចូលរួម 42
ខ. ការបញ្ចេញព័ត៌មាន 42
VI. **ការផ្តល់សំណង ការស្តារប្រាក់ចំណូលឡើងវិញ និងការផ្លាស់ទី** 44
ក. វិធានការផ្តល់សំណង 44
ខ. កម្មវិធីស្តារប្រាក់ចំណូលឡើងវិញ (IRP) 45
VII. **យន្តការដោះស្រាយការសោកស្តាយ** 55
ក. គោលបំណងនៃយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) 55
ខ. ដំណើរការដោះស្រាយបណ្តឹងតវ៉ា 55
VIII. **ការរៀបចំស្ថាប័ន និងការអនុវត្ត** 59
ក. ការរៀបចំស្ថាប័ន 59
ខ. កាលវិភាគនៃការអនុវត្ត 65
IX. **ថវិកា និងការផ្តល់ហិរញ្ញប្បទាន** 67
ក. ថវិកា និការផ្តល់ហិរញ្ញប្បទាន 67
ខ. លំហូរនៃមូលនិធិសម្រាប់សំណង និងជំនួយសាច់ប្រាក់ 67
X. **ការត្រួតពិនិត្យ និងការរាយការណ៍** 70
**ឧបសម្ព័ន្ធ** 1. **បញ្ជីត្រួតពិនិត្យផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត** 72
**ឧបសម្ព័ន្ធទី** 2. **ដំណើរការពិគ្រោះយោបល់** 76
**ឧបសម្ព័ន្ធទី** 3. **សូចនាករនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ផែនការដោះស្រាយផលប៉ះពាល់លម្អិត** (DRP) 79

# សេចក្ដីសង្ខេប

១.	ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF) នេះ ត្រូវបានរៀបចំឡើងសម្រាប់ (គម្រោង) សុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែប្រវាក់តម្លៃសត្វ (CLHVCIP)។ ក្របខ័ណ្ឌនេះទៀតសោតបង្ហាញពីគោលការណ៍ គោលនយោបាយ នីតិវិធី និងការរៀបចំស្ថាប័ន ដើម្បីកាត់បន្ថយហានិភ័យនានា និងផ្ដល់ឱកាសចិញ្ចឹមជីវិត និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។ ក្របខ័ណ្ឌនេះ ត្រូវបានចងក្រងឡើងដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្ដីថ្លែងគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB-SPS) ឆ្នាំ២០០៩។

២.	គម្រោងនេះ (CLHVCIP) មានលក្ខណៈស្របតាមផលជះជាអាទិ៍៖ ចក្ខុវិស័យនៃមហាអនុតំបន់ទន្លេមេគង្គក្នុងតួនាទីជាអ្នកផ្គត់ផ្គង់ឈានមុខគេលើផលិតផលកសិកម្មប្រកបដោយសុវត្ថិភាព និងមានលក្ខណៈមេត្រីភាពចំពោះបរិស្ថាន (យុទ្ធសាស្ត្រលើកកម្ពស់ខ្សែស្រវាក់តម្លៃកសិផលប្រកបដោយសុវត្ថិភាព និងមានលក្ខណៈមេត្រីភាពចំពោះបរិស្ថាន នៅក្នុងមហាអនុតំបន់មេគង្គ និងផែនការសកម្មភាពខេត្តសៀមរាប ឆ្នាំ ២០១៨-២០២២)។ លទ្ធផលរំពឹងទុកនៃគម្រោងនេះ គឺការកែលម្អសុខភាព ខ្សែប្រវាក់តម្លៃ និងពាណិជ្ជកម្មផ្លូវការនៃបសុសត្វ និងផលិតផលសត្វ។ គម្រោងនេះ នឹងត្រូវអនុវត្តក្នុងខេត្តគោលដៅចំនួន ៦ រួមមាន៖ ខេត្តកំពង់ចាម ឧត្ដរមានជ័យ រាជធានីភ្នំពេញ ព្រៃវែង សៀមរាប និងតាកែវ មានលទ្ធផលធំៗចំនួនបី៖ (១). ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វ និងខ្សែប្រវាក់តម្លៃសត្វ ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ។ (២). សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលសត្វ ត្រូវបានពង្រឹង។ និង (៣). ការរៀបចំជំរុញការអនុវត្តគោលនយោបាយសម្រាប់ការផ្គត់ផ្គង់ សុខភាព សុវត្ថិភាព និងពាណិជ្ជកម្ម និងផលិតផលសត្វ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។

៣.	តាំងពីដើមដំបូងមក រាជរដ្ឋាភិបាលកម្ពុជាមានចេតនាដើម្បីធ្វើយ៉ាងណាឱ្យអនុគម្រោងអភិវឌ្ឍន៍ទាំងឡាយអាចបញ្ចៀសឱ្យខាងតែបាននូវការពាក់ព័ន្ធនឹងការបែងចែងដីធ្លី ឬការតាំងលំនៅជាថ្មីណាមួយ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏រាជរដ្ឋាភិបាលនៅតែទទួលស្គាល់ថាក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ គឺជាការចាំបាច់ដើម្បីទប់ស្កាត់ផលប៉ះពាល់ទាំងឡាយណាដែលមិនបានមើលឃើញទុកជាមុន។ អនុគម្រោងជាក់លាក់ទាំងប្រាំ រួមមាន៖ ការបង្កើតមណ្ឌលត្រួតពិនិត្យសត្វនៅក្នុងខេត្តឧត្ដរមានជ័យ (OMLIC), ការបង្កើតមជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ (NVVC) នៅក្នុងខេត្តកណ្ដាល, ការបង្កើតមជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC) នៅក្នុងខេត្តកំពង់ធំ, ការបង្កើតផ្សារលក់ដូរមាន់ទារស់ដូនកែវ (DKLBM) នៅក្នុងខេត្តតាកែវ និងការកែលម្អអគារមន្ទីរពិសោធន៍នៃវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ (NAHPRI) នៅរាជធានីភ្នំពេញ។ ផ្អែកតាមលទ្ធផលនៃការអនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយការពារដែលបានធ្វើឡើងនៅចន្លោះខែមិថុនា ឆ្នាំ២០២១ ដល់ខែឧសភា ឆ្នាំ២០២២ ឃើញថាអនុគម្រោងទាំងនេះ នឹងមិនបង្កផលប៉ះពាល់ដល់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តនោះទេ ពីព្រោះមិនមានការផ្លាស់ទីជាលក្ខណៈរូបវន្ត ឬជាលក្ខណៈសេដ្ឋកិច្ចណាមួយឡើយ។ រាល់

ការងារសាងសង់ក្រោមអនុគម្រោងទាំងប្រាំនេះ នឹងធ្វើឡើងនៅលើដីរដ្ឋ ការទិញយកដីឯកជនពីបុគ្គល និង/ឬគ្រួសារប្រជាពលរដ្ឋ ដូច្នេះមិនទាមទារឱ្យមានការបែងចែកដីធ្លី ឬការតាំងទីលំនៅជាថ្មីណាមួយឡើយ។ សម្រាប់គម្រោងសាងសង់ផ្សារលក់មាន់ទារស់ដូនកែវ (DKLBM) នឹងមានផលប៉ះពាល់បណ្តោះអាសន្នមួយចំនួនដោយសារអ្នកលក់ដូរទាទាំងនោះ នឹងត្រូវផ្លាស់ទីតាំងទៅផ្នែកផ្សេងទៀតនៅក្នុងផ្សារដដែល ប៉ុន្តែត្រូវបានគេកំណត់ថានឹងមិនប៉ះពាល់ដល់ការរកប្រាក់ចំណូល ឬសុខុមាលភាពរបស់អាជីវករទាំងនោះទេ។

៤. ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF) ត្រូវបានរៀបចំឡើងដើម្បីណែនាំដល់ការសម្រិតសម្រាំងអនុគម្រោង ការពិនិត្យពិច័យ និងការចាត់ថ្នាក់អនុគម្រោងទាំងអស់ ទាក់ទងនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (IR) ការវាយតម្លៃផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ការរៀបចំ និងការអនុវត្តផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) និងរបាយការណ៍ស្តីពីការអនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយការពារ (DDRs) និងការត្រួតពិនិត្យតាមដានលើការអនុវត្ត RP ។ ស្របដែលអនុគម្រោងទាំងប្រាំដែលបានគ្រោងទុក មិនបង្កឱ្យមានការព្រួយបារម្ភទាក់ទងនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត នោះក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់តម្រូវឱ្យកំណត់ពីផលប៉ះពាល់ដែលអាចកើតមានទាក់ទងនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដោយសារគម្រោងបន្ទាប់បន្សំផ្សេងទៀតដែលអាចមាននាពេលអនាគត ជាពិសេសលើបញ្ហាចម្បងក្នុងការរកប្រាក់ចំណូលរបស់អ្នកទទួលរងផលប៉ះពាល់ (AP) ដោយសារការរៀបចំកែលម្អ និងពង្រីកបន្ថែម ដូចជាកន្លែងសត្តឃាត និងផ្សារលក់ដូរ ដែលអាចនឹងរងផលប៉ះពាល់មួយចំនួនជាបណ្តោះអាសន្ន។ ទោះជាយ៉ាងណាក៏ដោយ គម្រោងនេះនឹងមិនគាំទ្រចំពោះទម្រង់ណាមួយនៃការផ្លាស់ប្តូរទីតាំងជាលក្ខណៈរូបវន្ត ហើយក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ មិនបានរាប់បញ្ចូលការផ្តល់ជូនណាមួយសម្រាប់សកម្មភាពបែបនេះទេ។ សម្រាប់អនុគម្រោង ដែលត្រូវបានបង្កើតឡើងអំឡុងពេលអនុវត្តគម្រោង ចាំបាច់ត្រូវអនុវត្តវិធានការនានាដើម្បីបញ្ចៀសនូវរាល់ផលប៉ះពាល់ទាំងអស់នៃការតាំងទីលំនៅជាថ្មី។

៥. ជាទូទៅ មិនមានគម្លាតខ្លាំងប៉ុន្មានទេរវាងគោលនយោបាយគាំពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធៀបនឹងគោលនយោបាយគាំពារ ក៏ដូចជាគោលនយោបាយទាក់ទងនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅត្រង់កន្លែងណាសដែលមានគម្លាត (ទាក់ទងនឹងផលប៉ះពាល់លើជីវភាពរស់នៅ និងភាពធ្ងន់ធ្ងរនៃការខាតបង់ណាមួយ) ក្រោមក្របខ័ណ្ឌ RF បានធានាថាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលទ្ធផលនៃការអនុវត្តជារៀងរាល់ត្រីមាស និងស្ថានភាពរបស់អ្នកដែលរងផលប៉ះពាល់។ នេះមានន័យថាផែនការលម្អិត DRP ដែលអាចកើតមានណាមួយ អាចត្រូវបានត្រួតពិនិត្យដើម្បីធានាថាអ្នកដែលរងផលប៉ះពាល់ទាំងអស់ មិនគ្រាន់តែអាចទទួលបានប្រាក់ចំណូលរបស់ពួកគេឡើងវិញនៅត្រឹមកម្រិតមុនវត្តមានគម្រោងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានកែលម្អឱ្យប្រសើរជាងនេះទៀតផង។

៦. បន្ទាប់ពីការពិនិត្យពិច័យលើអនុគម្រោងសម្រាប់ផលប៉ះពាល់ IR រួចមក គេបានវាយតម្លៃថាមានផលប៉ះពាល់បែបនេះ នៅពេលប្រមូលព័ត៌មានទាក់ទងនឹងសេដ្ឋកិច្ចសង្គម និងទម្រង់នានាដែលបានរៀបចំទុកសម្រាប់ការធ្វើផែនការ DRP ណាមួយ។ ការពិនិត្យពិច័យនេះ រួមបញ្ចូលទាំងជំហានបឋម ការស្ទង់មតិសេដ្ឋកិច្ចសង្គម (SES) ក្នុងចំណោមអ្នកដែលរងផលប៉ះពាល់។ ស្របពេលជាមួយគ្នានេះដែរ ការធ្វើជំរឿន (Census) និងការធ្វើសារពើភ័ណ្ឌនៃការខាតបង់ (IOL) នឹងត្រូវធ្វើឡើងដោយក្នុងអំឡុងពេលរៀបចំអនុគម្រោងជំហានដំបូង។ ផ្អែកលើការរចនាប្លង់វិស្វកម្មលម្អិត (DED) នេះ ការអង្កេតវាស់វែងលម្អិត (DMS) នឹងត្រូវអនុវត្តចំពោះទីតាំងដីដែលរងផលប៉ះពាល់ និងចំពោះទ្រព្យសកម្មមិនមែនដីរបស់គ្រួសារទាំងអស់ ដែលរងផលប៉ះពាល់ដោយសារការអនុវត្តអនុគម្រោងនោះ។ ផ្អែកលើ DMS នេះ បានកំណត់ថាសំណងសម្រាប់ការបង្កើតប្រាក់ចំណូល ឬក្នុងករណីប៉ះពាល់ដល់ទ្រព្យសកម្មដទៃទៀតទៅដល់អ្នកដែលរងផលប៉ះពាល់នឹងត្រូវបានផ្តល់ជូន ហើយវិធានការស្តារប្រាក់ចំណូលចាំបាច់ណាមួយនឹងត្រូវអនុវត្តតាមម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបានដែលមានកំណត់នៅក្នុង RF។ សិទ្ធិទទួលបានសំណង នឹងត្រូវអនុវត្តផ្អែកតាមកាលបរិច្ឆេទឱសានវាទរបស់អនុគម្រោង។ ម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន គ្របដណ្តប់គ្រប់ប្រភេទនៃការប្រើប្រាស់ដីធ្លីទាំងអស់ ប៉ុន្តែពាក់ព័ន្ធនឹងគម្រោងនេះ ភាគច្រើនទំនងជាផលប៉ះពាល់បណ្តោះអាសន្នតែប៉ុណ្ណោះ។ វិធីសាស្ត្រសម្រាប់ការវាយតម្លៃទ្រព្យសកម្មដែលរងផលប៉ះពាល់ គឺផ្អែកលើប្រភេទនៃទ្រព្យទាំងនោះដែលបានកំណត់ឃើញថាអាចនឹងរងផលប៉ះពាល់ដោយសារគម្រោង។ ទន្ទឹមនឹងនេះ ការសិក្សាតម្លៃជំនួស (RCS) នឹងត្រូវធ្វើឡើងដោយក្រុមហ៊ុនឯករាជ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានបទពិសោធន៍ក្នុងការវាយតម្លៃទ្រព្យសកម្ម ដើម្បីកំណត់អត្រាទីផ្សារនៃទ្រព្យដែលរងផលប៉ះពាល់ទាំងនោះ។

៧. ការពិគ្រោះយោបល់ជាមួយអ្នករងផលប៉ះពាល់ គឺជាការចាំបាច់ក្នុងអំឡុងពេលនៃការរៀបចំការសិក្សាសមិទ្ធិលទ្ធភាព ដំណាក់កាលរចនាប្លង់លម្អិត ដំណើរការសាងសង់ និងប្រតិបត្តិការ និងការថែទាំ ប៉ុន្តែតាមរយៈការពិនិត្យពិច័យលើផលប៉ះពាល់ គេបានវាយតម្លៃថាទំនងជាអាចមានផលប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ ដំណើរការនេះត្រូវបានធ្វើឡើងសម្រាប់អនុគម្រោងទាំងប្រាំ ប៉ុន្តែមានតែអនុគម្រោងមួយប៉ុណ្ណោះ គឺការកែលម្អផ្សារលក់មាន់ទារស់ដូនកែវ (DKLBM) នៅក្នុងខេត្តតាកែវ ដែលត្រូវបានគេវាយតម្លៃថាអាចនឹងបណ្តាលឱ្យមានផលប៉ះពាល់ខ្លះៗជាបណ្តោះអាសន្ន។ កាតព្វកិច្ចផ្នែកគោលនយោបាយការពារដែលបានអនុវត្ត នឹងត្រូវដាក់បញ្ចូលនៅក្នុងឯកសារគម្រោង សម្រាប់ជាភស្តុតាងដែលបង្ហាញថាការពិគ្រោះយោបល់ពិតជាត្រូវបានធ្វើឡើងរួចហើយ។ ការពិគ្រោះយោបល់ទាំងនេះ ត្រូវបានសម្របសម្រួលនៅថ្នាក់ភូមិ ឃុំសង្កាត់ និងស្រុក ហើយតម្រូវឱ្យរួមបញ្ចូលយេនឌ័រប្រកបដោយបរិយាប័ន្ន និងដោយមានការបែងចែកទៅតាមភេទ អាយុ ឬ ស្ថានភាពសង្គមសេដ្ឋកិច្ចរបស់អ្នកដែលរងផលប៉ះពាល់ទាំងអស់រៀងៗខ្លួនផងដែរ។ ការពិភាក្សាជាក្រុម (FGD) ដែលមានអ្នកចូលរួមចំនួន ១០-១៥ នាក់ក្នុងមួយក្រុម ហើយប្រសិនបើចាំបាច់ ត្រូវបំបែកក្រុមពិភាក្សាឱ្យដាច់ដោយឡែករវាងក្រុមស្ត្រី និងបុរស ឬក្រុមអ្នករងផលប៉ះពាល់ក្រីក្រ និងក្រុមងាយរងគ្រោះ។ ព័ត៌មាន និងឯកសារផ្សេងៗជាភាសាខ្មែរ ក៏ត្រូវបានលាតត្រដាងក្នុងនោះរួមមាន ខិត្តប័ណ្ណព័ត៌មានសង្ខេបអំពីគម្រោង ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF) សេចក្តីព្រាងរបាយការណ៍អនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយ (DRP) និងការអនុវត្ត DRP ដែលត្រៀមរួចជាស្រេច និងរបាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមពាក់កណ្តាលឆ្នាំ (ប្រចាំឆមាស) រួមទាំងវិធីសាស្ត្រ

ទំនាក់ទំនងសមស្រប ត្រូវបានកំណត់សម្រាប់មនុស្សដែលមិនចេះអក្សរផងដែរ។ ជាមួយគ្នាផងដែរ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ(GDAHP) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏នឹងបញ្ចេញព័ត៌មានពាក់ព័ន្ធនឹងគម្រោងជាភាសាខ្មែរ និងភាសាអង់គ្លេសនៅលើគេហទំព័ររបស់ខ្លួនផងដែរ។

៨. យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) ត្រូវបានរៀបចំដើម្បីកំណត់ជំហានដែលអ្នករងផលប៉ះពាល់ទាំងអស់ អាចស្វែងរកដំណោះស្រាយចំពោះការប្តឹងតវ៉ាណាមួយ។ យន្តការ GRM នេះ គឺផ្អែកលើដំណើរការដែលមាននៅក្នុងប្រទេសកម្ពុជា សំដៅស្វែងរកដំណោះស្រាយ រួមទាំងមធ្យោបាយចុងក្រោយនៃការដោះស្រាយដោយប្រព័ន្ធតុលាការ។ ការស្វែងរកដំណោះស្រាយចំពោះការប្តឹងតវ៉ាណាមួយ ក៏អាចអនុវត្តបានតាមរយៈ ADB ផងដែរ ក្នុងករណីមិនមានលទ្ធផលជាទីគាប់ចិត្តនៅក្នុងមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយក្របខ័ណ្ឌ RF ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានដូច្នេះថា៖ ប្រសិនបើអាចធ្វើទៅបាន បណ្តឹងតវ៉ាគួរតែត្រូវបានដោះស្រាយនៅត្រឹមកម្រិតមូលដ្ឋានជាការស្រេច។

៩. រាល់ការចំណាយសម្រាប់សំណង និងជំនួយសម្រាប់ការតាំងទីលំនៅថ្មីទាំងអស់នៅក្រោមអនុគម្រោង នឹងត្រូវបានផ្តល់ហិរញ្ញប្បទានពីកញ្ចប់ថវិកាជាតិ ហើយមិនត្រូវការហិរញ្ញប្បទានពីកម្ចី និងជំនួយឥតសំណងរបស់ ADB ឡើយ។ បន្ទាប់ពីការព្រមព្រៀងលើផែនការ DRP និងថវិកា និងមុនការពិគ្រោះយោបល់ជាមួយអ្នករងផលប៉ះពាល់ ចាំបាច់ត្រូវរៀបចំផែនការផ្តល់សំណង និងការពិគ្រោះយោបល់ ក៏ដូចជាសេចក្តីព្រាងកិច្ចសន្យាសម្រាប់ការទូទាត់សំណងដល់អ្នករងផលប៉ះពាល់ទាំងអស់ ដូចបានកំណត់នៅក្នុង GDR ។ ការទូទាត់សំណង នឹងត្រូវធ្វើឡើងពេញលេញបន្ទាប់ពីបានចុះកិច្ចសន្យាព្រមព្រៀង ហើយលទ្ធផលនៃការបញ្ចប់ការទូទាត់ នឹងត្រូវបានបញ្ចូលទៅនៅក្នុងរបាយការណ៍ការអនុវត្តកាតព្វកិច្ច DRP ដែលនឹងត្រូវដាក់ជូន ADB ដើម្បីពិនិត្យ។

១០. អនុគម្រោង នឹងត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋាន GDAHP ដែលជាភ្នាក់ងារអនុវត្តគម្រោង (IA) តាមរយៈការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) ដែលនឹងគាំទ្រ GDAHP ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងគម្រោងទាំងមូល។ ទីប្រឹក្សាអនុវត្តគម្រោង (PIC) នឹងគាំទ្រអង្គភាពគ្រប់គ្រងគម្រោង (PMU) ដើម្បីធានាថានីតិវិធីត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយការអនុវត្តត្រូវបានគោរពតាមពេលវេលាដែលបានកំណត់។ ទោះយ៉ាងណាក៏ដោយ ចំពោះសកម្មភាពទាក់ទងនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) មិនមែនជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋាន GDAHP នោះទេ ប៉ុន្តែវាជាទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR) ដែលបានទទួលអាណត្តិអនុវត្តភារកិច្ចនេះ។ អគ្គនាយកដ្ឋាន GDAHP និងអង្គភាព PMU របស់ខ្លួន នឹងសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រុមការងារគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (IRC-WG) លើបញ្ហាទាំងអស់ដែលទាក់ទងនឹង ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ទី ២ (RD2) ។ នាយកដ្ឋាននេះត្រូវបានចាត់តាំងដោយអគ្គនាយកដ្ឋាន GDR នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដើម្បីឱ្យទទួលខុសត្រូវសម្រាប់គម្រោងនេះលើការអនុវត្ត DRPs ។

១១. ក្របខ័ណ្ឌ RF រួមបញ្ចូលទាំងភារកិច្ចបន្តជាមូលដ្ឋានចំនួនពីរ៖ (១). ការត្រួតពិនិត្យតាមដានផ្ទៃក្នុងប្រចាំត្រីមាស, និង (២). ការត្រួតពិនិត្យតាមដានសុវត្ថិភាពសង្គមពាក់កណ្ដាលប្រចាំឆ្នាំ ដែលភារកិច្ចទាំងពីរនេះ ត្រូវអនុវត្តដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងទិន្នន័យ (DIMDM) នៃអគ្គនាយកដ្ឋាន GDR ។ ការត្រួតពិនិត្យតាមដាន និងការរាយការណ៍ គឺជាការចាំបាច់ក្នុងផ្នែក៖ (១). ការរៀបចំស្ថាប័ន, (២). ការទូទាត់សំណងសម្រាប់សិទ្ធិទទួលបាន, (៣). ការដោះស្រាយបណ្ដឹងតវ៉ា, (៤). ការពិគ្រោះយោបល់ជាសាធារណៈ, (៥). ការចំណាយថវិកា, (៦). កម្មវិធីទ្រទ្រង់ជីវភាព (ប្រសិនបើមានបែងចែង ឬការរៀបចំទីតាំង និងការរុះរើកន្លែងលក់ដូរជាបណ្ដោះអាសន្នរបស់អាជីវករក្នុងផ្សារ), (៧). វឌ្ឍនភាពជារួម ធៀបនឹងកាលវិភាគនៃការអនុវត្តដែលបានព្រមព្រៀង, និង (៨). បញ្ហាសំខាន់ៗ។

# I. សេចក្តីផ្តើម

១. ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF) នេះ ត្រូវបានរៀបចំឡើងសម្រាប់ (គម្រោង) សុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែច្រវាក់តម្លៃសត្វ (CLHVCIP)។ ក្របខ័ណ្ឌនេះទៀតសោតបង្ហាញពីគោលការណ៍ គោលនយោបាយ នីតិវិធី និងការរៀបចំស្ថាប័ន ដើម្បីកាត់បន្ថយហានិភ័យនានា និង ផ្តល់ឱកាសចិញ្ចឹមជីវិត និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។ ក្របខ័ណ្ឌនេះ ត្រូវបានចងក្រងឡើងដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីថ្លែងគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB-SPS) ឆ្នាំ ២០០៩។ ទោះជាយ៉ាងណាក៏ដោយ តាំងពីដើមដំបូងមក រាជរដ្ឋាភិបាលកម្ពុជាមានចេតនាដើម្បីធ្វើយ៉ាងណាឱ្យអនុគម្រោងអភិវឌ្ឍន៍ទាំងឡាយអាចបញ្ចៀសឱ្យខាងតែបាននូវការពាក់ព័ន្ធនឹងការបែងចែងដីធ្លី ឬការតាំងលំនៅជាថ្មីណាមួយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលនៅតែទទួលស្គាល់ថាក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ គឺជាការចាំបាច់ដើម្បីទប់ស្កាត់ផលប៉ះពាល់ទាំងឡាយណាដែលមិនបានមើលឃើញទុកជាមុន។ ដូច្នេះ ក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ តម្រូវឱ្យកំណត់ពីផលប៉ះពាល់ដែលអាចកើតមានទាក់ទងនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) ជាពិសេសលើបញ្ហាចម្បងក្នុងការរកប្រាក់ចំណូលរបស់អ្នកទទួលរងផលប៉ះពាល់ ដោយសារការរៀបចំកែលម្អ និងពង្រីកបន្ថែម ដូចជាកន្លែងសត្តឃាត និងផ្សារលក់ដូរ ដែលអាចនឹងរងផលប៉ះពាល់មួយចំនួនជាបណ្តោះអាសន្ន។

## ក. ការការពិពណ៌នាគម្រោង

២. គម្រោងនេះ មានលទ្ធផលសំខាន់ៗចំនួនបី ដែលត្រូវបានពន្យល់យ៉ាងលម្អិតនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ប៉ុន្តែយើងអាចធ្វើការសង្ខេបយ៉ាងខ្លីដោយមានគ្រប់គ្រាន់ ដូចខាងក្រោម៖

(១). **លទ្ធផលទី ១៖** ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វ និងខ្សែ ច្រវាក់តម្លៃសត្វ ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ។

(២). **លទ្ធផលទី ២៖** សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលបសុសត្វ ត្រូវបានពង្រឹង។

(៣). **លទ្ធផលទី ៣៖** ការរៀបចំជំរុញការអនុវត្តគោលនយោបាយសម្រាប់ការផ្គត់ផ្គង់ សុខភាព សុវត្ថិភាព និងពាណិជ្ជកម្មសត្វ និងផលិតផលសត្វ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង តាមរយៈការគាំទ្រគោលនយោបាយឆ្លើយតបនឹងយេនឌ័រ។

៣. នៅក្រោមលទ្ធផលទី ១ មានអនុគម្រោងដែលពាក់ព័ន្ធនឹងបញ្ហាការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដែលបង្កើតជាបានលក្ខខណ្ឌតម្រូវនៃសេចក្តីថ្លែងគោលនយោបាយ (ADB-SPS ឆ្នាំ២០០៩) ហើយសម្រាប់

ឯកសារយោងណាមួយនឹងត្រូវធ្វើឡើងទូទាំងក្របខ័ណ្ឌ RF នេះ។ សម្រាប់អនុគម្រោងដែលធ្លាប់ជាកម្មវត្ថុនៃការអនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយ រហូតមកដល់បច្ចុប្បន្នមានដូចជា មណ្ឌលចត្តាឡីស័ក និងតំបន់គ្រប់គ្រងជំងឺ មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ មជ្ឈមណ្ឌលជាតិបង្កាត់ពូជសត្វគោ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ និង ផ្សារលក់មាន់ទារស់ដូនកែវ។ ក្រៅពីមជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វដែលស្ថិតនៅក្នុងខេត្តកណ្តាល និងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វដែលមាននៅក្នុងរាជធានីភ្នំពេញ អនុគម្រោងទាំងអស់ផ្សេងទៀត គឺស្ថិតនៅក្នុងខេត្តគម្រោងជាក់ស្តែងដូចជា ឧត្តរមានជ័យ សៀមរាប កំពង់ចាម ព្រៃវែង និងតាកែវ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់នូវបរិបទមួយចំនួនអំពីមូលហេតុនៃការបង្កើតគម្រោងនេះឡើង គឺពិតជាមានសារៈសំខាន់ណាស់។ អនុវិស័យចិញ្ចឹមសត្វនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) ដែលរួមមានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ព្រមទាំងខេត្តយូណាន និងក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន គឺជាតំបន់ផលិតស្បៀងអាហារដ៏សំខាន់មួយរបស់ពិភពលោក ដែលវិស័យកសិកម្មកំពុងដើរតួយ៉ាងសំខាន់ ជាពិសេសក្នុងតួនាទីអភិវឌ្ឍន៍សេដ្ឋកិច្ច។ មមហាអនុតំបន់ទន្លេមេគង្គ មានសក្តានុពលខ្ពស់សម្រាប់កំណើនសេដ្ឋកិច្ច និងការរួមចំណែកដល់ការពង្រឹងសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ផលិតកម្មបសុសត្វបាននិងកំពុងកើនឡើងច្រើនជាងទ្វេដងនៅចន្លោះឆ្នាំ២០០៦ និង ២០១៦ ហើយត្រូវបានគេរំពឹងថានឹងបន្តកើនឡើងទៀតក្នុងរយៈពេលមធ្យម។ ចាប់តាំងពីឆ្នាំ១៩៩៥ មក បណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គទទួលបានអត្រាកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំលើសពី ៦% ជារៀងរាល់ឆ្នាំ។ ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ បានបង្កជាផលប៉ះពាល់ដល់ចំណូលចិត្តនៃរបបអាហារ ដែលនាំទៅរកកំណើនយ៉ាងឆាប់រហ័សនៃតម្រូវការសម្រាប់សត្វចិញ្ចឹម និងផលិតផលសត្វចិញ្ចឹម។ តម្រូវការកើនឡើងបែបនេះ សបញ្ជាក់ពីឱកាសសម្រាប់កសិករខ្នាតតូច និងអាជីវកម្មកសិឧស្សាហកម្មខ្នាតតូច និងមធ្យម រួមទាំងកាលានុវត្តភាពសម្រាប់ស្រ្តីផងដែរ។

៤. ស្របពេលដែលផលិតកម្មស្រូវនៅតែជាចំណែកដ៏សំខាន់សម្រាប់វិស័យកសិកម្ម ប្រទេសមហាអនុតំបន់ទន្លេមេគង្គនៅតែជាអ្នកផលិតដ៏មានសក្តានុពលនៃផលិតផលសត្វ រួមមានសាច់គោ សាច់បក្សី ស៊ុត និងសាច់ជ្រូក ជាមួយនឹងវត្តមានកសិករខ្នាតតូចប្រមាណជាង ២៣ លាននាក់។ កសិដ្ឋានខ្នាតតូចអាចចិញ្ចឹមសមាមាត្រដ៏ច្រើននៃចំនួនប្រជាជនដែលផ្តល់អាហារសម្រាប់សមាមាត្រដ៏ច្រើននៃចំនួនប្រជាជន។ សត្វចិញ្ចឹម គឺជាទ្រព្យសកម្មដ៏មានតម្លៃ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងសម្រាប់ជាអាហារក្នុងគ្រួសារ រួមទាំងការផ្តល់ជី ប្រូតេអ៊ីន ការសន្សំសំចៃសម្រាប់ការចំណាយម្តងម្កាល ប្រាក់ចំណូលមិនទៀងទាត់ពីការលក់ដូរ ហើយសព្វថ្ងៃនេះបានក្លាយជាថាមពលដ៏កម្រដែលបង្កើតឡើងដោយសត្វ។

៥. ការចិញ្ចឹមសត្វតាមកសិដ្ឋាន ជាធម្មតាគឺជាផ្នែកមួយនៃប្រព័ន្ធកសិដ្ឋានចម្រុះដែលមានរួមផ្សំដោយសកម្មភាពកសិកម្មនានា។ ស្ទើរតែ ៩០% នៃសត្វចិញ្ចឹមទាំងអស់ត្រូវបានកាន់កាប់ដោយកសិករខ្នាតតូច។ កសិករខ្នាតតូចអាចមានគោ ជ្រូក និង/ឬមាន់យ៉ាងហោច ១០-៣០ ក្បាល។ សត្វទំពារអៀងធំៗ ជាទូទៅត្រូវបានគេចាត់ទុកថាជាប្រភេទសត្វចិញ្ចឹមក្នុងស្រុកដ៏សំខាន់បំផុតសម្រាប់ប្រជាកសិករនៅតាមទីជនបទ។ ដោយឡែក នៅក្នុងប្រទេសកម្ពុជា ការបរិភោគសត្វចិញ្ចឹមមិនត្រូវបានដាក់កម្រិតចំពោះសាច់ និងទឹកដោះគោទេ ដោយសារសត្វទាំងនេះក៏ជាប្រភពនៃទ្រព្យសម្បត្តិ ការងារ និងការដឹកជញ្ជូនដល់កសិករខ្នាតតូចនៅក្នុងសហគមន៍ជនបទផងដែរ។

ប្រទេសនេះនៅតែមានសកម្មភាពវិស័យកសិកម្មដ៏ច្រើនលើសលប់ ហើយសត្វចិញ្ចឹមគឺជាទ្រព្យសកម្មដ៏មានតម្លៃសម្រាប់គ្រួសារជនបទដែលមានចំនួនប្រមាណ ៧០%។

៦. អនុវិស័យបសុសត្វនៅកម្ពុជា មានកំណើនសក្តានុពលយ៉ាងខ្លាំង ដោយសារតែកំណើននៃការបរិភោគសាច់សត្វក្នុងប្រទេស ដែលបណ្តាលមកពីការធ្វើនគរូបនីយកម្ម និងកំណើនប្រជាជនយ៉ាងឆាប់រហ័ស ប៉ុន្តែការរីកចម្រើននេះអាស្រ័យលើថាតើប្រទេសកម្ពុជាអាចលើកកម្ពស់ប្រសិទ្ធភាព និងការប្រកួតប្រជែងនៃឧស្សាហកម្មបសុសត្វរបស់ខ្លួនដោយរបៀបណា។

៧. ឧបសគ្គចម្បងនៃឧស្សាហកម្មបសុសត្វនៅកម្ពុជា គឺការចំណាយខ្ពស់នៃការផលិតសត្វក្នុងស្រុក រួមទាំងកង្វះលទ្ធភាពទទួលបានស្តុកបង្កាត់ពូជប្រកបដោយគុណភាព និងបញ្ហាជំងឺឆ្លង ប៉ុន្តែក៏ទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយ និងការប្រែប្រួលទីផ្សារខ្ពស់។

៨. នៅក្នុងសាវតា និងបរិបទនេះ នាយកដ្ឋានសុខភាពសត្វ និងបសុព្យាបាលក្នុងឆ្នាំ២០១៦ ត្រូវបានបង្កើនមួយកម្រិតទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) និងបានបង្កើត "ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍបសុសត្វ ២០១៦-២០២៥" [3] ដែលបានកំណត់បញ្ហាយុទ្ធសាស្ត្រ និងផែនការដោះស្រាយអនុវិស័យបសុសត្វកម្ពុជាសម្រាប់រយៈពេល ១០ ឆ្នាំ រួមទាំងការដោះស្រាយការដាក់កម្រិតលើផលិតកម្មសត្វ សុខភាពសត្វ កំណើនទីផ្សារ សុវត្ថិភាពចំណីអាហារ និងការលើកកម្ពស់សុខភាពសាធារណៈ ការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង ការពង្រឹងវិស័យឯកជន ការគាំទ្រដល់ក្រុមកសិករ ឬសមាគមកសិករ ការពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងបញ្ហាអន្តរវិស័យសំខាន់ៗ ដូចជាយេនឌ័រ និងការប្រែប្រួលអាកាសធាតុជាដើម។

៩. ជាធម្មតា សត្វចិញ្ចឹមត្រូវគេចិញ្ចឹមដោយព្រលែងចោលឱ្យដើរដោយសេរី ដោយគ្មានក្តីបារម្ភពីជីវសុវត្ថិភាពអ្វីឡើយ។ ខណៈពេលដែលស្ថានភាពចិញ្ចឹមសត្វបែបនេះ គឺសមរម្យសម្រាប់ការសន្សំសំចៃនៅតាមជនបទ និងកត្តាភូមិសាស្ត្រដែលនៅមានកម្រិតផងនោះ វាបែរជាបង្កបញ្ហាដល់ការចិញ្ចឹមសត្វដែលជាកត្តាជំរុញកំណើនសេដ្ឋកិច្ចទៅវិញ៖ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារខ្នាតតូច មិនងាយនឹងទទួលបានប្រាក់កម្ចីសម្រាប់ពង្រីក ឬអភិវឌ្ឍវិស័យពាណិជ្ជកម្មក្នុងតំបន់ និងឧស្សាហកម្មនាំចេញបានឡើយ។ ម្យ៉ាងទៀត កង្វះជីវសុវត្ថិភាព ក៏បានធ្វើឱ្យប៉ះពាល់ដល់សុខភាពសត្វ និងបង្កឱ្យកើតមាននូវជំងឺរាតត្បាតកាន់តែច្រើនឡើងផងដែរ។

១០. ក្នុងរយៈពេលពីរទសវត្សកន្លងមកនេះ ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរដ៏សំខាន់មួយ ដោយឈានដល់ស្ថានភាពចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៥ និងប្រាថ្នាចង់ទទួលបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំបំណាច់ឆ្នាំ២០៣០ខាងមុខ។ សេដ្ឋកិច្ចប្រទេសកម្ពុជា មាននិរន្តរភាពជាមធ្យម តាមរយៈការជំរុញដោយការនាំចេញសម្លៀកបំពាក់ និងវិស័យទេសចរណ៍។ អត្រាកំណើន ៨% នៅចន្លោះឆ្នាំ១៩៩៨ និង

---

[3] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៦. *អគ្គនាយដ្ឋាន GDAHP ផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល ១០ ឆ្នាំ ២០១៦-២០២៥.* ភ្នំពេញ ប្រទេសកម្ពុជា។

២០១៨ បានជំរុញឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតនៅលើពិភពលោក។ ខណៈដែលប្រទេសជាតិស្ថិតក្នុងស្ថានភាពនយោបាយធូរស្រាលបន្តិច កំណើនសេដ្ឋកិច្ចក្នុងប្រទេសនៅតែរឹងមាំដដែល ហើយត្រូវបានគេប៉ាន់ប្រមាណថាបានឈានដល់ ៧.១% ក្នុងឆ្នាំ២០១៩។ ជាអកុសលជំងឺរាតត្បាតកូវីដ-១៩ កំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ហើយនៅឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចក្នុងប្រទេសត្រូវបានព្យាករណ៍ថានឹងត្រូវធ្លាក់ចុះជាអវិជ្ជមាន -២% [4]។

១១. អនុវិស័យកសិកម្ម ដែលរួមមានការដាំដំណាំ ការចិញ្ចឹមសត្វ ការនេសាទ និងអនុផលព្រៃឈើ/សត្វព្រៃ បានចូលរួមចំណែកប្រមាណ ២១% (តម្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩ ហើយប្រើប្រាស់កម្លាំងពលកម្មមួយផ្នែកធំ។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្ននេះមានការថយចុះដោយសារតែកត្តាយន្តកម្ម និងវិស័យឧស្សាហកម្មដែលកំពុងរីកចម្រើនខ្លាំង ដូចជាឧស្សាហកម្មកាត់ដេរ ដែលទាក់ទាញកម្លាំងពលកម្មពីប្រជាជននៅតាមជនបទកាន់តែច្រើនឡើង ជាពិសេសស្ត្រី។ ស្រូវ គឺជាដំណាំសំខាន់របស់ប្រទេសកម្ពុជា ជាអាហារចម្បង និងជាទំនិញនាំចេញដ៏មានសក្តានុពលបំផុតរបស់កម្ពុជា។ បសុសត្វ រួមទាំងបសុបក្សីជាប់ចំណាត់ថ្នាក់លេខ ៣ ជាមួយនឹងការរួមចំណែក ១១.១១% ដល់ផលិតផលក្នុងស្រុកសរុបនៃវិស័យកសិកម្ម នៅពីក្រោយវិស័យជលផល (២៤.៣%)។

១២. ទិដ្ឋភាពសំខាន់មួយ គឺប្រព័ន្ធផលិតកម្មចម្បងរបស់ប្រទេសកម្ពុជា នៅតែពឹងផ្អែកយ៉ាងទូលំទូលាយលើការធ្វើកសិកម្មជាលក្ខណៈគ្រួសារ រួមទាំងផលិតកម្មសត្វគោ ក៏ដូចជាសត្វក្របី និងសត្វទំពារអៀងតូចៗ (ភាគច្រើនសត្វពពែ) និងផលិតកម្មបសុបក្សី (៦៨.៧%)។ មានតែផលិតកម្មជ្រូកប៉ុណ្ណោះ ដែលបានផ្លាស់ប្តូរពីការចិញ្ចឹមជាលក្ខណៈគ្រួសារ មកចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ដោយសារតែការកើនឡើងនៃការប្រើប្រាស់វិធីសាស្ត្របង្កាត់ពូជសិប្បនិម្មិត។

១៣. លទ្ធផលវាយតម្លៃចុងក្រោយស្តីពីការលើកកម្ពស់កំណើនវិស័យកសិកម្មប្រកបដោយបរិយាប័ន្ន និងដោយចីរភាពរបស់សហភាពអឺរ៉ុប បានបង្ហាញថា៖ គម្រោងជលផល និងបសុសត្វ ឃើញមានជាហូរហែរនៅក្នុងគ្រប់ខេត្តទាំងអស់ដែលបានចុះធ្វើទស្សនកិច្ច ពោលគឺចំនួន ៦០-៨៥% នៃប្រព័ន្ធផលិតកម្មជ្រូក និងមាន់ដែលចិញ្ចឹមដោយព្រលែងចោល (មិនសូវសំខាន់សម្រាប់គោក្របី) ដែលពេលបច្ចុប្បន្ននេះត្រូវបានជំនួសដោយការចិញ្ចឹមដែលពឹងផ្អែកជាខ្លាំងទៅលើប្រព័ន្ធខ្សែច្រវាក់តម្លៃប្រកបដោយជោគជ័យ និងដោយចីរភាព ដែលបានបង្កើតឡើងសម្រាប់ផលិតកម្មជ្រូក និងផលិតកម្មបសុបក្សី។ ការបង្កាត់ពូជសិប្បនិម្មិតសម្រាប់សត្វគោ កំពុងដំណើរការនៅតាមបណ្តាខេត្តចំនួន ១៤ និងនៅតាមបណ្តាខេត្តចំនួន ១០ សម្រាប់សត្វជ្រូក។ ដំណើរការបង្កាត់ពូជនេះ បានធ្វើឲ្យគុណភាពពូជមានភាពប្រសើរឡើង និងបង្កើនប្រាក់ចំណូលសម្រាប់ប្រជាកសិករផងដែរ។ សហគ្រាសចិញ្ចឹមមាន់មាននិរន្តរភាពជាមុខរបរសមរម្យសម្រាប់ស្ត្រី ហើយអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារបាន។ ក្រុមទីផ្សារបសុសត្វដែលទទួលបានជោគជ័យលើសហគ្រាសចិញ្ចឹមមាន់ និងជ្រូក បានផ្តល់ជាលទ្ធផលឱ្យកសិករខ្នាតតូចចំនួន ១១,០០០ គ្រួសារបង្កើនសមត្ថភាពក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ស្របតាមតម្រូវការទីផ្សារ។ ដើម្បី

[4] ធនាគារពិភពលោក ឆ្នាំ២០២០។ *ធនាគារពិភពលោកប្រចាំនៅកម្ពុជា (The World Bank in Cambodia)* https://www.worldbank.org/en/country/cambodia/overview

គាំទ្រដល់ភាពជោគជ័យ និងជានានិរន្តរភាពផលិតកម្មសត្វ អគ្គនាយកដ្ឋាន GDAHP បានសម្រេចបញ្ចូលកម្មវិធីបង្កាត់ពូជសិប្បនិម្មិត (AI) ក្នុងផែនការថវិកា និងផែនការបណ្តុះបណ្តាលឆ្នាំ២០២០ ដើម្បីសម្រេចឱ្យបាន ៣០% នៃការបង្កាត់ពូជ AI នៅឆ្នាំ២០២៣ នៅក្នុងខេត្តក្រុងទាំង ២៥ ដែលជាកម្មវត្ថុនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។

១៤. ការពឹងផ្អែកលើរបរកសិកម្មជាលក្ខណៈគ្រួសារ ដែលពឹងផ្អែកលើការប្រើប្រាស់សត្វដែលមានទំហំតូច និងមិនទាន់ផលិតបានច្រើន ដែលចំណាយពេលរហូតដល់ ៥ ឆ្នាំទម្រាំតែគ្រប់ទម្ងន់ដែលងាចសម្លាប់យកសាច់បាន ហើយសត្វទាំងនេះរួមចំណែកដល់អត្រាខ្ពស់នៃការបំភាយឧស្ម័នផ្ទះកញ្ចក់។ នេះអាចកាត់បន្ថយបានមួយផ្នែកដោយបច្ចេកទេសផ្តល់ចំណីឱ្យកាន់តែប្រសើរ ប៉ុន្តែការកែលម្អហ្សែន និងការកាត់បន្ថយចំនួនគោក្របី គឺជាផ្នែកសំខាន់ដែលអនុញ្ញាតឱ្យផលិតកម្មសាច់គោស្ថិតក្នុងបរិមាណដូចគ្នាក្នុងរយៈពេលខ្លីជាងនេះ។

១៥. ទោះបីជាមានការនាំចេញសត្វគោខ្លះក៏ដោយ កម្ពុជានៅតែជាប្រទេសនាំចូលគោរស់ ជ្រូក និងបសុបក្សីដទៃទៀតផងដែរ។ សាច់គោ សាច់ជ្រូក និងសាច់មាន់ដែលនាំចូល គឺត្រូវការជាចាំបាច់ ដើម្បីភ្ជាប់គម្លាតរវាងបរិមាណនៃការផលិត និងការប្រើប្រាស់សាច់សត្វនៅក្នុងប្រទេស។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប៉ាន់ប្រមាណថា ក្នុងអំឡុងឆ្នាំ២០១៩ តម្រូវការប្រើប្រាស់របស់មនុស្សយ៉ាងហោចណាស់ ២៩០,៩២៤ នាក់ ឬប្រហែល ១៨% នៃចំនួនប្រជាជនសរុប ត្រូវគ្របដណ្តប់ដោយសាច់នាំចូល (ប្រហែល ៥០,០០០ តោនក្នុងមួយឆ្នាំ)។

១៦. ប្រទេសកម្ពុជាងាយរងគ្រោះដោយសារជំងឺសត្វឆ្លងកាត់ព្រំដែន ដូចជា ជំងឺអុតក្តាម (FMD), ជំងឺដុំពកស្បែក (LSD) ឬជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ជំងឺទាំងនេះច្រើនតែបង្កើតជារបាំងមិនមែនពន្ធដ៏សំខាន់ក្នុងការធ្វើពាណិជ្ជកម្មសត្វរស់ ហើយក្នុងករណីខ្លះ ផលិតផលសត្វត្រូវអនុគ្គឱ្យស្របតាមកិច្ចព្រមព្រៀង SPS របស់អង្គការពាណិជ្ជកម្មពិភពលោក។ ប្រទេសកម្ពុជា ក៏ងាយរងគ្រោះផងដែរដោយសារជំងឺឆ្លងដែលទើបនឹងកើតថ្មីៗ ដែលជាញឹកញាប់ដូចជាកូវីដ-១៩ និងជំងឺគ្រុនផ្តាសាយបក្សី ជាដើម។ ដូច្នេះ ត្រូវចាំបាច់ត្រូវបង្កើតតំបន់គ្រប់គ្រងជំងឺសម្រាប់ការផ្ទុះរាលនៃជំងឺផ្សេងៗ។ វិសោធនកម្មប្រកាសលេខ ១៦ ស្តីពីអនាម័យសត្វ និងផលិតកម្មសត្វកំពុងដំណើរការរៀបចំធ្វើ។ ភាគីពាក់ព័ន្ធទាំងអស់បានយល់ពីសារៈសំខាន់នៃការគ្រប់គ្រងការធ្វើចរាចរសត្វ និងការពិនិត្យតាមដាន តួនាទីរបស់ស្ថានីយ៍ចត្តាឡីស័ក និងយល់ថាប្រព័ន្ធកំណត់អត្តសញ្ញាណសត្វ គឺចាំបាច់សម្រាប់ការគ្រប់គ្រងអនាម័យ និងជំងឺរបស់សត្វ។ មានការណែនាំថា ការត្រួតពិនិត្យ និងវិសោធនកម្មលើប្រកាសទាំងអស់ គួរតែត្រូវបានធ្វើយ៉ាងហោចណាស់ម្តងរៀងរាល់ ៥ ឆ្នាំម្តង។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្ននៅមានកង្វះខាតសមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រងតំបន់គ្មានជំងឺ។ អគ្គនាយកដ្ឋាន GDAHP មានយុទ្ធសាស្ត្របឋមសម្រាប់បង្កើតស្ថានីយ៍ចត្តាឡីស័កក្នុងខេត្តនីមួយៗដែលមានព្រំប្រទល់ខាងក្រៅ ដើម្បីរក្សាសត្វឱ្យស្ថិតក្រោមការសង្កេត មុនពេលអនុញ្ញាតឱ្យធ្វើចរាចរ ប៉ុន្តែបច្ចុប្បន្នការងារនេះស្ថិតក្នុងដំណាក់កាលបឋមនៅឡើយ។

១៧. គ្រោះថ្នាក់ពីចំណីអាហារកើតមានច្រើនដោយសារតែខ្វះអនាម័យក្នុងអំឡុងពេលសត្តឃាត និងការចាត់ចែងអាហារ ប៉ុន្តែក៏មកពីការគំរាមកំហែងដ៏អាក្រក់ដែលបង្កឡើងដោយសំណល់នៃផលិតផលឱសថពេទ្យសត្វផងដែរ ជាពិសេសដោយសារតែការប្រើប្រាស់ថ្នាំអង់ទីប៊ីយោទិកដោយគ្មានការទទួលខុសត្រូវ និងគ្មានការគ្រប់គ្រងដែលជាហេតុជំរុញឱ្យមានការវិវត្តនៃមេរោគដែលបង្ហាញឱ្យឃើញពីភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ (AMR) ។ កត្តានេះនាំឱ្យមានការកើនឡើងនៃជំងឺឆ្លងដែលប៉ះពាល់ដល់សុខភាពមនុស្ស ដែលត្រូវព្យាបាលដោយឱសថដែលមានតម្លៃកាន់តែថ្លៃ និងត្រូវការឱសថការីឯកទេសកាន់តែច្រើន ជាមួយនឹងហានិភ័យនៃការកើនឡើងចំនួនអ្នកស្លាប់ និងការកើនឡើងនូវបន្ទុកចំណាយរបស់រដ្ឋទៅលើថ្លៃថែទាំសុខភាពប្រជាពលរដ្ឋ។ ផលិតកម្មសត្វចិញ្ចឹម រួមជាមួយនឹងការប្រើប្រាស់ថ្នាំខុសចំពោះសុខភាពមនុស្ស ត្រូវបានចាត់ទុកថាជាមូលហេតុចម្បងនៃការកើនឡើងនៃភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ (AMR) ហើយវិស័យនេះ គឺជាកត្តាសំខាន់ក្នុងការបំបែក AMR នៅក្នុងបរិស្ថាន។ ការប្រើប្រាស់ថ្នាំខុស ជាពិសេសថ្នាំសម្លាប់មេរោគដោយអ្នកចិញ្ចឹមសត្វ គឺកំពុងរីករាលដាលពាសពេញប្រទេស។ ឧបសគ្គផ្សេងទៀតរួមមានការប្រើប្រាស់បសុឱសថ និងថ្នាំជីវសាស្ត្រយ៉ាងទូលំទូលាយដោយភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) និងដោយអ្នកចិញ្ចឹមសត្វផ្ទាល់ និងការនាំចូលដោយខុសច្បាប់នូវបសុឱសថ និងថ្នាំជីវសាស្ត្រ។ ការប្រើប្រាស់បសុឱសថ គួរតែត្រូវបានដាក់កម្រិត និងអនុញ្ញាតបានសម្រាប់តែអ្នកឯកទេសខាងឱសថសាស្ត្រ ឬបន្ទាប់ពីការធ្វើតេស្តសាកល្បងភាពប្រែប្រួលតែប៉ុណ្ណោះ ហើយបើកការត្រួតពិនិត្យតាមឱសថស្ថាន និងកន្លែងពេទ្យសត្វ ឬកន្លែងលក់បសុឱសថ ក៏ដូចជាការត្រួតពិនិត្យលើការអនុវត្តការចែកចាយបសុឱសថ។

១៨. រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ថ្មីស្តីពីសុខភាពសត្វ និងបសុព្យាបាលកាលពីឆ្នាំ២០១៦ ហើយកំពុងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងអនុក្រឹត្យដែលមានស្រាប់។ ផែនការសកម្មភាពពហុវិស័យរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ (AMR) ត្រូវបានដាក់ឱ្យដំណើរការដោយក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ ក្រុមការងារបច្ចេកទេសរួមគ្នាមួយចំនួន (TWGs) ត្រូវបានបង្កើតឡើងដូចជា (១). ក្រុមការងារបច្ចេកទេស AMR , (២). ក្រុមការងារបច្ចេកទេសជំងឺឆ្លងពីសត្វទៅមនុស្ស, (៣). ក្រុមការងារបច្ចេកទេសសុវត្ថិភាពម្ហូបអាហារ, និង (៤). ក្រុមការងារស៊ើបអង្កេត និងឆ្លើយតបចំពោះជំងឺរាតត្បាតដោយសារចំណីអាហារអន្តរក្រសួង ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ "សុខភាពតែមួយ" ឬ "សុខភាពទាំងអស់" ដែលត្រូវបានផ្សព្វផ្សាយ និងគាំទ្រដោយអង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ អង្គការសុខភាពសត្វពិភពលោក និងអង្គការសុខភាពពិភពលោក។

១៩. ក្រៅពីការគំរាមកំហែងនៃជំងឺសត្វឆ្លងកាត់ព្រំដែន ភាពទន់ខ្សោយនៃសេវាសុខភាពសត្វ គឺជាឧបសគ្គបន្ថែមទៀតចំពោះការអភិវឌ្ឍន៍អនុវិស័យបសុសត្វនៅកម្ពុជា។ សេវាសុខភាពសត្វ ពឹងផ្អែកមួយកម្រិតធំលើសមត្ថភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) ដែលទទួលបានការបណ្តុះបណ្តាលនៅមានកម្រិត និងមិនទាន់បានរៀបចំឱ្យមានប្រសិទ្ធភាពនៅឡើយ។

## II. សន្និធានភាពនៃក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

### ក. លទ្ធផលទី ១៖ អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ

### ១. មណ្ឌលត្រួតពិនិត្យសត្វ និងចត្តាឡីស័ក និងតំបន់គ្រប់គ្រងជំងឺទី ១

២០. ទីតាំងសក្តានុពលសម្រាប់សាងសង់មណ្ឌលត្រួតពិនិត្យសត្វនៅជិតព្រំដែននៃខេត្តឧត្តរមានជ័យ និង មណ្ឌលចត្តាឡីស័កសត្វគោនៅខេត្តព្រៃវែង ត្រូវបានកំណត់រួចហើយ។ មណ្ឌលត្រួតពិនិត្យសត្វ គឺជាស្ថានីយ៍ត្រួតពិនិត្យដែលត្រូវយកសត្វមកទុកជាបណ្តោះអាសន្ន ដើម្បីធ្វើការត្រួតពិនិត្យសុខភាព (ជ្រូក និងគោ) ដែលនាំចូលពីប្រទេសថៃ ដែលនឹងត្រូវដឹកជញ្ជូនទៅតាមសត្តឃាតដ្ឋានដោយផ្ទាល់។ ដោយឡែក មណ្ឌលចត្តាឡីស័កក្នុងខេត្តព្រៃវែង គឺសម្រាប់ប្រមូលផ្តុំសត្វដែលនឹងត្រូវនាំចេញទៅប្រទេសវៀតណាម ដោយតម្រូវឱ្យមានការរក្សាទុករយៈពេល ២១ ថ្ងៃ។ សំណង់អគារ រួមទាំងមន្ទីរពិសោធន៍រោគវិនិច្ឆ័យ កន្លែងស្នាក់នៅរបស់បុគ្គលិក (ជាលក្ខណៈអន្តេវាសិកដ្ឋាន) និងកន្លែងសុវត្ថិភាព ជណ្តើរលើកដាក់សត្វ កន្លែងត្រួតពិនិត្យសត្វ និងក្រោលគោ ត្រូវបានរចនាឡើង និងមានការគ្រប់គ្រងទឹកកង្វក់តាមរយៈប្រព័ន្ធប្រព្រឹត្តកម្មទឹកង្វក់ដោយវិមជ្ឈការ (DEWATS)។

២១. សម្រាប់ការផ្តួចផ្តើមបង្កើតតំបន់គ្រប់គ្រងជំងឺ (DCZ) គឺមានលក្ខណៈខុសពីការបង្កើតមណ្ឌលត្រួតពិនិត្យសត្វ នៅក្នុងខេត្តឧត្តរមានជ័យ ដោយសារតែមណ្ឌលត្រួតពិនិត្យសត្វ គ្រាន់តែជាស្ថានីយ៍ត្រួតពិនិត្យបណ្តោះអាសន្ន ទៅលើសត្វជ្រូក និងគោដែលនាំចូល និងត្រូវដឹកជញ្ជូនទៅកាន់ទីសត្តឃាតនានាដោយផ្ទាល់។ ចំណែកមណ្ឌលចត្តាឡីស័កនៅខេត្តព្រៃវែង គឺសម្រាប់ប្រមូលផ្តុំសត្វគោដែលត្រូវនាំចេញទៅប្រទេសវៀតណាម ហើយក៏មានការផ្តួចផ្តើមឱ្យបង្កើតជា DCZ នៅក្នុងខេត្តនេះដែរ ក្នុងគោលបំណងការពារស្ថានភាពសុខភាពសត្វ និងបន្ថែមគុណតម្លៃដល់ការធ្វើពាណិជ្ជកម្មសត្វទំពារអៀងធំៗទៅកាន់ប្រទេសវៀតណាម។ តំបន់គ្រប់គ្រងជំងឺសត្វខេត្តព្រៃវែង គួរតែរួមបញ្ចូលស្រុកនៅជុំវិញដែលលាតសន្ធឹងរហូតដល់តំបន់ព្រំដែន ជាមួយនឹងការពង្រីកជាលំដាប់ទៅកាន់តំបន់ផ្សេងទៀត និងការបង្កើនការកាច់វ៉ាក់សាំងជំងឺអុតក្តាម និងជំងឺដុំពកស្បែក និងការអនុលោមតាមការគ្រប់គ្រងការធ្វើចរាចរសត្វ តាមរយៈការបង្កើតប៉ុស្តិ៍ត្រួតពិនិត្យ។ ភាពជោគជ័យនៃគំនិតផ្តួចផ្តើមក្នុងការបង្កើតតំបន់គ្រប់គ្រងជំងឺសត្វខេត្តព្រៃវែងដែលបានស្នើឡើង គួរតែផ្តល់លទ្ធភាពឱ្យខេត្តទាំងមូលក្លាយជាតំបន់គ្រប់គ្រងជំងឺដែលដំណើរការពេញមួយរយៈកាលនៃការអនុវត្តគម្រោង ជាមួយនឹងការពង្រីកជាបន្តបន្ទាប់ទៅកាន់ខេត្តតាកែវដែលនៅជាប់គ្នានោះ។ អនុគម្រោងនេះជានាថាពិធីសាមណ្ឌលចត្តាឡីស័កសត្វ ត្រូវបាន ត្រួតពិនិត្យតាមដានសុខភាពសត្វទាំងការនាំចូល និងនាំចេញជាពិសេសការគ្រប់គគ្រងជំងឺអុតក្តាម ជំងឺដុំពកស្បែក និងជំងឺប៉េស្តជ្រូកអាហ្វ្រិក។

### ២. មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ (NVVC)

២២. ដើម្បីដោះស្រាយការពឹងផ្អែកនាពេលបច្ចុប្បន្នរបស់កម្ពុជា លើការនាំចូលវ៉ាក់សាំងសត្វគ្រប់ប្រភេទ មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ (NVVC) ត្រូវបានស្នើឱ្យបង្កើតឡើងដែលដំបូងនឹងផលិតវ៉ាក់សាំងសត្វសំខាន់ៗ រួមមានវ៉ាក់សាំងប្រឆាំងជំងឺសារទឹកលើគោ និងក្របី វ៉ាក់សាំងប្រឆាំងជំងឺប៉េស្តជ្រូក និងជំងឺដង្កោ ជំងឺអុតមាន់ ជំងឺអុតក្តាម និងជំងឺប៉េស្តទា។ មជ្ឈមណ្ឌលនេះនឹង អនុញ្ញាតឱ្យមានការជំនួសតម្រូវការនាំចូលវ៉ាក់សាំងសត្វ

ដោយការផលិតដោយខ្លួនឯងនាពេលអនាគតដ៏ខ្លីខាងមុខនេះ។ ការផលិតវ៉ាក់សាំងប្រឆាំងជំងឺអុតក្តាម មិនមែនជាគោលដៅចម្បងទេ (ព្រោះថាមានវិទ្យាស្ថានផលិតវ៉ាក់សាំងចំនួន ១៤ រួចហើយនៅក្នុងតំបន់) ជាមួយនឹងការបន្តនាំចូលវ៉ាក់សាំងប្រភេទនេះ ដោយសារតែសារៈសំខាន់នៃវ៉ាក់សាំងដែលត្រូវគ្នាទៅនឹងមជ្ឈដ្ឋានដែលកំពុងវិវត្តជាបន្តបន្ទាប់នៃជាតិពុលបញ្ចេញដោយមេរោគ (serotype) នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ និងលើសពីនេះ។ ទីតាំង NVVC ដែលត្រូវបានស្នើឡើង ស្ថិតក្នុងភូមិតានូ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល លើដីកម្មសិទ្ធិរបស់ GDAHP/MAFF ទំហំ ១៥ ហិកតា។ ដោយសារទីតាំងនេះស្ថិតនៅក្នុងតំបន់វាលទំនាបនៃអាងទន្លេមេគង្គ ដែលមានការជន់លិចនៅរដូវវស្សា និងមានសកម្មភាពជួសជុលជាច្រើនកំពុងបន្តធ្វើ ដូចជាការចាក់ដីបំពេញ និងឈូសឆាយផ្លូវចូល។ លំនៅដ្ឋានដែលនៅជិតបំផុតមានចម្ងាយ ០.៧ គម ពីទីតាំង។ វ៉ាក់សាំងដែលផលិតនៅមជ្ឈមណ្ឌលនេះនឹងត្រៀមសម្រាប់ចែកចាយទូទាំងប្រទេស ហើយអាចឱ្យម្ចាស់ គោ ក្របី ជ្រូក ពពែ មាន់ និងទា បានចាក់វ៉ាក់សាំងការពារសត្វចិញ្ចឹមរបស់ពួកគេ ប្រឆាំងនឹងជំងឺដង្កោ និងជំងឺអាសន្នរោគ (លើសត្វមាន់) និងជំងឺសារទឹក និងជំងឺដុំពកស្បែក (លើសត្វទំពារអៀង)។

## ៣. មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC)

២៣. មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC) ដែលបានស្នើឡើង គឺជាគំនិតផ្តួចផ្តើមអាទិភាពមួយ ដើម្បីឈានទៅរកការត្រៀមខ្លួនជេញថ្លៃ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការកែសម្រួលសេនេទិកសត្វគោ តាមរយៈការបង្កើនសមត្ថភាពនៃការបង្កាត់ពូជសិប្បនិម្មិត (AI) នៅកម្ពុជា។ មជ្ឈមណ្ឌលនេះនឹងត្រូវបង្កើតឡើងនៅលើផ្ទៃដី ១៣១.២ ហិកតាដែលត្រូវបានចាត់ចែងរួចហើយដោយអគ្គនាយកដ្ឋាន GDAHP ស្ថិតក្នុងខេត្តកំពង់ធំ ដែលមានចម្ងាយប្រហែល ២០៨ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ មជ្ឈមណ្ឌលនេះទៀតសោត នឹងបង្កើតតំបន់ជីវសុវត្ថិភាពដែលនឹងផ្តល់ជម្រកសម្រាប់គោបាពូជចំនួន ១៦ ក្បាល ដែលអនុញ្ញាតឱ្យមានការប្រមូល រក្សាទុក និងការចែកចាយទឹកមេជីវិតរបស់គោបាទាំងនេះសម្រាប់បង្កាត់ពូជ និងមានការបណ្តុះបណ្តាលអ្នកបច្ចេកទេស AI ពេទ្យសត្វ បុគ្គលិកសាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងកសិករឈានមុខដែលមានសក្តានុពល។ ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការរួមមាន៖ ក្រោលចិញ្ចឹមសត្វ កន្លែងឱ្យចំណី និងវាលចំណីស្មៅ បន្ទប់ពិសោធន៍កែច្នៃទឹកមេជីវិត មណ្ឌលបណ្តុះបណ្តាល ការិយាល័យ កន្លែងស្នាក់នៅសម្រាប់បុគ្គលិក និងសិក្ខាកាម កន្លែងផលិតអាស៊ូតរាវដែលមានចំណុះចាប់ពី ១៥០លីត្រ/ថ្ងៃ ហើយត្រូវហ៊ុមព័ទ្ធដោយរបងជីវសុវត្ថិភាព ដើម្បីកំណត់ការចេញចូលរបស់សត្វ និងមនុស្ស និងមានការគ្រប់គ្រងទឹកកង្វក់ តាមរយៈប្រព័ន្ធ DEWATS ផងដែរ។ ទឹកមេជីវិតដែលផលិតចេញពីសត្វគោទាំងនេះ នឹងអាចរកបានតាមរយៈជំនួយសម្រាប់ការបង្កាត់ពូជសិប្បនិម្មិត (AI) សម្រាប់កសិករទាំងអស់ដែលកំពុងស្វែងរកការកែលម្អគុណភាពគោដែលពួកគេកំពុងចិញ្ចឹម។

## ៤. ផ្សារលក់មាន់ទារស់ដូនកែវ (DKLBM)

២៤. ហេដ្ឋារចនាសម្ព័ន្ធសំណង់នៃផ្សារ DKLBM រួមមានផ្សារលក់សត្វមាន់ទារស់ដែលមានទំហំ ១០ម x ១៩.៥ ម ក្នុងក្រុង ដូនកែវនៃខេត្តតាកែវ។ ផ្សារនេះ នឹងរួមបញ្ចូលកន្លែងសម្រាប់អាជីវករលក់ដូរសត្វមាន់ទារស់ រហូតដល់ចំនួន ៤០ នាក់ និងអ្នកសត្តឃាតមាន់ទា ចំនួន ៥ នាក់។ កន្លែងលក់មាន់ទានេះ នឹងស្ថិតនៅដាច់ដោយឡែក ពី

កន្លែងសម្លាប់ ហើយអតិថិជន នឹងត្រូវខ័ណ្ឌចែកពីកន្លែងប្រមូលផ្តុំសត្វមាន់ទារស់ដោយរបងសំណាញ់ដែក។ ផ្សារនេះនឹងរួមបញ្ចូលការផ្គត់ផ្គង់ទឹកក្តៅបានពីពន្លឺព្រះអាទិត្យដែលជំរុញដោយអគ្គិសនីទៅដល់កន្លែងសម្លាប់ មាន់ទាសមត្ថភាពលាងសម្អាតដោយសម្ពាធខ្ពស់ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់ដោយវិមជ្ឈការ (DEWATS) នៅក្រោមដីដែលនឹងបង្ហូរចូលទៅក្នុងប្រព័ន្ធលូរបស់ក្រុង។ ហេដ្ឋារចនាសម្ព័ន្ធនេះ នឹងត្រូវសាងសង់លើដីកម្មសិទ្ធិរបស់រដ្ឋាភិបាលក្នុងទំហំផ្ទៃដីប្រមាណ ២០០ ម៉ែត្រក្រឡា ដែលមានទីតាំងនៅក្បែរផ្សារជំដូនកែវ។

២៥. ផ្សារ DKLBM នឹងជំនួសផ្សារលក់សត្វមាន់ទាដែលគ្មានអនាម័យ ដែលមានស្រាប់ ដោយការធានាបាននូវកម្រិតសុវត្ថិភាពចំណីអាហារកាន់តែល្អប្រសើរដោយការញែកចេញពីគ្នា និងធ្វើឱ្យប្រសើរឡើងទាំងដំណើរការលក់ដូរ និងការសម្លាប់សត្វ ធ្វើឱ្យប្រសើរឡើងនូវអនាម័យ កាត់បន្ថយ ហានិភ័យដល់មនុស្ស និងការចម្លងរោគដោយសារសត្វមាន់ទាដែលស្លាប់ ជាពិសេសពីជំងឺគ្រុនផ្តាសាយបក្សី ដែលមានអត្រាឆ្លងខ្ពស់ (មេរោគ HAPI) និងភ្នាក់ងារបង្ករោគដ៏មានសក្តានុពលផ្សេងទៀត ក៏ដូចជាការកែលម្អសុខុមាលភាពសត្វផងដែរ។ ផ្សារនេះ ក៏ត្រូវរៀបចំរចនាឡើងដើម្បីធានាឱ្យមានការបោះចោលសំណល់រឹង និងរាវ ដែលមានស្រាប់ ចេញពីការរក្សាទុកដាក់មាន់ទា និងការសម្លាប់សត្វឱ្យបានសមរម្យផងដែរ។

២៦. ផ្សារលក់សត្វមាន់ទារស់ DKLBM នឹងត្រូវគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងផ្សារដូនកែវតែម្តង។ អាជីវករលក់មាន់ទា និងអ្នកសម្លាប់សត្វ នឹងត្រូវបង់ថ្លៃសេវា (ឬផាសុី) ជារៀងរាល់ខែ ដើម្បីអាចលក់ដូរ និងសម្លាប់សត្វនៅក្នុងផ្សារនេះបាន។ ដំណើរការអនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយ បានរួមបញ្ចូលការសិក្សាអំពីផលប៉ះពាល់នៃការផ្លាស់ប្តូរទីតាំងលក់ដូររបស់អាជីករលក់មាន់ទា និងអ្នកសត្តឃាតអំឡុងពេលសាងសង់ផ្សារ DKLBM ហើយបានសន្និដ្ឋានថាអ្នកទាំងនោះនឹងមិនរងផលប៉ះពាល់ជាសម្ភារៈ ឬសង្គមដោយសារការផ្លាស់ប្តូរទីតាំងលក់នេះទេ។ ការសិក្សានោះក៏បានរកឃើញថា ហាង ឬតូបលក់ដូរនៅជាប់តំបន់ផ្សារនោះ ក៏នឹងមិនរងផលប៉ះពាល់ពីការសាងសង់ផ្សារនេះដែរ។

២៧. ដោយផ្អែកលើការពិគ្រោះយោបល់ជាច្រើនជុំជាមួយអ្នកលក់ទាំងនោះ ពួកគេមិនជឿថាប្រាក់ចំណូលរបស់ពួកគេនឹងត្រូវបានថយចុះដោយសារតែការផ្លាស់ទីតាំងបណ្តោះអាសន្នរយៈពេល ៦ ខែ អំឡុងពេលសាងសង់ផ្សារនេះទេ ដោយសារតែអតិថិជននឹងបន្តទិញមាន់ទារស់ ឬដែលទើបតែសម្លាប់ថ្មីៗ។ យ៉ាងណាក៏ដោយ ពួកគេមានការបារម្ភខ្លាំងខ្លាចក្រែងមានការបិទខ្ទប់បន្ថែមទៀតដោយសារជំងឺរាតត្បាតកូវីដ-១៩ ប៉ុន្តែទំនងជាមិនមានការបិទខ្ទប់សារជាថ្មីនោះទេ ដោយសារតែកម្ពុជាបានបង្ហាញឱ្យឃើញថាជាប្រទេសមួយដែលអាចគ្រប់គ្រងជំងឺរាតត្បាតក្នុងតំបន់បានយ៉ាងល្អប្រសើរបំផុត។ ក្នុងដំណើរបេសកកម្មអនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយ បានគេរកឃើញផងដែរថា ម្ចាស់តូប ឬហាងអាជីវកម្មផ្សេងទៀត ដែលនៅជុំវិញផ្សារនោះ ដូចជាហាងសាឡន និងហាងកាត់សក់ នឹងមិនរងផលប៉ះពាល់ក្នុងអំឡុងពេល ឬក្រោយពេលសាងសង់ផ្សារ DKLBM នេះទេ។ អនុគម្រោងនេះ នឹងធ្វើជាឧទាហរណ៍មួយសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវផ្សារលក់មាន់ទាដទៃទៀតជាបន្តបន្ទាប់ ទាំងការបញ្ចៀសបាននូវផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត លើកលែងតែផលប៉ះពាល់បណ្តោះអាសន្នមួយចំនួនតូច

ហើយអតិថិជនដែលទិញមាន់ទា នឹងកាន់តែមានទំនុកចិត្តថាសត្វមាន់ទាដែលពួកគេទិញត្រូវបានត្រួតពិនិត្យជំងឺយ៉ាងត្រឹមត្រូវ ហើយសត្តឃាតត្រូវបានធ្វើឡើងប្រកបដោយអនាម័យល្អ និងដោយមេត្តាធម៌។

២៨. ការកែលម្អផ្សារក្រមួនរបស់រដ្ឋ និងវិស័យឯកជនដែលមានស្រាប់ នឹងអាចអនុវត្តផងដែរនៅក្នុងបណ្ដាខេត្តគោលដៅរបស់គម្រោង រួមទាំងការបង្កើតវិធានការសុវត្ថិភាព និងអនាម័យ កាត់បន្ថយការរីករាលដាលនៃជំងឺ រួមទាំងការផ្ដល់ទឹកស្អាត និងសាប៊ូលាងដៃ ស្បែកជើង និងឧបករណ៍កែច្នៃផលិតផលសត្វ ក៏ដូជាការគ្រប់គ្រងការចោលសំណល់សត្វ ដើម្បីបង្ការហានិភ័យនៃការរីករាលដាលជំងឺក្នុងចំណោមសត្វ និងការពារសុវត្ថិភាពអាជីវករបុគ្គលិកផ្សារ និងអតិថិជនពីការឆ្លងរោគផងដែរ។ ដំណើរការនេះនឹងត្រូវបានបង្កើតឡើង ដើម្បីធានាបាននូវការត្រួតពិនិត្យសុខភាពសត្វទាំងអស់ដែលយកមកចូលផ្សារ និងមានការណែនាំឱ្យអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណសត្វ ប្រព័ន្ធព័ត៌មានសុខភាពសត្វ និងផលិតកម្មសត្វ និងការបិទផ្សារជារៀងរាល់ល្ងាចសម្រាប់លាងសម្អាត និងសម្លាប់មេរោគ។ ចំណុចនេះទាមទារឱ្យមានការចូលរួមពីរដ្ឋាភិបាល និងម្ចាស់ផ្សារ ដើម្បីធានាថាសកម្មភាពជីវសុវត្ថិភាពទាំងនេះត្រូវបានអនុវត្ត និងអាចកាត់បន្ថយបានដោយជោគជ័យលើការចម្លងមេរោគ និងហានិភ័យដល់សុខភាពសាធារណៈ។ ទន្ទឹមនឹងនេះ ផ្សារទាំងអស់ដែលត្រូវកែលម្អ នឹងមានរៀបចំដំឡើងប្រព័ន្ធ DEWATS និងជីវឧស្ម័ន។

## ៥. វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ (NAHPRI)

២៩. អគ្គនាយកដ្ឋាន GDAHP បានស្នើឱ្យមានការកែលម្អវិទ្យាស្ថាន NAHPRI ដើម្បីឆ្លើយតបចំពោះតម្រូវការផ្នែកសមត្ថភាពត្រួតពិនិត្យគុណភាពចំណី និងការធ្វើតេស្តសុវត្ថិភាពចំណីអាហារ។ អគារវិទ្យាស្ថាន NAHPRI ដែលមានកម្ពស់ ៣ ជាន់នៅក្នុងបរិវេណនៃអគ្គនាយកដ្ឋាន GDAHP នឹងត្រូវបានកែលម្អឡើងវិញ ដើម្បីឱ្យក្លាយជាមន្ទីរពិសោធន៍មួយដែលមានលក្ខខណ្ឌសុវត្ថិភាពកម្រិត ២ ទាំងស្រុង ជាមួយនឹងការរុះរើការិយាល័យបច្ចុប្បន្នដែលមានទំហំពាក់កណ្ដាលនៃជាន់ទី២ និងនៅកន្លែងផ្សេងទៀត ដើម្បីពង្រីកសមត្ថភាពមន្ទីរពិសោធន៍ធ្វើតេស្តសំណល់សាច់សត្វ។ ចំណែកនៅជាន់ផ្ទាល់ដី នឹងត្រូវបានកែលម្អដើម្បីបង្កើតជាកន្លែងទទួលសំណាក និងកន្លែងស្តុកសំណាក និងធ្វើជាមន្ទីរពិសោធន៍ចំណីសត្វ។ តារាងលម្អិតនៃការធ្វើតេស្តប្រចាំឆ្នាំដែលរំពឹងទុក និងបរិក្ខារថ្មីៗដែលត្រូវការជាចាំបាច់ ត្រូវបានរៀបចំរួចរាល់ ហើយបញ្ហាបោះចោលសំណល់កង្វក់ ក៏កំពុងត្រូវបានដោះស្រាយផងដែរ។ ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជាដែលកំពុងប្រើប្រាស់ផលិតផលសាច់ ទំនងជាទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់វិទ្យាស្ថាន NAHPRI តាមរយៈការលើកកម្ពស់សុវត្ថិភាពចំណីអាហារ គុណភាពចំណីអាហារ និងផលិតផលសាច់សត្វ។

# III. គោលបំណង ក្របខ័ណ្ឌគោលនយោបាយ និងសិទ្ធិទទួលបាន

## ក. កម្មវត្ថុនៃក្របខ័ណ្ឌស្តីពីការបែងចែកដីធ្លី និងការតាំងទីលំនៅជាថ្មី

៣០. ក្របខ័ណ្ឌស្តីបីការតាំងទីលំនៅជាថ្មី (RF) នេះផ្តល់នូវនីតិវិធី និងគោលការណ៍សំខាន់ៗនៃការគាំពារ IR ដែលនឹងគ្រប់គ្រងលើការរៀបចំ ការធ្វើបច្ចុប្បន្នកម្ម និងការអនុវត្ត DRPs សម្រាប់អនុគម្រោងនេះ ស្របតាមលក្ខខណ្ឌតម្រូវនៃ SPS-ADB ឆ្នាំ២០០៩ និងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជាសម្រាប់ការត្រួតពិនិត្យតាមដាន និងការអនុវត្ត DRP នៃអនុគម្រោងនានា។ ក្របខ័ណ្ឌ RF ត្រូវបានរៀបចំឡើងដោយផ្អែកលើការពិគ្រោះយោបល់ផ្សេងៗដែលបានធ្វើឡើងជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងមន្ត្រីរដ្ឋាភិបាល ដែលត្រូវបានកាត់បន្ថយចំនួនខ្លះដោយសារតែការបិទខ្ទប់អំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។ ទោះជាយ៉ាងណាក៏ដោយ ការពិគ្រោះយោបល់ទល់មុខគ្នា ត្រូវបានធ្វើឡើងនៅក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ ដោយទីប្រឹក្សាជាតិទទួលបន្ទុកផ្នែកគាំពារសង្គមនៃក្រុម TRTA ក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ និងក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២២ និងការពិគ្រោះយោបល់ដែលបានធ្វើឡើងដោយទីប្រឹក្សាអន្តរជាតិទទួលបន្ទុកផ្នែកគាំពារសង្គមនៃក្រុម TRTA និងដោយមានជំនួយពីបុគ្គលិកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១ និងខែឧសភា និងខែមិថុនា ឆ្នាំ២០២២។

## ខ. គោលនយោបាយ និងក្របខ័ណ្ឌច្បាប់

៣១. គោលនយោបាយស្តីពីការបែងចែកដីធ្លី និងការផ្តល់សំណងរបស់គម្រោង នឹងត្រូវរៀបចំជាផែនការ និងអនុវត្តស្របតាមលក្ខខណ្ឌតម្រូវរបស់ ADB និងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា។ ការវិភាគលម្អិតលើគោលនយោបាយ និងបទប្បញ្ញត្តិនានាដែលមានស្រាប់ ត្រូវបានអនុវត្តដើម្បីពិពណ៌នាអំពីភាពអាចអនុវត្តបានចំពោះគោលនយោបាយ និងបទប្បញ្ញត្តិទាំងនោះ នៅក្នុងវង្វង់ក្របខ័ណ្ឌនេះ ដូចខាងក្រោម៖

### ១. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

៣២. រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់ការបែងចែកដីធ្លីជាប្រយោជន៍សាធារណៈ។ ដំបូងបំផុត គឺនៅត្រង់មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ចែងថា៖ ការដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈ តម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

### ២. ច្បាប់ភូមិបាល ឆ្នាំ២០០១

៣៣. ច្បាប់ភូមិបាល ឆ្នាំ២០០១ គឺជាច្បាប់ដ៏ទូលំទូលាយមួយដែលចែងអំពីសិទ្ធិកាន់កាប់ដីធ្លី និងអចលនទ្រព្យនៅកម្ពុជា។ ដោយផ្អែកលើបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ច្បាប់ភូមិបាលនេះ មានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយដូចជាដី ដើមឈើ និងរចនាសម្ព័ន្ធសំណង់នៅមួយកន្លែង។

៣៤. សិទ្ធិ និងទំនួលខុសត្រូវរបស់រដ្ឋាភិបាលទាក់ទងនឹងសិទ្ធិគ្រប់គ្រងលើដីសាធារណៈ (ឬអំណាចអស្សាមិករណ៍) ត្រូវបានបញ្ជាក់នៅក្នុងច្បាប់ភូមិបាល។ រដ្ឋាភិបាលអាចដកយកដីឯកជនសម្រាប់គោលបំណងប្រើប្រាស់ជាសាធារណៈ ប៉ុន្តែត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។ ច្បាប់ភូមិបាល ត្រង់មាត្រា ៥ ចែងថា៖ គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

៣៥. បទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ភូមិបាល ដែលពាក់ព័ន្ធនឹងការបែងចែកដីធ្លី ការទូទាត់សំណង និងការតាំងទីលំនៅជាថ្មី រួមមាន៖

(១). ភោគៈត្រឹមត្រូវតាមច្បាប់ គឺជាមូលដ្ឋានតែមួយគត់សម្រាប់ភាពជាម្ចាស់កម្មសិទ្ធិ ហើយរាល់ការផ្ទេរ ឬផ្លាស់ប្តូរសិទ្ធិនៃកម្មសិទ្ធិ ត្រូវធ្វើឡើងតាមវិធាននៃនីតិរួមនៃការលក់ ការបន្តមរតក ការដោះដូរ ឬ ប្រទានកម្ម ឬតាមសេចក្តីសម្រេចរបស់តុលាការ។ (មាត្រា ៦)។

(២). របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់។ (មាត្រា ៧)។

(៣). មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដី នៃព្រះរាជាណាចក្រកម្ពុជា ឬមានសិទ្ធិទិញ ឬលក់ដី។ (មាត្រា ៨ និង ៦៦)។

(៤). ដីសាធារណៈរបស់រដ្ឋ រួមមានក្នុងចំណោមការចាត់ថ្នាក់ផ្សេងៗ និងទ្រព្យសម្បត្តិទាំងឡាយណា៖

(ក). ដែលបានកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹក ច្រាំងទន្លេ ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ឬបឹងធម្មជាតិ

(ខ). ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និង ឧទ្យានសាធារណៈ និងដីចំណី ឬ

(គ). ដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈដូចជាសាលារៀន ឬអគារសិក្សារបស់រដ្ឋ មន្ទីរពេទ្យរដ្ឋ ឬអគាររដ្ឋបាលទាំងឡាយ។ (មាត្រា ១៥)។

(៥). បុគ្គលទាំងឡាយដែលកាន់កាប់ ឬមានប័ណ្ណកាន់កាប់ដោយខុសច្បាប់លើដីសាធារណៈរបស់រដ្ឋ មិនអាចទាមទារសំណងទូទាត់បានឡើយ។ នេះរួមបញ្ចូលទាំងដីដែលរៀបចំទុកដោយរដ្ឋាភិបាលសម្រាប់ជាចំណីផ្លូវសាធារណៈ ដូចជាផ្លូវថ្នល់ និងផ្លូវដែក ជាដើម។ ជាងនេះទៅទៀត ការមិនប្រគល់ដី ដែលកាន់កាប់ដោយខុសច្បាប់ឱ្យបានទាន់ពេលវេលាទេនោះ នឹងត្រូវទទួលពិន័យ និង/ឬដាក់ពន្ធនាគារ ទៀតផង។ (មាត្រា ១៩)។

(៦). កម្មសិទ្ធិនៃដីធ្លីដែលត្រូវបានផ្តល់ដោយរដ្ឋ ជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព រួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ។ ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិសមូហភាព គឺត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរ និងយន្តការធ្វើសេចក្តីសម្រេចចិត្តរបស់

សហគមន៍ជនជាតិដើមភាគតិច អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅ ដូចជាច្បាប់ការពារបរិស្ថានជាដើម។ (មាត្រា ២៦)។ ចំណែកត្រង់មាត្រា ២៣ ចែងថា ៖ សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។ (មាត្រា ២៣)។

(៧). បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងស្របច្បាប់ចាប់ពី ៥ ឆ្នាំឡើងទៅ (គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះ) មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិ ជាស្ថាពរ (មាត្រា ៣០)។ បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមកដោយស្របច្បាប់តិចជាង រយៈពេល ៥ ឆ្នាំ (**គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ក្នុងឆ្នាំ២០០១**) អាចរក្សាកាន់កាប់រហូតដល់គ្រប់រយៈពេលស្របច្បាប់ ៥ ឆ្នាំ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរ។ (មាត្រា ៣០)។

## ៣. ច្បាប់ស្តីពីអស្សាមិករណ៍

៣៦. ច្បាប់ស្តីពីអស្សាមិករណ៍ ត្រូវបានរដ្ឋសភាជាតិអនុម័តនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០ រួមមាន ៨ ជំពូក និង ៣៩ មាត្រា។ ច្បាប់នេះ ផ្តល់នូវ នីតិវិធីច្បាស់លាស់លើសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិឯកជនសម្រាប់បម្រើឱ្យផលប្រយោជន៍ជាតិ និងសាធារណៈ។ មាត្រាសំខាន់ៗមួយចំនួននៃច្បាប់នេះ មានដូចតទៅ៖

(១). មាត្រា ២៖ ច្បាប់នេះមានគោលបំណងជាអាទិ៍៖ (ក). ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជន ដោយសមរម្យ និងយុត្តិធម៌។ (ខ). ធានាការទូទាត់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។ (គ). បម្រើផលប្រយោជន៍ជាតិ និងសាធារណៈ។ និង (ឃ). ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រូបវន្តសាធារណៈ។

(២). មាត្រា ៧៖ មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។

(៣). មាត្រា ៨៖ រដ្ឋត្រូវទទួលទិញយកនូវចំណែកនៃអចលនវត្ថុដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយតម្លៃសមរម្យ និងយុត្តិធម៌ តាមសំណើររបស់ម្ចាស់អចលនវត្ថុ ឬម្ចាស់កម្មសិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬពុំអាចសាងសង់លំនៅស្ថានបាន ឬពុំអាចប្រកបអាជីវកម្មផ្សេងទៀតបាន។

(៤). មាត្រា ១១៖ មុននឹងដំណើរការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលាជូនគណៈកម្មការអស្សាមិករណ៍ តាមសំណើររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុដែលរងផលប៉ះពាល់ដោយអស្សាមិករណ៍។

(៥). មាត្រា ១២៖ គណៈកម្មាធិការអស្សាមិករណ៍ ត្រូវបង្កើតឡើង និងដឹកនាំដោយតំណាងមួយរូបមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានសមាសភាពតំណាងមកពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានកំណត់ដោយអនុក្រឹត្យ (អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៨)។ មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលម្អិត ចំពោះរាល់សិទ្ធិម្ចាស់អចនវត្ថុនិងម្ចាស់សិទ្ធិលើអចនវត្ថុនិងព្រទ្យសម្បត្តិផ្សេងៗទៀតដែលមានពាក់ព័ន្ធ នឹងការផ្តល់សំណង់ ព្រមទាំងកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ ដទៃទៀត។ ក្នុងការធ្វើអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិត អាជ្ញាធររាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ជាមួយក្រុមប្រឹក្សា ឃុំសង្កាត់ និងតំណាងភូមិ ឬសហគមន៍ ដែលរងផលប៉ះពាល់ពីអស្សាមិករណ៍ ដើម្បីផ្តល់ព័ត៌មាន ជាក់លាក់ច្បាស់លាស់ និងទទួលបាននូវមតិ យោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើ នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

(៦). មាត្រា ១៦៖ មុននឹងស្នើសុំគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការស្ទង់មតិជាសាធារណៈជាមួយនឹងការពិពណ៌នាលម្អិតអំពីកម្មសិទ្ធិករ និង/ឬម្ចាស់សិទ្ធិនៃអចលនវត្ថុ និងអចលនទ្រព្យផ្សេងទៀតដែលអាចត្រូវការសំណង ហើយបញ្ហាផ្សេងទៀតទាំងអស់ នឹងត្រូវកត់ត្រាផងដែរ។ នៅក្នុងការស្ទង់មតិនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការរៀបចំ ចាត់ចែង ធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ជាមួយក្រុមប្រឹក្សា ឃុំ-សង្កាត់ និងតំណាងភូមិ ឬសហគមន៍ដែលរងនូវអស្សាមិករណ៍ គឺដើម្បីទទួលបាននូវពត៌មានដែលបានផ្តល់ពីអ្នកទាំងអស់នោះឱ្យបានច្បាស់លាស់ និងទទួលបាននូវមតិយោបល់ពីគ្រប់ភាគីដែលពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

(៧). មាត្រា ២២៖ ចំនួនទឹកប្រាក់ដែលត្រូវទូទាត់សំណងទៅម្ចាស់អចលនវត្ថុ និងម្ចាស់សិទ្ធិលើអចនវត្ថុត្រូវបានឆ្លងកាត់ការវាយតម្លៃជាក់លាក់តាមតម្លៃទីផ្សារនៃអចលនវត្ថុ ឬតម្លៃជំនួសដោយគិតត្រឹមថ្ងៃចេញប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ តម្លៃទីផ្សារ ឬតម្លៃជំនួស ត្រូវកំណត់ដោយគណៈកម្មការ ឬក៏ភ្នាក់ងារឯករាជ្យដែលជាអ្នកវាយតម្លៃ តាមរយៈការជ្រើសរើសដោយគណៈកម្មាធិការអស្សាមិករណ៍។

## ៤. ច្បាប់ជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

៣៧. **អនុក្រឹត្យលេខ ១១៥ ២២ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦** ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR)។ នេះគឺជាឧបករណ៍និតិវិធីដែលរៀបរាប់ពីតួនាទី និងការទទួលខុសត្រូវរបស់ GDR ទាក់ទងនឹងការរៀបចំ និងការអនុវត្តផែនការតាំងទីលំនៅថ្មី និងក្នុងការសម្របសម្រួលគណៈកម្មាធិការអន្តរក្រសួងស្រាយផលប៉ះពាល់លើការតាំងលំនៅថ្មី (IRC)។

៣៨. **អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨** ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា សម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត សម្រាប់គម្រោងហិរញ្ញប្បទានពីខាងក្រៅ ដែលកំណត់នូវគោលនយោបាយ បទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការអនុវត្តពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) ដែលនឹងអនុវត្តចំពោះគម្រោងនេះ។ នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (SOP) ផ្តល់នីតិវិធីសម្រាប់ការប្រើប្រាស់គោលនយោបាយការពារដៃគូអភិវឌ្ឍន៍ និងសម្រាប់វិធានការបំពេញចន្លោះប្រហោងដែលបទប្បញ្ញត្តិនៃ SOP មានភាពខ្វែងគំនិតគ្នាជាមួយនឹងលក្ខខណ្ឌតម្រូវផ្នែកការការពារជាកាតព្វកិច្ចរបស់ដៃគូអភិវឌ្ឍន៍។

៣៩. **អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច** ខែមីនា ឆ្នាំ២០០៣ ចែងអំពីការបែងចែកដីរដ្ឋជូនប្រជាពលរដ្ឋដែលគ្មានដីដោយឥតគិតថ្លៃ សម្រាប់គោលបំណងធ្វើជាលំនៅឋាន ឬធ្វើកសិកម្មជាលក្ខណៈគ្រួសារ រួមទាំងការផ្តល់ ដីជំនួសដែលបាត់បង់ ប្រសិនបើក្នុងករណីនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។

៤០. **អនុក្រឹត្យលេខ ២៥ ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា** ខែមេសា ឆ្នាំ១៩៨៩ ទទួលស្គាល់កម្មសិទ្ធិផ្ទះឯកជនរួមទាំងដីធ្លី និងបានបញ្ជាក់ក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១ (មាត្រា ៤)។ ប្រជាពលរដ្ឋកម្ពុជា អាចចុះបញ្ជីដីធ្លីដែលខ្លួនកាន់កាប់ជាមួយការិយាល័យរដ្ឋបាលសុរិយោដីមូលដ្ឋាន (CAO) ដោយមានវិញ្ញាបនបត្របញ្ជាក់ប្លង់កម្មសិទ្ធិដីធ្លី។ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី គឺជាដំណើរការដ៏វែងឆ្ងាយ ហើយការិយាល័យភាគច្រើនមានគំនរឯកសារ សំខាន់ៗជាច្រើន និងពាក្យស្នើសុំដែលមិនទាន់សម្រេចដោះស្រាយរួច។ ប្រជាពលរដ្ឋត្រូវបានផ្តល់បង្កាន់ដៃបញ្ជាក់ កម្មសិទ្ធិមួយ ទម្រាំមានការចេញប័ណ្ណកម្មសិទ្ធិជាផ្លូវការ ហើយបង្កាន់ដៃនោះ គឺជាតឹកតាងដែលអាចយកទៅ ប្រើប្រាស់បានសម្រាប់ម្ចាស់ដីពិតប្រាកដ ឬក្នុងការលក់ដូរផងដែរ។ ស្ថានភាពផ្លូវច្បាប់នៃការប្រើប្រាស់ដីនៅកម្ពុជា បច្ចុប្បន្ន អាចចាត់ថ្នាក់ដូចខាងក្រោម៖

(១). *ដីឯកជនដែលមានប័ណ្ណកម្មសិទ្ធិ៖* កម្មសិទ្ធិករមានប័ណ្ណកម្មសិទ្ធិជាផ្លូវការលើដី ហើយទាំងម្ចាស់ និងរដ្ឋបាលសុរិយោដីសុទ្ធតែមានច្បាប់ចម្លងនៃប័ណ្ណកម្មសិទ្ធិនោះ។

(២). *ដីឯកជនគ្មានប័ណ្ណកម្មសិទ្ធិ៖* កម្មសិទ្ធិករមានពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដែលមិនទាន់សម្រេច ហើយកំពុងរង់ចាំការចេញប័ណ្ណកម្មសិទ្ធិផ្លូវការ។ រដ្ឋបាលសុរិយោដី ទទួលស្គាល់ម្ចាស់កម្មសិទ្ធិ។

(៣). *ប័ណ្ណបញ្ជាក់សិទ្ធិប្រើប្រាស់ដីធ្លី៖* ក្នុងករណីនេះ បង្កាន់ដៃសម្រាប់ការប្រើប្រាស់ដីរយៈពេលវែង ត្រូវបានចេញឱ្យប្រើប្រាស់បាន។ សិទ្ធិប្រើប្រាស់ដីនេះ ត្រូវបានទទួលស្គាល់ដោយរដ្ឋបាល សុរិយោដី។

(៤). *ដីជួល៖* រដ្ឋាភិបាល ឬម្ចាស់ឯកជនជួលដី ជាធម្មតាក្នុងរយៈពេលខ្លី។ រដ្ឋាភិបាលអាចដកហូត យកដីមកវិញបាន ប្រសិនបើត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍណាមួយ។

(៥). *ការកាន់កាប់មិនស្របច្បាប់៖* អ្នកប្រើប្រាស់ គ្មានសិទ្ធិប្រើប្រាស់ដីលើដីដែលខ្លួនកាន់កាប់ ឬប្រើប្រាស់នោះបានទេ។ រដ្ឋបាលសុរិយោដី មិនទទួលស្គាល់ចំពោះការប្រើប្រាស់ដីនេះឡើយ។

៤១. **សារាចរលេខ ០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ចែងថា៖**

(១). អ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ គ្មានសិទ្ធិទទួលបានសំណង និងអាចត្រូវបានផ្តន្ទាទោសតាមច្បាប់ភូមិបាល ឆ្នាំ២០០១ និង

(២). អ្នកកាន់កាប់ដីដោយខុសច្បាប់ដែលក្រីក្រ គ្មានដីធ្លី និងជាផ្នែកមួយនៃក្រុមជនងាយរងគ្រោះ អាចត្រូវបានផ្តល់ឱ្យនូវដីមួយប្លង់។

## ៥. គោលនយោបាយដោះស្រាយផលប៉ះពាល់, សេចក្តីថ្លែងគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS-ADB)

៤២. គោលបំណងនៃគោលនយោបាយការពារស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ធនាគារអភិវឌ្ឍន៍ អាស៊ី (ADB) គឺ៖ (១). ដើម្បីបញ្ចៀសនូវការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត តាមដែលអាចធ្វើទៅបាន, (២). ដើម្បីកាត់បន្ថយការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត តាមរយៈការសិក្សារកមើលជម្រើសគម្រោង និងការរៀបចំរចនាប្លង់ផ្សេងៗទៀត, (៣). ដើម្បីលើកស្ទួយ ឬយ៉ាងហោចណាស់ស្តារឡើងវិញ ចំពោះការប្រកបរបរចិញ្ចឹមជីវិតរបស់អ្នកដែលត្រូវផ្លាស់ទីលំនៅទាំងអស់ ឱ្យបានក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោងអភិវឌ្ឍន៍, និង (៤). ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រ ដែលផ្លាស់ទីលំនៅ និងក្រុមងាយរងគ្រោះផ្សេងៗទៀត។

២៦. គោលការណ៍ការការពារស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ផ្តោតលើការផ្លាស់ទីលំនៅជាលក្ខណៈរូបវន្ត (ការផ្លាស់ទីលំនៅជាថ្មី ការបាត់បង់ដីលំនៅឋាន ឬការបាត់បង់ទីជម្រក) និងការផ្លាស់ទីលំនៅ ជាលក្ខណៈសេដ្ឋកិច្ច (ការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ ការទទួលបានទ្រព្យសម្បត្តិ ប្រភពចំណូល ឬមធ្យោបាយ ចិញ្ចឹមជីវិត) ដែលជាលទ្ធផលនៃ (១). លទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត (ដោយបង្ខំ) ឬ (២). ការរិតត្បិតដោយមិនស្ម័គ្រចិត្ត (ដោយបង្ខំ) លើការប្រើប្រាស់ដីធ្លី ឬលើការចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារដែលបានកំណត់ដោយស្របច្បាប់។ គោលការណ៍នេះ ផ្តោតលើចំណុចថាតើការខាតបង់ និងការរឹតត្បិតដោយមិនស្ម័គ្រចិត្តទាំងនោះ មានសភាពទាំងស្រុង ឬដោយផ្នែក ជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន។

២៧. សម្រាប់ប្រតិបត្តិការនៃគម្រោងណាមួយក្រោមក្របខណ្ឌនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលតម្រូវឱ្យមានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ការធ្វើផែនការតាំងទីលំនៅជាថ្មី គឺជាផ្នែកសំខាន់មួយនៃការរចនាប្លង់គម្រោង ដែលត្រូវដោះស្រាយចាប់ពីដំណាក់កាលដំបូងនៃវដ្តគម្រោង ដោយពិចារណាលើគោលការណ៍ ជាមូលដ្ឋាន ដូចខាងក្រោម៖

(១). ពិនិត្យពិច័យគម្រោងឱ្យបានឆាប់ពីដំបូង ដើម្បីកំណត់ពីផលប៉ះពាល់ និងហានិភ័យនៃការតាំងទីលំនៅ ជាថ្មីដោយមិនស្ម័គ្រចិត្តពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ កំណត់វិសាលភាព នៃផែនការតាំងទីលំនៅ

ជាថ្មីតាមរយៈការស្ទង់មតិ និង/ឬជំរឿនប្រជាជនដែលរងផលប៉ះពាល់ (អ្នកដែលត្រូវផ្លាស់ទី) រួមទាំងការវិភាគយេនឌ័រ ជាពិសេសទាក់ទងនឹងផលប៉ះពាល់ និងហានិភ័យ នៃការតាំងលំនៅជាថ្មី។

(២). អនុវត្តការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយអ្នកដែលត្រូវផ្លាស់ទី សហគមន៍ ម្ចាស់ស្រុក និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ (NGOs)។ ជូនដំណឹងដល់ អ្នកដែលត្រូវផ្លាស់ទី ទាំងអស់អំពីសិទ្ធិ និងជម្រើសនៃការតាំងទីលំនៅជាថ្មីរបស់ពួកគេ។ យកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការចាំបាច់របស់ក្រុមងាយរងគ្រោះ ជាពិសេសអ្នកដែលស្ថិត នៅក្រោមបន្ទាត់ភាពក្រីក្រ អ្នកគ្មានដីធ្លី ចាស់ជរា ស្ត្រី និងកុមារ និងជនជាតិដើមភាគតិច និងអ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់លើដីធ្លី និងធានាឱ្យមានការចូលរួមរបស់ពួកគេក្នុងការពិគ្រោះយោបល់។ បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា។

(៣). លើកស្ទួយ ឬយ៉ាងហោចណាស់ស្តារជីវភាពរស់នៅរបស់អ្នកដែលត្រូវផ្លាស់ទីទាំងអស់ តាមរយៈ៖ (ក). យុទ្ធសាស្ត្រតាំងទីលំនៅជាថ្មីនៅលើដីដែលមាន ប្រសិនបើការចិញ្ចឹមជីវិតដែលរងផលប៉ះពាល់គឺ អាស្រ័យលើដី តាមលទ្ធភាពដែលអាចធ្វើបាន ឬសំណងជាសាច់ប្រាក់តាមតម្លៃជំនួសសម្រាប់ដីនោះ ប្រសិនបើការបាត់បង់ដីនោះមិនប៉ះពាល់ដល់ជីវភាពរស់នៅ, (ខ). ការជំនួសភ្លាមៗនូវទ្រព្យសម្បត្តិ ជាមួយនឹងលទ្ធភាពទទួលបានទ្រព្យសម្បត្តិដែលមានតម្លៃស្មើគ្នាឬខ្ពស់ជាងនេះ, (គ). ការទូទាត់សំណង ភ្លាមៗតាមតម្លៃជំនួសពេញលេញសម្រាប់ទ្រព្យសម្បត្តិដែលមិនអាចស្តារឡើងវិញបាន, និង (ឃ). ការផ្តល់ជាប្រាក់ចំណូល និងសេវាកម្មបន្ថែម តាមរយៈគម្រោងចែករំលែកអត្ថប្រយោជន៍ តាមដែលអាច ធ្វើទៅបាន។

(៤). ផ្តល់ជំនួយតាមតម្រូវការចាំបាច់ផ្នែករូបវន្ត និងសេដ្ឋកិច្ច ដល់អ្នកដែលត្រូវផ្លាស់ទី រួមមានដូចជា៖ (ក). ប្រសិនបើមានការផ្លាស់ទី ការកាន់កាប់ដោយធានាចំពោះដីសម្រាប់ការផ្លាស់ទីលំនៅឋានល្អប្រសើរ នៅកន្លែងតាំងលំនៅជាថ្មី ជាមួយនឹងលទ្ធភាពទទួលបានឱកាសការងារ និងផលិតភាពដែលអាច ប្រៀបធៀបបាន សមាហរណកម្មនៃអ្នកតាំងលំនៅជាថ្មីជាលក្ខណៈសេដ្ឋកិច្ច និងសង្គមទៅក្នុងសហគមន៍ ម្ចាស់ស្រុករបស់ពួកគេ និងការពង្រីកអត្ថប្រយោជន៍គម្រោងទៅដល់ សហគមន៍ម្ចាស់ស្រុក, (ខ). ការផ្តល់ជំនួយអន្តរកាល និងជំនួយអភិវឌ្ឍន៍ ដូចជាការអភិវឌ្ឍដីធ្លី ការទទួលបានកម្ចីឥណទាន ការបណ្តុះបណ្តាល ឬឱកាសការងារ, និង (គ). ហេដ្ឋារចនាសម្ព័ន្ធបម្រើដល់ពលរដ្ឋ និងសេវាសហគមន៍ តាមតម្រូវការ។

(៥). ធ្វើឱ្យប្រសើរឡើងនូវស្តង់ដានៃការរស់នៅរបស់ជនក្រីក្រដែលរងផលប៉ះពាល់ និងក្រុមងាយ រងគ្រោះផ្សេងៗទៀត រួមទាំងស្ត្រី យ៉ាងហោចណាស់ឱ្យបានក្នុងកម្រិតស្តង់ដាអប្បបរមាជាតិ។ ចំពោះប្រជាជននៅតាមតំបន់ជនបទ ត្រូវផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានដីធ្លី និងធនធាន ស្របច្បាប់ និងសមរម្យ ចំណែកប្រជាជននៅតំបន់ទីក្រុងវិញ ត្រូវផ្តល់ឱ្យពួកគេនូវប្រភពចំណូលសមរម្យ និងលទ្ធភាពទទួលបានលំនៅឋានស្របច្បាប់ និងសមរម្យ។

(៦). រៀបចំនីតិវិធីក្នុងលក្ខណៈតម្លាភាព សង្គតភាព និងសមធម៌ ប្រសិនបើការបែងចែកដីធ្លីត្រូវធ្វើឡើង តាមរយៈការចរចា។

(៧). ត្រូវធានាថាអ្នកដែលត្រូវផ្លាស់ទី ដែលគ្មានប័ណ្ណកម្មសិទ្ធិលើដី ឬសិទ្ធិស្របច្បាប់ណាមួយ ដែលអាចទទួលស្គាល់បានលើដីធ្លីនោះ ពួកគេមានសិទ្ធិទទួលបានជំនួយសម្រាប់ការតាំងទីលំនៅថ្មី និងការផ្តល់សំណងសម្រាប់ការខាតបង់ទ្រព្យសម្បត្តិមិនមែនដីធ្លី។

(៨). ត្រូវរៀបចំផែនការលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LARP) ដែលរៀបរាប់លម្អិត អំពីសិទ្ធិរបស់អ្នកដែលត្រូវផ្លាស់ទី យុទ្ធសាស្ត្រស្តារប្រាក់ចំណូល និងជីវភាពឡើងវិញ ការរៀបចំ ស្ថាប័ន ការត្រួតពិនិត្យ និងក្របខ័ណ្ឌនៃការរាយការណ៍ ថវិកា និងកាលវិភាគនៃការអនុវត្តតាមពេលវេលាកំណត់។

(៩). លាតត្រដាងសេចក្តីព្រាងផែនការលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LARP) រួមទាំងឯកសារនៃដំណើរការពិគ្រោះយោបល់ក្នុងលក្ខណៈទាន់ពេលវេលា មុនពេលវាយតម្លៃគម្រោង នៅតាមកន្លែងដែលអាចទទួលយកបាន និងក្នុងទម្រង់ និងជាភាសាដែលអាចយល់បានសម្រាប់អ្នក ដែលត្រូវផ្លាស់ទី និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ លាតត្រដាងផែនការតាំងទីលំនៅជាថ្មីចុងក្រោយ និងការធ្វើបច្ចុប្បន្នកម្មផែនការនេះជូនដល់អ្នកដែលត្រូវផ្លាស់ទី និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

(១០). បង្កើតទម្រង់ និងអនុវត្តការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ជាផ្នែកនៃគម្រោងអភិវឌ្ឍន៍ ឬកម្មវិធី។ រួមបញ្ចូលការចំណាយពេញលេញលើការតាំងលំនៅជាថ្មីនៅក្នុងការបង្ហាញពីការចំណាយ និងអត្ថប្រយោជន៍របស់គម្រោង។ សម្រាប់គម្រោងដែលមានផលប៉ះពាល់ដល់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ត្រូវពិចារណាលើការអនុវត្តសមាសភាគនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តនៃគម្រោងជាប្រតិបត្តិការឯកត្តជន (ឬស្វយ័ត)។

(១១). ទូទាត់សំណង និងផ្តល់សិទ្ធិតាំងទីលំនៅជាថ្មីផ្សេងទៀត មុនពេលការផ្លាស់ទីលំនៅជាលក្ខណៈ រូបវន្ត ឬសេដ្ឋកិច្ច។ អនុវត្តផែនការ LARP ក្រោមការត្រួតពិនិត្យយ៉ាងជិតដល់ពេញមួយវដ្តគម្រោង។

(១២). តាមដាន និងវាយតម្លៃលទ្ធផលនៃការតាំងលំនៅជាថ្មី ផលប៉ះពាល់នានាលើស្តង់ដានៃ ការរស់នៅរបស់អ្នកដែលត្រូវផ្លាស់ទី និងថាតើគោលបំណងនៃផែនការ LARP ត្រូវបានសម្រេច ដោគជ័យដោយគិតគូរពីលក្ខខណ្ឌជាមូលដ្ឋាន និងលទ្ធផលនៃការត្រួតពិនិត្យការតាំងទីលំនៅជាថ្មី ដែរឬទេ។ ត្រូវលាតត្រដាងរបាយការណ៍ត្រួតពិនិត្យ។

## ៦. គោលនយោបាយពាក់ព័ន្ធផ្សេងទៀតរបស់ ADB

៤៥. **ជនជាតិដើមភាគតិច៖** អនុគម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ជនជាតិដើមភាគតិច នឹងមិនត្រូវបានផ្តល់ហិរញ្ញប្បទាននៅក្រោមក្របខ័ណ្ឌគម្រោងនោះទេ។[5]

---

[5] ជនជាតិដើមភាគតិចនឹងត្រូវបានកំណត់អត្តសញ្ញាណដោយអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីការការពារសុវត្ថិភាព ADB SPS ៣

៤៦. **យេនឌ័រ៖** កង្វល់ និងបញ្ហាទាក់ទងនឹងយេនឌ័រ នឹងត្រូវបានគិតគូរពិចារណាក្នុងការរៀបចំផែនការ និងការអនុវត្តការតាំងទីលំនៅជាថ្មី។ វិធានការចែករំលែកអត្ថប្រយោជន៍ផ្សេងៗគ្នាទៅតាមយេនឌ័រ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការ DRPs ដើម្បីធានាថាស្ត្រី និងបុរសក្នុងគ្រួសារត្រូវបានយកចិត្តទុកដាក់ដោយស្មើភាពគ្នា។

## ឃ. ការប្រៀបធៀបរវាងគោលការណ៍ ADB-SPS (2009) និងច្បាប់ និងបទប្បញ្ញត្តិប្រទេសកម្ពុជា

៤៧. ជាទូទៅ គោលការណ៍សំខាន់ៗនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ស្តីពីលទ្ធកម្មដីធ្លី ការផ្តល់សំណង ការផ្តល់ជំនួយ និងការតាំងទីលំនៅឡើងវិញ ឆ្លុះបញ្ចាំងពីខ្លឹមសារដែលមាននៅក្នុងគោលការណ៍ SPS របស់ ADB។ ការប្រៀបធៀបរវាងគោលការណ៍ SPS របស់ ADB និងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា ត្រូវបានបង្ហាញក្នុង **តារាងទី 1** ហើយដំណោះស្រាយ និងការបញ្ជាក់ដើម្បីបំពេញចន្លោះប្រហោងសំខាន់ៗត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF)។

## តារាងទី 1. ការវិភាគចន្លោះប្រហោង និងដំណើរស្រុះស្រួលគ្នារវាង គោលការណ៍ ADB-SPS (2009) និង SOP របស់រាជរដ្ឋាភិបាលកម្ពុជា

| លេខ | លក្ខខណ្ឌតម្រូវនៃ SPS របស់ ADB ស្តីពី IR និង SR-2 | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និតិវិធីប្រតិបត្តិការស្តង់ដារអប្បបរមា (SOP) ឆ្នាំ២០១៨ | គម្លាតរវាង ADB SPS និង SOP | ការបំភ្លឺ |
|---|---|---|---|---|
| ១ | ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការបញ្ចេញព័ត៌មាន<br>• អនុវត្តការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយ APs រួមទាំងក្រុមដែលងាយរងគ្រោះ (VGs) ភាគីពាក់ព័ន្ធ និងការបញ្ចេញព័ត៌មានស្តីពីសិទ្ធិទទួលបាន និងជម្រើសនៃការតាំងលំនៅថថ្មី។<br>• (VGs រួមមាន៖ អ្នកដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ អ្នកគ្មានដី ជនចាស់ជរា ស្រ្តីមេផ្ទះ ស្រ្តី និងកុមារ ជនជាតិដើមភាគតិច | • SOP នៅត្រង់ជំពូកទី IV និងក្រោមភារកិច្ចសំខាន់ៗ ក្នុងការរៀបចំផែនការតាំងលំនៅថ្មីជាមូលដ្ឋាន ការលើកឡើងអំពីការពិគ្រោះយោបល់ជាកិច្ចការមួយក្នុងចំណោមកិច្ចការដែលមានគោលបំណងពាំនាំការយល់ដឹងអំពីគម្រោងនេះទៅដល់សហគមន៍ដែលរងផលប៉ះពាល់ ហើយជូនដំណឹងពួកគេអំពីការសម្រេបដែលអាចកើតមាន និងស្វែងរកមតិកែលម្អរបស់ពួកគេ។<br>• នៅក្នុងជំពូកទី V ក្រោមភារកិច្ចសំខាន់ៗនៅក្នុងផែនការតាំងទីលំនៅថ្មីលម្អិតដែលបានធ្វើបច្ចុប្បន្នកម្ម បន្ទាប់ពីការរចនាលម្អិត) ការលើកឡើងអំពីការពិគ្រោះយោបល់ជាកិច្ចការមួយក្នុងចំណោមភារកិច្ចដែលមានគោលបំណងជូនដំណឹងដល់ APs អំពីសិទ្ធិទទួលបាន និងវិធីសាស្រ្តនៃសំណង និងនីតិវិធី GRM ការលើកឡើងអំពីការរុះរើទីលំនៅទៅកន្លែងតាំងទីលំនៅថ្មី និងការពិគ្រោះ | • SOP ភាគច្រើនអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ SPS, 2009 ទោះបីជាយ៉ាងណាក៏ដោយ វាមិនបានលើកឡើងជាពិសេសអំពីការលាតត្រដាងពីម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន (EM) ដល់មនុស្សគ្រប់គ្នាក្នុងអំឡុងពេលពិគ្រោះយោបល់នោះទេ។ ទោះយ៉ាងណាក៏ដោយ វាបានលើកឡើងថា BRP/RP និង DRP/UDRP ត្រូវបានលាតត្រដាងនៅការិយាល័យឃុំសម្រាប់ការបង្ហាញដល់សហគមន៍ដែលរងផលប៉ះពាល់។ EM គឺជាផ្នែកសំខាន់មួយប្រសិនបើឯកសារទាំងនេះត្រូវបានលាតត្រដាងដល់សហគមន៍ដែលរងផលប៉ះពាល់។.ចំណុចនេះត្រូវបានពន្យល់យ៉ាងលម្អិតនៅក្នុងឧបសម្ព័ន្ធទី 7 ដោយបានចង្អុលបង្ហាញយ៉ាងច្បាស់ថា EM និងការភ្ជាប់នៅក្រោម EM ត្រូវបានពន្យល់ដល់ AH នីមួយៗ | ការបំភ្លឺមួយចំនួនដែលបានស្នើឡើង រួមមាន៖<br>• ព័ត៌មានលំអិតផ្ទាល់ខ្លួនរបស់អ្នកដែលត្រូវផ្លាស់ទី និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ និងព័ត៌មានរសើបផ្សេងទៀតដែលប៉ះពាល់ដល់ឯកជនភាពរបស់ពួកគេ នឹងមិនត្រូវបានបង្ហាញជាដាច់ខាត។<br>• របាយការណ៍ត្រួតពិនិត្យ RPs/RPs/ការតាំងទីលំនៅថ្មី ដែលបានធ្វើបច្ចុប្បន្នកម្ម រួមមានសេចក្តីសង្ខេបនៃការពិគ្រោះយោបល់ជាមួយ AP (រួមទាំង VGs) ពេញមួយវដ្តនៃគម្រោង។<br>• របាយការណ៍ត្រួតពិនិត្យការតាំងទីលំនៅថ្មី/RPs/RPs/ដែលបានធ្វើបច្ចុប្បន្នកម្មរួច ត្រូវបានលាតត្រដាងនៅលើគេហទំព័ររបស់ ADB និងត្រូវបានបកប្រែជាភាសាខ្មែរទុកនៅការិយាល័យឃុំ-សង្កាត់ផងដែរ។<br>• SOP កថាខ័ណ្ឌ ១២០; ព័ត៌មានទូទៅសម្រាប់ PIB រួមមានគោលនយោបាយសំណង (សិទ្ធិទទួលបាន) ដូចមានចែងក្នុងកថាខណ្ឌ 119។ |

| លេខ | លក្ខខណ្ឌតម្រូវនៃ SPS របស់ ADB ស្តីពី IR និង SR-2 | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និតិវិធីប្រតិបត្តិការស្តង់ដារអេប្បបរមា (SOP) ឆ្នាំ២០១៨ | គម្លាតរវាង ADB SPS និង SOP | ការបំភ្លឺ |
|---|---|---|---|---|
| | និងអ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់)។<br><br>• *ដើម្បីអនុលោមតាមគោលការណ៍ ADB SPS IR 2, 9, 12 (ទំព័រ 17), កថាខណ្ឌ 54 (ទំព័រ 20), កថាខណ្ឌទី 73 (ទំព័រ 26), ឧបសម្ព័ន្ធទី 2, កថាខណ្ឌទី 18 (ទំព័រ 47), កថាខណ្ឌ 26, 27, 28 ( ទំព័រ 49)* | យោបល់ពីផ្ទះមួយទៅផ្ទះមួយ ដើម្បីបញ្ជាក់ការស្ទង់មតិ។<br>• ជំពូក VIII នៃ SOP ពិពណ៌នាលម្អិតអំពីតម្រូវការសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ ការចូលរួម និងការបញ្ចេញព័ត៌មាន។ នៅក្នុងកថាខណ្ឌ 126 ចែងថា ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងពេញមួយវដ្តនៃគម្រោង។ | ក្នុងអំឡុងពេលពិគ្រោះយោបល់ពីគ្រួសារមួយទៅផ្ទះមួយ។<br>• ជាមួយគ្នានេះដែរ ពុំមានការលើកឡើងអំពីការលាត្រដាងរបាយការណ៍ត្រួតពិនិត្យឡើយ។ SOP មិនលើកឡើងដោយឡែកអំពីការយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី និងក្រុមដែលងាយរងគ្រោះសម្រាប់ការដាក់បញ្ចូលពួកគេក្នុងអំឡុងពេលពិគ្រោះយោបល់ទេ។ | • កិច្ចប្រជុំពិគ្រោះយោបល់ជាក់លាក់ចំនួនបួនត្រូវបានលើកឡើងនៅក្នុង SOP ប៉ុន្តែដោយសារតែនៅក្នុង SOP បានបញ្ជាកក់ថា ការពិគ្រោះយោបល់បាន នឹង ជាដំណើរការបន្តនៅទូទាំងការអនុវត្តគម្រោង។<br>• បុគ្គលិក ADB អាចចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់។<br>• កិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើងដើម្បីពិគ្រោះជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដែលងាយរងគ្រោះ (ដូចបានកំណត់ក្នុងកថាខណ្ឌ 53-55) ហើយនឹងត្រូវធ្វើឡើងពេញមួយវដ្តគម្រោង។ |
| ២ | យន្តការដោះស្រាយបណ្តឹងតវ៉ា៖<br>• បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ាដែលងាយស្រួលយល់ ងាយស្រួលអនុវត្តបាន នីតិវិធីតម្លាភាព ការឆ្លើយតបយេនឌ័រ និងសមស្របតាមវប្បធម៌។ | ជំពូកទី IX នៃ SOP លើកឡើងអំពីយន្តការដោះស្រាយបណ្តឹងតវ៉ា៖<br>• យន្តការ GRM ត្រូវបានបង្កើតឡើងជាការរៀបចំមូលដ្ឋាននៅថ្នាក់ខេត្តសម្រាប់ទទួល កត់ត្រា វាយតម្លៃ និងសម្របសម្រួលការដោះស្រាយពាក្យបណ្តឹង និងការទាមទារតវ៉ា ដែលបានលើកឡើងដោយអ្នករងផលប៉ះពាល់ ទាក់ទងនឹងសំណង និងសិទ្ធិទទួលបានរបស់គេក្នុង | | • ស្ថានភាពនៃបណ្តឹងនៅថ្នាក់ឃុំ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ត្រួតពិនិត្យតាមកាលកំណត់ និងដាក់ជូនទៅ ADB ។<br>• ឧបសម្ព័ន្ធ 8.2 ស្តីពីការចុះបញ្ជីពាក្យបណ្តឹង ទោះបីជាយ៉ាងណាក៏ដោយ នៅពេលរាយការណ៍ស្ថានភាពនៃពាក្យបណ្តឹង នឹងត្រូវបានរួមបញ្ចូលផងដែរ។ |

| លេខ | លក្ខខណ្ឌតម្រូវនៃ SPS របស់ ADB ស្តីពី IR និង SR-2 | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និតិវិធីប្រតិបត្តិការស្តង់ដារអេប្បបរមា (SOP) ឆ្នាំ២០១៨ | គម្លាតរវាង ADB SPS និង SOP | ការបំភ្លឺ |
|---|---|---|---|---|
| | *ដើម្បីអនុលោមតាមគោលការណ៍ ADB SPS IR 2 (ទំព័រ 17), កថាខណ្ឌ 59, 60 (ទំព័រ 22), ឧបសម្ព័ន្ធទី 2, កថាខណ្ឌ 29 (ទំព័រ 49)* | ការដកហូតដីធ្លី និងអចលនវត្ថុផ្សេងទៀតក្រោមច្បាប់ស្តីពីអស្សាមិករណ៍។ | | |
| ៣ | សំណងនិងជំនួយ៖<br>• ផ្តល់ជូន APs នូវសំណង និងជំនួយទាំងរូបវន្ត និងសេដ្ឋកិច្ចដែលត្រូវការ។<br><br>*ដើម្បីអនុវត្តតាមគោលការណ៍គោលនយោបាយ ADB SPS 3, 4, 5, 7 (ទំព័រ 17) និងឧបសម្ព័ន្ធទី 2 កថាខណ្ឌទី 7, 8, 9,10 (ទំព័រ 45), 11 និង 12* | • SOP រួមបញ្ចូលសំណង និងប្រាក់ឧបត្ថម្ភលើការផ្ទេរ/រុះរើ ដល់ APs នៅក្នុងសិទ្ធិទទួលបានរបស់ខ្លួន។<br>• SOP មានបទប្បញ្ញត្តិសម្រាប់ដីផ្លាស់ប្តូរទីលំនៅ (សម្រាប់ APs ដែលមានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លី) និងស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន ពោលគឺលទ្ធភាពទទួលបានដីរបស់រដ្ឋ។ នេះមិនអនុវត្តចំពោះអ្នករស់នៅ ឬអ្នកចូលមករស់នៅដោយខុសច្បាប់។<br>• SOP មានបទប្បញ្ញត្តិសម្រាប់ការស្តារជីវភាពឡើងវិញសម្រាប់ DPs ទាំងអស់ (កំណត់ចំពោះការជ្រើសរើសកម្មវិធី 1 ក្នុង | | • ប្រាក់ឧបត្ថម្ភអន្តរកាល SOP EM 2b សមស្របនឹងពេលវេលាដែលត្រូវផ្លាស់ប្តូរទីតាំងអាជីវកម្ម ប៉ុន្តែដើម្បីបង្កើតអាជីវកម្មឡើងវិញគឺស្មុគស្មាញជាង ហើយត្រូវការពេលវេលាច្រើនជាងការរុះរើទីតាំង។<br>• ការស្តារឡើងវិញនូវជីវភាពរស់នៅ នឹងមានភាពសមស្របជាមួយផលប៉ះពាល់ដែលបានវាយតម្លៃក្នុងអំឡុងពេលការស្ទង់មតិសេដ្ឋកិច្ចសង្គម DMS ជាមួយ APs ។<br>• សម្រាប់ក្រុមដែលងាយរងគ្រោះ លើកលែងតែអ្នកចូលមករស់នៅដោយខុសច្បាប់ការផ្តល់សិទ្ធិទទួលបានលំនៅដ្ឋាន និងប្រភពចំណូលគ្រប់គ្រាន់ស្របច្បាប់ និងសមរម្យ។<br>• អត្រាវាយតម្លៃមានសុពលភាពក្នុងរយៈពេល |

| លេខ | លក្ខខណ្ឌតម្រូវនៃ SPS របស់ ADB ស្តីពី IR និង SR-2 | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និតិវិធីប្រតិបត្តិការស្តង់ដារអេប្បបរមា (SOP) ឆ្នាំ២០១៨ | គម្លាតរវាង ADB SPS និង SOP | ការបំភ្លឺ |
|---|---|---|---|---|
| | *(ទំព័រ 46), 16 និង 17 (ទំព័រ 47 )* | ចំណោម 3 កម្មវិធីដែលបានកំណត់ជាមុន)។<br>• SOP មានបទប្បញ្ញត្តិសម្រាប់ការផ្តល់ទីតាំងផ្លាស់ប្តូរដល់ DPs ដែលមានសិទ្ធិ ដែលត្រូវបានជ្រើសរើសតាមទីតាំងដែលអាចរកបាននូវសេវាសង្គមជាមូលដ្ឋាន និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ អាស្រ័យលើភាពអាចរកបាននៃដីក្នុងតម្លៃសមរម្យ និងលទ្ធភាពទទួលបានដីរបស់រដ្ឋនៅជិតតំបន់គម្រោង។ | | មួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការព្រមព្រៀងលើរបាយការណ៍ RCS ដោយ IRC ហើយក្រោយមកបានធ្វើបច្ចុប្បន្នកម្ម។<br>• អ្នករងផលប៉ះពាល់ដែលមានសិទ្ធិស្របច្បាប់ទាំងប្លង់រឹង និងទន់ ត្រូវបានចាត់ទុកថាមានសិទ្ធិដូចគ្នា។ |
| ៤ | • នីតិវិធីសម្រាប់ការចរចារ<br>• បង្កើតនីតិវិធីក្នុងលក្ខណៈតម្លាភាព ស៊ីសង្វាក់គ្នា និងសមធម៌ ប្រសិនបើការទិញដីធ្វើឡើង តាមរយៈការចរចារ<br>*ដើម្បីអនុវត្តតាមគោលការណ៍របស់ ADB SPS IR គោលការណ៍ទី 6 (ទំព័រ 17) កថាខណ្ឌ* | ជំពូក-X (ផ្នែក-ខ) នៃ SOP ចែងថា ក្នុងករណីការទិញដីឯកជនដែលអ្នកលក់សុខចិត្តលក់ ហើយអ្នកទិញសុខចិត្តទិញដោយស្ម័គ្រចិត្តបែបនេះអាចទទួលបានក្រោមកិច្ចសន្យាពាណិជ្ជកម្ម។ តម្លៃនឹងត្រូវបានចរចាគ្នាជាផ្នែកនៃបទដ្ឋានពាណិជ្ជកម្ម។ | | ១. សម្រាប់ករណីលក់ទិញដោយស្ម័គ្រចិត្ត (កន្លែងដែលអស្សាមកម្មនឹងមិនត្រូវបានប្រើ) ADB នឹងមានសិទ្ធិពិនិត្យមើលឯកសារទាំងអស់សម្រាប់ផ្ទៀងផ្ទាត់នៅនឹងកន្លែងនៅអគ្គនាយកដ្ឋាន GDR ។ ប្រសិនបើកិច្ចព្រមព្រៀងទិញលក់ដោយស្ម័គ្រចិត្ត មិនអាចសម្រេចបានទេ ទីតាំងជំនួសនឹងត្រូវបានជ្រើសរើស។<br>២. នៅពេលដែលដំណោះស្រាយដោយការចរចាត្រូវបានអនុវត្តជំនួសឱ្យការទិញយកដីបែបកំហិតដោយផ្អែកលើតម្រូវការ SR 2 កថាខណ្ឌ 25 នឹងត្រូវអនុវត្តតាម ដោយចងក្រងទុកជាឯកសារ និងពិពណ៌នានៅក្នុងផែនការតាំងទីលំនៅថ្មី និង |

| លេខ | លក្ខខណ្ឌតម្រូវនៃ SPS របស់ ADB ស្តីពី IR និង SR-2 | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មី ដោយមិនស្ម័គ្រចិត្ត និតិវិធីប្រតិបត្តិការស្តង់ដារអប្បបរមា (SOP) ឆ្នាំ២០១៨ | គម្លាតរវាង ADB SPS និង SOP | ការបំភ្លឺ |
|---|---|---|---|---|
| | *73 (ទំព័រ 26)*<br>*ឧបសម្ព័ន្ធទី 2 កថាខណ្ឌ 25 (ទំព័រ 48-49)* | | | ព័ត៌មាននៃការចរចាដែលមានក្នុងរបាយការណ៍ត្រួតពិនិត្យ។<br>• ការចរចានឹងផ្តល់តម្លៃសមរម្យ និងយុត្តិធម៌សម្រាប់ដី/ឬទ្រព្យសម្បត្តិផ្សេងទៀត។<br>• ត្រូវប្រាកដថាការចរចាណាមួយជាមួយអ្នកដែលត្រូវផ្លាស់ទី បានដោះស្រាយដោយបើកចំហនូវហានិភ័យនៃភាពមិនស៊ីសង្វាក់គ្នាលើព័ត៌មាន និងអំណាចចរចារបស់ភាគីពាក់ព័ន្ធក្នុងប្រតិបត្តិការបែបនេះ។<br>• និតិវិធីដោះស្រាយដោយការចរចា នឹងអនុវត្តតាមកថាខណ្ឌទី 25 នៃឧបសម្ព័ន្ធទី 2 នៃ SPS ហើយបានការព្រមព្រៀងពី ADB ។ |
| ៥ | គ្រួសារដែលរងផលប៉ះពាល់ (គ្មានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិដែលអាចទទួលស្គាល់បានលើការកាន់កាប់ដី)<br>• ធានាថា APs ដែលគ្មានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិស្របច្បាប់ដែលអាចទទួលស្គាល់បាន | ជំពូកទី VII៖<br>• ផ្នែក ខកថាខ័ណ្ឌ ១០៤ លើកឡើងថា៖<br>• គ្មានការផ្តល់សំណងចំពោះអ្នកដែលត្រូវផ្លាស់ទីដែលកាន់កាប់ដីដែលជាដីចំណីផ្លូវរបស់រដ្ឋ (ROW) ។<br>ផ្នែក គ នៃ SOP លើកឡើងថា៖ | ការបំភ្លឺចាំបាច់ពីរបៀបដែលអ្នកដែលរងផលប៉ះពាល់ក្រីក្រ និងងាយរងគ្រោះត្រូវបានផ្តល់សិទ្ធិទទួលបានដីធ្លីស្របច្បាប់ និងតម្លៃសមរម្យ។ | • សម្បទានដីសង្គមកិច្ចមិនមែនជាសិទ្ធិទទួលបានទេ។ ទោះជាយ៉ាងណាក៏ដោយ IRC អាចគ្រាន់តែជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធនិងសមត្ថកិច្ចអំពីជនក្រីក្រ និងគ្រួសារគ្មានដីដែលរងផលប៉ះពាល់ដែលអាចមានសិទ្ធិស្នើសុំសម្បទានដីសង្គមកិច្ចពីរដ្ឋ។ លក្ខណៈវិនិច្ឆ័យនៃការផ្តល់សម្បទានដីសង្គមកិច្ចនឹងត្រូវបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ ការសម្រេចផ្តល់សម្បទានដីសង្គមកិច្ច ក៏នឹងធ្វើឡើង |

| លេខ | លក្ខខណ្ឌតម្រូវនៃ SPS របស់ ADB ស្តីពី IR និង SR-2 | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មី ដោយមិនស្ម័គ្រចិត្ត និតិវិធីប្រតិបត្តិការស្តង់ដារអេប្បបមា (SOP) ឆ្នាំ២០១៨ | គម្លាតរវាង ADB SPS និង SOP | ការបំភ្លឺ |
|---|---|---|---|---|
| | អាចមានសិទ្ធិទទួលបានជំនួយសម្រាប់ការតាំងទីលំនៅឡើងវិញ និងសំណងសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិមិនមែនដី។<br><br>*ដើម្បីអនុវត្តតាមគោលការណ៍ ADB SPS IR 2, 5, 7 (ទំព័រ 17) ឧបសម្ព័ន្ធទី 2 កថាខណ្ឌទី 9 ទី 11 ទី 12 ទី 16 និងទី 17 (ទំព័រ 45, 46 និង 47* | • សិទ្ធិទទួលបានសំណងដល់អ្នកដែលរងផលប៉ះពាល់ភាគច្រើន អាស្រ័យទៅលើភាពស្របច្បាប់នៃការកាន់កាប់ ឬកម្មសិទ្ធិលើដី និងទ្រព្យសម្បត្តិផ្សេងទៀតនៅកាលបរិច្ឆេទឱសានវាទ។ ប្រភេទអ្នកដែលត្រូវផ្លាស់ទីខាងក្រោមមានសិទ្ធិទទួលបានសំណង ប៉ុន្តែសំណងនឹងប្រែប្រួលអាស្រ័យលើស្ថានភាពរបស់ពួកគេ៖<br>• កម្មសិទ្ធិករស្របច្បាប់ និងអ្នកមានប័ ណ្ណកម្មសិទ្ធិ ឬមានសិទ្ធិប្រើប្រាស់ដីរួមទាំងសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី<br>• អ្នកជួលដី និង ឬអ្នកបង់រំលោះ រួមទាំងនិយោជិត កម្មករ អ្នកលក់ដូរ។<br>• អ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិលើដី (អ្នកកាន់កាប់ខុសច្បាប់) ដែលប្រកបរបរកសិកម្ម ឬអាជីវកម្ម។<br>• ក្រុមក្រីក្រ និងងាយរងគ្រោះ។ | | តាមធន្ទានុសិទ្ធិតែមួយគត់របស់អាជ្ញាធរពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិរបស់កម្ពុជាស្តីពីសម្បទានដីសង្គមកិច្ច។<br>• អគ្គនាយកដ្ឋាន GDR នឹងផ្តល់ព័ត៌មានប្រសិនបើមានកម្មវិធីសម្បទានដីសង្គមកិច្ចដែលមាននៅក្នុងតំបន់គម្រោងនៅក្នុងរបាយការណ៍ត្រួតពិនិត្យរបស់ខ្លួន។ |

ប្រភព៖ ឯកសារជំនួយស្មារតី (ឯកសាជូនភ្ជាប់ទី ៣) នៃបេសកកម្មកិច្ចសន្ទនាស្តីពីគោលនយោបាយការពារ ដែលបានធ្វើឡើងនៅថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០១៩

## គ. ការពិនិត្យពិច័យលើអនុគម្រោង និងការចាត់ថ្នាក់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត

៤៨. គោលការណ៍ ADB-SPS (ឆ្នាំ២០០៩) ចាត់ថ្នាក់គម្រោង/អនុគម្រោង និងសកម្មភាពរបស់វាទៅជាប្រភេទនៃការគាំពារសង្គម។ ការពិនិត្យពិច័យលើសកម្មភាពនានា អាចកំណត់បានទាំងសារៈសំខាន់ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលអាចកើតមានលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (IR)។ ផលប៉ះពាល់អវិជ្ជមាន ត្រូវបានពិនិត្យឡើងវិញ ហើយការរចនាគម្រោង/អនុគម្រោងត្រូវបានកែសម្រួលតាមលទ្ធភាពដែលអាចធ្វើបាន ដូច្នេះផលប៉ះពាល់ទាំងនោះអាចត្រូវបានបញ្ចៀស ហើយប្រសិនបើមិនអាចបញ្ចៀសបាន គឺត្រូវកាត់បន្ថយវាឱ្យនៅត្រឹមកម្រិតអប្បបរមា។ អនុគម្រោងទាំងអស់នឹងត្រូវបានពិនិត្យពិច័យ និងចាត់ថ្នាក់ក្រោមក្របខ័ណ្ឌគម្រោង ដោយប្រើទម្រង់បញ្ជីត្រួតពិនិត្យការចាត់ថ្នាក់ IR ដែលមាននៅក្នុង **ឧបសម្ព័ន្ធទី** 1 នៃក្របខ័ណ្ឌ RF នេះ។ ប្រភេទ IR របស់អនុគម្រោងនីមួយៗគឺត្រូវកំណត់ដោយប្រភេទនៃសមាសភាគរសើបបំផុតទាក់ទងនឹងផលប៉ះពាល់របស់វា ហើយត្រូវបានណែនាំដោយ
លក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងទំព័រទី ៣ នៃ នៃផ្នែកទី ១៩ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងរបស់ ADB F1/OP [6] ។

៤៩. អនុគម្រោងដែលមានផលប៉ះពាល់ខ្លាំងដល់ IR (ប្រភេទ A) និងអ្នកដែលត្រូវផ្លាស់ទីជារូបវន្ត ឬជនជាតិដើមភាគតិចដែលត្រូវផ្លាស់ទី នឹងមិនមានសិទ្ធិទទួលបានការគាំទ្រក្រោមក្របខ័ណ្ឌគម្រោងបែបនេះទេ។ មានតែអនុគម្រោងដែលមានផលប៉ះពាល់ IR តិចតួច (ប្រភេទ B) ឬគ្មានផលប៉ះពាល់ IR សោះ (ប្រភេទ C) នឹងមានសិទ្ធិទទួលបានការគាំទ្រក្រោមក្របខ័ណ្ឌគម្រោង។

- សម្រាប់អនុគម្រោងដែលពាក់ព័ន្ធនឹង IR (ប្រភេទ B) តម្រូវឱ្យមានការរៀបចំជាផែនការដោះស្រាយផលប៉ះពាល់លម្អិត(DRP) ស្របគ្នាជាមួយនឹងវិសាលភាព និងកម្រិតនៃផលប៉ះពាល់ ដូចដែលបានពិពណ៌នានៅក្នុងក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF) នេះ ប៉ុន្តែមិនធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារ និងបញ្ហាដែលបានកំណត់ដែលត្រូវដោះស្រាយនៅក្នុង DRP ស្របតាលក្ខខណ្ឌតម្រូវនៃ ADB SPS (ឆ្នាំ២០០៩) [6] ។
- អនុគម្រោងប្រភេទ C នឹងត្រូវឆ្លងកាត់ការយកចិត្តទុកដាក់ខ្ពស់ មុនពេលត្រូវបានបញ្ជាក់ជាយថាហេតុក្រោមប្រភេទប្រធានបទគម្រោម។

---

[6] DRP នឹងត្រូវបានរៀបចំដោយ GDR នឹងគាំទ្រដល់អ្នកជំនាញដោះស្រាយផលប៉ះពាល់ដែលចូលរួមដោយ EA ក្រោមក្របខ័ណ្ឌគម្រោងនេះ។ DRP នឹងត្រូវបានអនុម័តដោយ IRC និងជម្រះដោយ ADB ។

៥០. វិធានការនានានឹងត្រូវអនុវត្តការដើម្បីបញ្ចៀស ឬយ៉ាងហោចណាស់កាត់បន្ថយផលប៉ះពាល់នៃការតាំងលំនៅជាថ្មី ដោយពិចារណាលើជម្រើសដែលអាចមាន និង/ឬការកែតម្រូវលើការរៀបចំ។ល។

## ឃ. លទ្ធភាពទទួលបាន និងសិទ្ធិទទួលបាន

### ១. លទ្ធភាពទទួលបាន

៥១. លទ្ធភាពទទួលបាន នឹងត្រូវបានកំណត់ទាក់ទងនឹងកាលបរិច្ឆេទឱសានវាទ ដែលនឹងត្រូវបានកំណត់អំឡុងពេលធ្វើសារពើភ័ណ្ឌនៃការខាតបង់ (IOL) និងការជំរឿនអ្នករងផលប៉ះពាល់ ដែលត្រូវបញ្ជាក់សុពលភាព និងអះអាងក្នុងអំឡុងពេលធ្វើអង្កេតវាស់វែងលម្អិត (DMS) នៅដំណាក់កាលរចនាប្លង់វិស្វកម្មលម្អិត (DED)។ អ្នករងផលប៉ះពាល់ទាំងអស់ដែលបានកំណត់នៅក្នុងរបៀងនៃផលប៉ះពាល់ (COI) របស់អនុគម្រោង គិតត្រឹមកាលបរិច្ឆេទឱសានវាទ នឹងមានលទ្ធភាពទទួលបានសំណង និងជំនួយសម្រាប់ការតាំងទីលំនៅថ្មី។ ព័ត៌មានអំពីកាលបរិច្ឆេទឱសានវាទ នឹងត្រូវចងក្រងជាឯកសារ និងផ្សព្វផ្សាយពាសពេញតំបន់អនុគម្រោង តាមរយៈការបិទផ្សាយនៅលើផ្ទាំងប៉ាណូជូនដំណឹងឃុំ-សង្កាត់ និងតាមវត្តអារាមនានា។ អ្នកដែលទន្ទ្រានចូលទៅក្នុងតំបន់ដែលបានស្ទង់មតិជាពិសេសនៅក្នុងរបៀងនៃផលប៉ហពាល់ (COI) បន្ទាប់ពីកាលបរិច្ឆេទឱសានវាទ ដោយមិនគិតពីស្ថានភាពនៃភាពងាយរងគ្រោះរបស់ពួកគេ នឹងមិនអាចទទួលបានសំណង ឬជំនួយផ្សេងទៀតទេ លុះត្រាតែមានការផ្លាស់ប្តូរនៅក្នុងការរចនាអនុគម្រោង។ ដូចគ្នានេះដែរ ការផ្លាស់ប្តូរ ឬការកែលម្អណាមួយចំពោះទ្រព្យសកម្មដែលមានស្រាប់ កាលបរិច្ឆេទឱសានវាទ នឹងមិនត្រូវបានរាប់បញ្ចូល ឬផ្តល់សំណងឡើយ។

៥២. អ្នកដែលត្រូវផ្លាស់ទីពីតំបន់អនុគម្រោងណាមួយ ត្រូវបានបែងចែកជាបីប្រភេទ៖ (១). អ្នកដែលមានសិទ្ធិស្របច្បាប់ជាផ្លូវការលើដីធ្លី (ប័ណ្ណកម្មសិទ្ធិ) ដែលត្រូវបាត់បង់ទាំងស្រុង ឬមួយផ្នែកនៃដីរបស់ខ្លួន, (២). អ្នកដែលបាត់បង់ដីទាំងស្រុង ឬមួយផ្នែកដែលខ្លួនកាន់កាប់ ហើយដែលមិនមានសិទ្ធិស្របច្បាប់ជាផ្លូវការចំពោះដីនោះ (ប័ណ្ណកម្មសិទ្ធិ) ប៉ុន្តែមានសិទ្ធិទាមទារដីទាំងនោះដែលត្រូវបានទទួលស្គាល់ ឬដែលទទួលស្គាល់ក្រោមច្បាប់កម្ពុជា ,និង (៣). អ្នកដែលបាត់បង់ដីទាំងស្រុង ឬមួយផ្នែកដែលខ្លួនកាន់កាប់ ហើយដែលមិនមានសិទ្ធិស្របច្បាប់ជាផ្លូវការ (ប័ណ្ណកម្មសិទ្ធិ) ឬមិនមានការទទួលស្គាល់ ឬមិនមានការទាមទារដែលត្រូវបានទទួលស្គាល់ចំពោះដីនោះ។

៥៣. អ្នកដែលត្រូវផ្លាស់ទី ដូចបានរៀបរាប់ក្នុងចំណុច (១) និង (២) ខាងលើនេះ ត្រូវបានផ្តល់ឱ្យនូវដីជំនួស ឬសំណងជាសាច់ប្រាក់ ក្នុងតម្លៃជំនួសពេញលេញសម្រាប់ដីដែលពួកគេបាត់បង់ ការទូទាត់សម្រាប់ទ្រព្យសកម្មមិនមែនដីដែលរងផលប៉ះពាល់ដោយផ្នែក ឬទាំងស្រុងដែលខ្លួនមាន និងជំនួយសម្រាប់ការតាំងទីលំនៅថ្មី ជាសាច់ប្រាក់ ឬជាសន្ដានចិត្ត។ ចំណែកអ្នកដែលត្រូវផ្លាស់ទី ដូចបានរៀបរាប់ក្នុងចំណុច (៣) ត្រូវបានផ្តល់សំណងក្នុងតម្លៃជំនួសពេញលេញសម្រាប់ទ្រព្យសកម្មមិនមែនដីដែលខ្លួនមាន និងសម្រាប់ការកែលម្អដែលពួកគេបានធ្វើនៅលើដីនោះ និងជំនួយសម្រាប់ការតាំងទីលំនៅថ្មី ប្រសិនបើពួកគេកាន់កាប់តំបន់អនុគម្រោង មុនកាលបរិច្ឆេទឱសានវាទនៃអនុគម្រោង។ អ្នកដែលត្រូវផ្លាស់ទី ដែលកាន់កាប់តំបន់អនុគម្រោងបន្ទាប់ពីកាលបរិច្ឆេទឱសានវាទ នឹងមិនមានសិទ្ធិទទួលបានសំណង ឬជំនួយណាមួយឡើយ។

## ២. សិទ្ធិទទួលបាន

៥៤. សិទ្ធិទទួលបាន គឺផ្អែកលើសិទ្ធិដែលអាចទទួលបាននៅចំកាលបរិច្ឆេទឱសានវាទ ស្របតាមគោលការណ៍ និងគោលនយោបាយស្តីពីការផ្តល់សំណង ការកាត់បន្ថយ និងលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដូចដែលបានកំណត់ដោយគម្រោង។ សំណងទាំងអស់សម្រាប់ទ្រព្យសកម្មដែលរងផលប៉ះពាល់ នឹងផ្អែកលើគោលការណ៍នៃតម្លៃជំនួសពេញលេញ ស្របតាមលក្ខខណ្ឌតម្រូវនៃ ADB-SPS (ឆ្នាំ២០០៩)[7]។ ដើម្បីអនុវត្តការសិក្សាតម្លៃជំនួស (RCS) អគ្គនាយកដ្ឋាន GDR នឹងជ្រើសរើសអ្នកវាយតម្លៃឯករាជ្យដែលមានជំនាញវិជ្ជាជីវៈ (ទីប្រឹក្សា RCS) នៅក្នុងតំបន់អនុគម្រោងទាំងអស់ក្នុងអំឡុងពេល DMS ដើម្បីកំណត់អត្រាសំណងដែលឆ្លុះបញ្ចាំងពីតម្លៃទីផ្សារបច្ចុប្បន្នសម្រាប់ (១). ដីកសិកម្ម ដីលំនៅដ្ឋាន និងដីអាជីវកម្ម, (២). ប្រភេទផ្សេងគ្នានៃរចនាសម្ព័ន្ធដែលរងផលប៉ះពាល់, និង (៣). ដំណាំ និងដើមឈើ ការខាតបង់ផ្នែកអាជីវកម្ម ថ្លៃដឹកជញ្ជូន ប្រាក់ឧបត្ថម្ភសម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ អនុផលឈើ/របងឈើ រួមមាននៅក្រោមដំណាំ និងដើមឈើ។

៥៥. អត្រាវាយតម្លៃតាមការសិក្សាតម្លៃជំនួស (RCS) នៅក្នុងតំបន់អនុគម្រោងនឹងមានសុពលភាពរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការព្រមព្រៀងទៅលើ RCS ពីសំណាក់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ (IRC)[8] ហើយប្រសិនបើការផ្តល់ជូនសំណង និង/ឬជំនួយមិនត្រូវបានធ្វើឡើងសម្រាប់គ្រួសារដែលរងផលប៉ះពាល់ក្នុងរយៈពេលនេះ នោះតម្លៃជំនួសនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារជាក់ស្តែងនៅពេលនោះដោយទីប្រឹក្សា RCS ។ លទ្ធផលនៃ RCS នឹងជាមូលដ្ឋានសម្រាប់ការប៉ាន់ស្មានថវិកាសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការចំណាយសម្រាប់ការតាំងទីលំនៅថ្មី។

៥៦. នៅពេលដែលមិនមានលក្ខខណ្ឌទីផ្សារ ឬស្ថិតក្នុងដំណាក់កាលបង្កើត អ្នកទទួលរងផលប៉ះពាល់ សមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋាន នឹងត្រូវពិគ្រោះយោបល់គ្នាដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់ ដូចជាទាក់ទងនឹងប្រតិបត្តិការដីធ្លីថ្មីៗ តម្លៃដីតាមប្រភេទ ប័ណ្ណកម្មសិទ្ធិ ការប្រើប្រាស់ដី លទ្ធភាពរកបាននៃដីនៅក្នុងតំបន់អនុគម្រោង ក៏ដូចជាព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

## ខ. វិធីសាស្ត្រ និងជម្រើសនៃលទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត

៥៧. ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដូចខាងក្រោម៖

(១). ការទទួលបានដី តាមរយៈវិធីសាស្ត្រទិញ-លក់ដោយស្ម័គ្រចិត្ត (WBWS)

(២). ការទទួលបានដី តាមរយៈវិធីសាស្ត្រដោះស្រាយដោយការចរចា

---

[7] ឧបសម្ព័ន្ធ 2, ផ្នែករង ឃ. កថាខណ្ឌទី ១០, ទំព័រទី ៤៥, ADB SPS (ឆ្នាំ២០០៩).

[8] កថាខណ្ឌទី ១៨៦, ទំព័រទី ៥១, លទ្ធកម្មដីធ្លី និងនិតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (ឆ្នាំ ២០១៨)

(៣). ការទទួលបានដី តាមរយៈការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត។

៥៨. ប្រសិនបើគ្រួសារដែលរងផលប៉ះពាល់មានចំនួនតិចតួច ត្រង់ចំណុច (១) និងចំណុច (២) ខាងលើ នឹងត្រូវអនុវត្ត ហើយមិនតម្រូវឱ្យរៀបចំផែនការ DRP នោះទេ។ ប្រសិនបើគ្រួសារដែលរងផលប៉ះពាល់មានចំនួនច្រើន ចាំបាច់ត្រូវរៀបចំផែនការ DRP ក្រោមវិធីសាស្ត្រត្រង់ចំណុច (៣)។ ស្របពេលដែលមានក្របខ័ណ្ឌ RF ដែលពិពណ៌នាអំពីនីតិវិធីលម្អិតសម្រាប់ចំណុច (៣) និងបន្ទាប់ពីគោលការណ៍ ADB-SPS ឆ្នាំ២០០៩ និងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា វិធីសាស្ត្រនៃការទទួលបានដីត្រង់ចំណុច (១) និង (២) ត្រូវអនុម័តដូចខាងក្រោម៖

## ១. **វិធីសាស្ត្រទិញ-លក់ដោយស្ម័គ្រចិត្ត** (WBWS)

៥៩. វិធីសាស្ត្រទិញ-លក់ដោយស្ម័គ្រចិត្ត (WBWS) អាចប្រព្រឹត្តទៅនៅកន្លែងដែលទីផ្សារដីកំពុងដំណើរការ ឬកំពុងប្រតិបត្តិការ ដោយមានការព្រមព្រៀងពីអ្នកលក់ ហើយអ្នកលក់ទទួលបានតម្លៃស្របនឹងតម្លៃទីផ្សារដែលកំពុងមានជាក់ស្តែង។ ប៉ុន្តែវិធីសាស្ត្រនេះ មិនត្រូវបានអនុវត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងឡាយណាដែលមានអ្នករងផលប៉ះពាល់ចំនួនច្រើន ឬចំពោះទីកន្លែងណាដែលគ្មានជម្រើសក្នុងកំណត់ជាទីតាំងនៃហេដ្ឋារចនាសម្ព័ន្ធក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងនោះទេ។ ក្នុងអំឡុងពេលនៃការរៀបចំក្របខ័ណ្ឌ RF សម្រាប់ SCMF គឺមិនមានគ្រួសារដែលរងផលប៉ះពាល់ណាមួយត្រូវបានរកឃើញ ឬត្រូវបានរំពឹងថានឹងត្រូវអនុវត្តវិធីសាស្ត្រ WBWS នេះទេ។ ចំណុចនេះ នឹងត្រូវពិនិត្យសារជាថ្មីឡើងវិញក្នុងអំឡុងពេលអនុវត្តគម្រោងជាកើស្តែង ប៉ុន្តែទំនងជាមិនមានការផ្លាស់ប្តូរអ្វីគួរឱ្យកត់សម្គាល់នោះឡើយ។ ក្នុងករណីត្រូវអនុវត្តវិធីសាស្ត្រ WBWS ចាំបាច់ត្រូវអនុវត្តតាមដំណើរការដូចខាងក្រោម៖

(១). អគ្គនាយកដ្ឋាន GDR នឹងធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាភាសាដែលអាចយល់បានជាមួយគ្រួសារដែងរងផលប៉ះពាល់ ដើម្បីធានាថាពួកគេត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីគម្រោង/អនុគម្រោង អត្ថប្រយោជន៍របស់វា ដីដែលត្រូវការសម្រាប់គម្រោង/អនុគម្រោង គោលនយោបាយដោះស្រាយផលប៉ះពាល់ ច្បាប់ និងបទប្បញ្ញត្តិ សិទ្ធិទទួលបាន និងសំណងក្នុងការចំណាយលើការជំនួសពេញលេញតាមអត្រាទីផ្សារបច្ចុប្បន្ន។ អគ្គនាយកដ្ឋាន GDR នឹងពិភាក្សាជាមួយគ្រួសារដែលរងផលប៉ះពាល់ (AHs) ទាំងអស់ អំពីឆន្ទៈ (ភាពស្ម័គ្រចិត្ត) របស់ពួកគេក្នុងការលក់ដីសម្រាប់ការសាងសង់គម្រោង/អនុគម្រោង និងទទួលបានការព្រមព្រៀងពីពួកគេជាមុន។

(២). អគ្គនាយកដ្ឋាន GDR នឹងដឹកនាំធ្វើ DMS និង RCS ដើម្បីកំណត់សារពើភ័ណ្ឌនៃការខាតបង់ និងតម្លៃជំនួស។

((៣). ការធ្វើ RCS នឹងអាចគណនាតម្លៃទីផ្សារនៃដីដែលនឹងត្រូវទិញ ឬលក់។

(៤). ប្រសិនបើមានការបាត់បង់ប្រាក់ចំណូល ទីប្រឹក្សា RCS នឹងគណនាចំនួននៃការខាតបង់ដោយផ្អែកលើម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន (EM) ដែលភ្ជាប់ជាមួយក្របខ័ណ្ឌ RF នេះ។

(៥). ក្នុងករណីបាត់បង់ដើមឈើហូបផ្លែ ទីប្រឹក្សា RCS នឹងគណនាការខាតបង់ផ្នែកសេដ្ឋកិច្ចដោយផ្អែកលើបក្កភាព និងរូបមន្តដែលបានបង្ហាញនៅក្នុង EM ។

(៦). ប្រសិនបើមានការផ្លាស់ទីជារូបវន្ត ប្រាក់ឧបត្ថម្ភអន្តរកាលនឹងត្រូវបានផ្តល់ជូនតាមអត្រាដែលបានបង្ហាញនៅក្នុង EM ។

(៧). ចំនួនទឹកប្រាក់សរុបនៃសំណងនឹងត្រូវបានគណនា និងផ្តល់ជូនជាចំនួនដុំមួយដល់គ្រួសារដែលរងផលប៉ះពាល់នីមួយៗនីមួយៗ។

(៨). កិច្ចសន្យាមួយនឹងត្រូវបានរៀបចំដែលបង្ហាញពីការបំបែកចំនួន និងចំនួនសរុបនៃសំណង ហើយចរចាជាមួយគ្រួសារដែលរងផលប៉ះពាល់នីមួយៗ។ កំណត់ហេតុនឹងត្រូវបានរៀបចំ និងចុះហត្ថលេខាដោយ IRC-WG និង AHs ។

(៩). ប្រសិនបើ AHs ទាំងអស់យល់ស្របជាមួយនឹងកញ្ចប់សំណងជាដុំរបស់ពួកគេ ចំនួនទឹកប្រាក់ជាដុំនឹងត្រូវបានប្រគល់ជូននៅពេលចុះហត្ថលេខាលើកិច្ចសន្យា។

(១០). ដោយសារការរក្សាការសម្ងាត់នៃព័ត៌មាន និងលក្ខណៈពាណិជ្ជកម្មនៃកិច្ចសន្យា ឯកសារទាំងអស់ស្តីពី WBWS នឹងត្រូវបានរក្សាទុកនៅអគ្គនាយកដ្ឋាន GDR សម្រាប់ផ្ទៀងផ្ទាត់ដោយ ADB ។[9]

## ២. វិធីសាស្ត្រដោះស្រាយដោយការចរចា

៦០. សម្រាប់ដំណោះស្រាយដោយការចរចា អគ្គនាយកដ្ឋាន GDR នឹងបង្កើតនីតិវិធីក្នុងលក្ខណៈតម្លាភាព ស្រប និងសមធម៌ ប្រសិនបើលទ្ធកម្មដី ឬការផ្លាស់ប្តូរសិទ្ធិប្រើប្រាស់ដីធ្លីត្រូវបានទទួលតាមរយៈការចរចា ដើម្បីធានាថា AHs ដែលចូលខ្លួនទៅក្នុងការចរចាអាចរក្សាបានប្រាក់ចំណូល និងស្ថានភាពជីវភាពដូចពីមុន ឬប្រសើរជាង។

៦១. ដំណើរការខាងក្រោមនឹងត្រូវបានអនុម័តសម្រាប់ដំណោះស្រាយដោយការចរចា បន្ទាប់ពីដំណើរការនៅក្នុងកថាខណ្ឌទី ២៥, ឧបសម្ព័ន្ធទី 2 នៃ SPS៖

(១). ដើម្បីធានាបាននូវការចរចាណាមួយជាមួយ AHs ដោះស្រាយហានិភ័យនៃភាពមិនស៊ីសង្វាក់គ្នានៃព័ត៌មាន និងអំណាចចរចារបស់ភាគីពាក់ព័ន្ធក្នុងប្រតិបត្តិការបែបនេះ អគ្គនាយកដ្ឋាន GDR នឹងឱ្យភាគីខាងក្រៅឯករាជ្យដើម្បីចូលរួមចងក្រងឯកសារដំណើរការនៃការចរចា និងដំណោះស្រាយ ហើយព្រមព្រៀងជាមួយ ADB លើដំណើរការនានា គោលនយោបាយ ការគណនាការចំណាយ និងតម្រូវការនៃការរក្សាកំណត់ត្រាទុក។

(២). អគ្គនាយកដ្ឋាន GDR នឹងធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាភាសាដែលអាចយល់បានជាមួយគ្រួសារដែងរងផលប៉ះពាល់ ដើម្បីធានាថាពួកគេត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីគម្រោង/អនុគម្រោង អត្ថប្រយោជន៍របស់វា ដីដែលត្រូវការសម្រាប់គម្រោង/អនុគម្រោង គោលនយោបាយដោះ

---

[9] ឯកសារជំនួយស្មារតី (ឯកសាជូនភ្ជាប់ទី ៣) ចំណុច ៤ (១) នៃបេសកកម្មកិច្ចសន្ទនាស្តីពីគោលនយោបាយការពារ ដែលបានធ្វើឡើងនៅថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០១៩

ស្រាយផលប៉ះពាល់ ច្បាប់ និងបទប្បញ្ញត្តិ សិទ្ធិទទួលបាន និងសំណងក្នុងការចំណាយលើការជំនួសពេញលេញតាមអត្រាទីផ្សារបច្ចុប្បន្ន។ នេះនឹងត្រូវបានចងក្រងទុកជាឯកសារគ្រប់គ្រាន់។

(៣). អគ្គនាយកដ្ឋាន GDR នឹងធ្វើការស្ទង់មតិសេដ្ឋកិច្ចសង្គម និងជំរឿន, DMS និង RCS ដើម្បីកំណត់សារពើភ័ណ្ឌនៃការខាតបង់ និងតម្លៃជំនួស។

(៤). RCS នឹងគណនាតម្លៃទីផ្សារនៃដីដែលរងផលប៉ះពាល់ និង/ឬទ្រព្យសកម្មផ្សេងទៀតដែលស្មើនឹងតម្លៃជំនួសពេញលេញ។ នៅពេលដែលអត្រាទីផ្សារសម្រាប់ដីមិនមានអត្រាឯកតា RCS នឹងត្រូវបានបង្កើតឡើងនៅក្នុងការពិគ្រោះយោបល់ជាមួយ AHs ឬអ្នកប្រើប្រាស់ដីដើម្បីកំណត់ចំនួនសំណងសម្រាប់ដីដែលត្រូវទិញ និងទ្រព្យសម្បត្តិដែលភ្ជាប់ជាមួយដី។

(៥). ប្រសិនបើមានការបាត់បង់ប្រាក់ចំណូល ទីប្រឹក្សា RCS នឹងគណនាចំនួននៃការខាតបង់ដោយផ្អែកលើ EM នៅក្នុងក្របខ័ណ្ឌ RF នេះ។

(៦). ក្នុងករណីបាត់បង់ដើមឈើហូបផ្លែ ទីប្រឹក្សា RCS នឹងគណនាការខាតបង់ផ្នែកសេដ្ឋកិច្ចដោយផ្អែកលើបក្កភាព និងរូបមន្តដូចដែលបានកំណត់ក្នុង SOP ។

(៧). ក្នុងករណីដំណាំប្រចាំឆ្នាំ នឹងត្រូវវាយតម្លៃតាមអត្រាទីផ្សារសុទ្ធសម្រាប់ទិន្នផលដំណាំរយៈពេលមួយឆ្នាំ។

(៨). ប្រសិនបើមានការផ្លាស់ទីជារូបវន្ត ប្រាក់ឧបត្ថម្ភអន្តរកាលនឹងត្រូវបានផ្តល់ជូនតាមអត្រាដែលបានបង្ហាញនៅក្នុង EM ។

(៩). ចំនួនទឹកប្រាក់សរុបនៃសំណងនឹងត្រូវបានគណនា និងផ្តល់ជូនជាចំនួនដុំមួយដល់គ្រួសារដែលរងផលប៉ះពាល់នីមួយៗនីមួយៗ។

(១០). កិច្ចសន្យាមួយនឹងត្រូវបានរៀបចំដែលបង្ហាញពីការបំបែកចំនួន និងចំនួនសរុបនៃសំណង ហើយចរចាជាមួយគ្រួសារដែលរងផលប៉ះពាល់នីមួយៗ។ កំណត់ហេតុនឹងត្រូវបានរៀបចំ និងចុះហត្ថលេខាដោយ IRC-WG និង AHs ។

(១១). ប្រសិនបើ AHs ទាំងអស់យល់ស្របជាមួយនឹងកញ្ចប់សំណងជាដុំរបស់ពួកគេ ចំនួនទឹកប្រាក់ជាដុំនឹងត្រូវបានប្រគល់ជូននៅពេលចុះហត្ថលេខាលើកិច្ចសន្យា។

(១២). ក្នុងករណីដែល AH មិនយល់ព្រមលើដំណោះស្រាយដែលបានចរចា ការផ្តល់ជូននៃដំណោះស្រាយដែលបានចរចាសម្រាប់ AHs ទាំងអស់ នឹងត្រូវបានដកចេញ ហើយអគ្គនាយដ្ឋាន GDR នឹងបន្តរៀបចំ DRP សម្រាប់ដាក់ជូន ADB ដើម្បីពិនិត្យ និងអនុម័ត។ គោលការណ៍ដែលបានព្រមព្រៀងគ្នានៅក្នុងក្របខ័ណ្ឌ RF នេះនឹងត្រូវបានអនុវត្ត ប្រសិនបើ DRP នឹងត្រូវរៀបចំនៅពេលមានការបរាជ័យនៃការចរចា។ ក្នុងករណីបែបនេះ លក្ខខណ្ឌតម្រូវចំពោះការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ ADB ដែលមានចែងក្នុង SPS នឹងត្រូវបានអនុវត្ត។

(១៣). ព័ត៌មានស្តីពីការចរចានឹងត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ត្រួតពិនិត្យ បន្ទាប់ពីដំណើរការនេះត្រូវបានបញ្ចប់ និងដាក់ជូនទៅកាន់ ADB [10]។

## ច. វិធានការដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់នៃការតាំងទីលំនៅថ្មី

៦២. វិធានការសម្រាប់អនុគម្រោង ត្រូវបានអនុវត្តដើម្បីបញ្ចៀស ឬយ៉ាងហោចណាស់កាត់បន្ថយផលប៉ះពាល់នៃការតាំងលំនៅថ្មីដោយពិចារណាលើជម្រើសសក្តានុពល និង/ឬការកែតម្រូវលើការរៀបចំជារួម។ ពិសេសនៅកន្លែងណាដែលអនុគម្រោង នឹងតម្រូវឲ្យមានការទិញយកដី ដើម្បីធានាបាននូវលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធពេញមួយឆ្នាំ ជាពិសេសស្ថានីយ៍ចត្តាឡីស័កសត្វ និងតំបន់គ្រប់គ្រងជំងឺក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រៃវែង មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបុសសត្វ ក្នុងខេត្តកណ្តាល វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងរាជធានីភ្នំពេញ សុទ្ធសឹងជាទីតាំងដែលត្រូវបានជ្រើសរើស ដើម្បីបញ្ចៀសផលប៉ះពាល់ហួតដល់កម្រិតអតិបរមាដែលអាចធ្វើទៅបាន ជាពិសេសលើតំបន់លំនៅដ្ឋាន ផ្ទះសម្បែង និងសំណង់អគារផ្សេងៗ កន្លែងអាជីវកម្ម និងដំណាំកសិកម្ម ដីព្រៃឈើ និងតំបន់បេតិកភណ្ឌ។ ដោយឡែកសម្រាប់ការកែលម្អផ្សារលក់មាន់ទាដូនកែវ ក្នុងខេត្តតាកែវ វិធានការត្រូវបានរៀបចំឡើងដើម្បីធានានូវផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដែលនឹងពាក់ព័ន្ធផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលរចំពោះអ្នកដែលត្រូវផ្លាស់ទីតាំងលក់ដូរចំនួន ២៨ នាក់ ហើយផលប៉ះពាល់នេះត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍អនុវត្តកាតព្វកិច្ចផ្នែកគោលនយោបាយដែលបានរៀបចំជាផ្នែកមួយនៃការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់អនុគម្រោងនេះ។

---

[10] ឯកសារជំនួយស្មារតី (ឯកសាជូនភ្ជាប់ទី ៣) ចំណុច ៤ (១) នៃបេសកកម្មកិច្ចសន្ទនាស្តីពីគោលនយោបាយការពារ ដែលបានធ្វើឡើងនៅថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០១៩

# IV. ព័ត៌មានសេដ្ឋកិច្ចសង្គម

## ក. ការវាយតម្លៃហេតុប៉ះពាល់សង្គម

៦៣. ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) ទាមទារឱ្យមានការវាយតម្លៃពីអតីតកាល បច្ចុប្បន្នកាល និង អនាគតនៃផលប៉ះពាល់សង្គមដែលអាចកើតមាន និងការវិភាគយេនឌ័រ។ សម្រាប់អនុគម្រោងណាមួយដែលពាក់ព័ន្ធនឹងផលប៉ះពាល់ LAR ការស្ទង់មតិសេដ្ឋកិច្ចសង្គម និងជំរឿន នឹងត្រូវបានអនុវត្ត ដោយមានទិន្នន័យមូលដ្ឋានសេដ្ឋកិច្ចសង្គមសមស្រប ដែលប្រមូលបានដើម្បីកំណត់អត្តសញ្ញាណមនុស្សទាំងអស់ដែលនឹងត្រូវផ្លាស់ទីដោយសារអនុគម្រោង និងដើម្បីវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ចសង្គមរបស់គម្រោងមកលើពួកគេនៅ សមិទ្ធិលទ្ធភាព និងដំណាក់កាលរចនាប្លង់វិស្វកម្មលម្អិត។

៦៤. រាជរដ្ឋាភិបាលបានបង្កើតកម្រងសំណួរស្តង់ដា (ហៅថា DMS Questionnaire) ដោយផ្អែកលើកម្រងសំណួរស្ទង់មតិសេដ្ឋកិច្ចសង្គម (SES) ដែលប្រើក្នុងគម្រោងហិរញ្ញប្បទានរបស់ ADB កន្លងមក ដែលនឹងត្រូវប្រើប្រាស់ដើម្បីប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គម។ សារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់ AHs ការវាយតម្លៃប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ និងព័ត៌មានបែងចែកតាមយេនឌ័រ ដែលទាក់ទងនឹងលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមនៃ AHs នឹងត្រូវបានវាយតម្លៃ និងរៀបចំយ៉ាងត្រឹមត្រូវ។ ស្ថិតិមូលដ្ឋានពាក់ព័ន្ធដទៃទៀត នឹងត្រូវបានប្រមូលពីឃុំសង្កាត់ និងស្រុកភូមិក្នុងតំបន់គម្រោង។

៦៥. ជាផ្នែកមួយនៃការវាយតម្លៃផលប៉ះពាល់សង្គម អនុគម្រោងនឹងកំណត់អត្តសញ្ញាណក្រុមក្រីក្រ និងក្រុមងាយរងគ្រោះក្នុងចំណោមគ្រួសារដែលរងផលប៉ះពាល់ទាំងអស់ ដែលអាចភាពសភាពខុសគ្នា ឬមិនសមាមាត្រដោយសារអនុគម្រោង ដោយសារស្ថានភាពលំបាក ឬងាយរងគ្រោះរបស់ពួកគេ ស្របតាមលក្ខណៈវិនិច្ឆ័យដែលបង្កើតឡើងដោយអគ្គនាយកដ្ឋាន GDR (និងបានកំណត់នៅក្នុងនិយមន័យ)។ នៅពេលដែលបុគ្គល និងក្រុមទាំងនោះត្រូវបានកំណត់អត្តសញ្ញាណរួច អនុគម្រោងនឹងស្នើ ហើយអនុវត្តវិធានការដែលបានកំណត់គោលដៅរួច ដើម្បីកុំឱ្យផលប៉ះពាល់អវិជ្ជមានមកលើពួកគេ ហើយពួកគេមិនបាត់បង់ឱកាសចំពោះការចែករំលែកអត្ថប្រយោជន៍ដែលកើតចេញពីការអភិវឌ្ឍន៍នេះទេ។

៦៦. ការប្រមូលព័ត៌មាន និងតម្រូវការរបស់ពួកគេនឹងអាស្រ័យលើប្រភេទ និងទំហំនៃផលប៉ះពាល់នីមួយៗ។ នៅដំណាក់កាលគម្រោងបច្ចុប្បន្ន លទ្ធផលរបស់គម្រោងនឹងមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាននោះទេ។ នេះនឹងត្រូវបានពិនិត្យនៅដំណាក់កាលអនុវត្តហើយត្រូវបានគេសន្មត់ថាឧទាហរណ៍ក្រោមលទ្ធផល ២.១ ទាក់ទងនឹងការកែតម្រូវតាមរយៈ DED នៅលើទីតាំងហេដ្ឋារចនាសម្ព័ន្ធដែលបានស្នើឡើង នឹងមិននាំទៅរកការចាត់ថ្នាក់ IR ថ្មីណាមួយទេ។ ប្រសិនបើមានតម្រូវការដែលមិនបានមើលឃើញទុកជាមុនសម្រាប់លទ្ធកម្មដីធ្លីក្នុងទំហំតូចបំផុត (ដោយការធ្វេសប្រហែសណាមួយ) វិធីសាស្ត្រនៃដំណោះស្រាយដោយការចរចា នឹងត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋាន GDR មុនពេលឈានចូលទៅដល់វិធីសាស្ត្រផ្អែកលើ DRP ។ ចំណុចនេះនឹងជាកម្មវត្ថុនៃការព្រមព្រៀងរបស់ AHs តាមឆន្ទៈរបស់ខ្លួនក្នុងការចូលរួមក្នុងដំណោះស្រាយដោយការចរចា។

## ខ. វិធីសាស្ត្រសម្រាប់ការស្ទង់អង្កេតដោយវាស់វែងលម្អិត[11]

៦៧. គម្រោងនឹងអនុវត្តជំរឿន ១០០% និងបញ្ជីសារពើភណ្ឌទ្រព្យសកម្មរបស់ AHs ដើម្បីកំណត់ (១). តើពួកគេជានរណា, (២). តើពួកគេប្រកបរបរអ្វីសម្រាប់ការចិញ្ចឹមជីវិត, និង (៣). តើពួកគេមានកម្មសិទ្ធិអ្វីខ្លះ ហើយដែលទំនងជាបាត់បង់ដោយសារគម្រោង។ ព័ត៌មាន និងទិន្នន័យ DMS/SES ដែលត្រូវប្រមូល គឺមាននៅក្នុងកម្រងសំណួរ DMS ។

៦៨. បន្ទាប់ពីការយល់ព្រមពីក្រុមប្រឹក្សាភិបាល ADB នៃគម្រោង និងការបញ្ចប់ការសិក្សាវាយតម្លៃអនុគម្រោង និង DED (ឈានដល់ដំណាក់កាលកំណត់ព្រំដីពិតប្រាកដដែលត្រូវការ) ដោយទីប្រឹក្សាដែលចូលរួមក្រោមក្របខ័ណ្ឌគម្រោង និង PMU នោះ GDR ដែលនឹងអនុវត្តការអង្កេតដោយវាស់វែងលម្អិត (DMS) ដោយប្រើកម្រងសំណួរ DMS ។ គ្រួសារដែលរងផលប៉ះពាល់ នឹងត្រូវបានផ្តល់ប័ណ្ណសម្គាល់ដែលមានរៀបរាប់លម្អិតអំពីទ្រព្យសកម្ម ប្រាក់ចំណូល និងដីដែលរងផលប៉ះពាល់របស់ពួកគេបន្ទាប់ពីការធ្វើ DMS ។

៦៩. ក្រុមការងារ IRC-WG រួមជាមួយនឹង PRSC-WG ដែលបង្កើតឡើងសម្រាប់អនុគម្រោងដោយ IRC នឹងអនុវត្ត DMS ដែលនឹងកំណត់ ១០០% នៃជំរឿន AHs ពោលគឺ ១០០% នៃ SES; ការកំណត់អត្តសញ្ញាណ និងការវាស់វែង ១០០% នៃការបាត់បង់ដី និងទ្រព្យសម្បត្តិមិនមែនដី (១០០% IOL)។ ការស្ទង់មតិ DMS នឹងត្រូវបានអនុវត្តតាមរយៈការសម្ភាស និងការពិគ្រោះយោបល់តាមគ្រួសារនីមួយៗ។

៧០. កម្រងសំណួរ DMS អាចចាប់យកទិន្នន័យ SES ពាក់ព័ន្ធ និងគន្លឹះសម្រាប់ ១០០% នៃ DPs ។ នេះនឹងរាប់បញ្ចូលទាំងទិន្នន័យគ្រួសារផងដែរផ្អែកតាមទំហំ និងជនជាតិ ភេទ អាយុ ស្ថានភាពគ្រួសារ កម្រិតវប្បធម៌របស់មេគ្រួសារប្រភេទនិងប្រភពប្រាក់ចំណូល ស្ថានភាពការងារ និងប្រាក់ចំណូលគ្រួសារសរុប ទិន្នន័យបែងចែកតាមភេទ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មនុស្សចាស់ ជនពិការ ឬជនជាតិដើមភាគតិច និងមធ្យោបាយចិញ្ចឹមជីវិតផ្សេងទៀត ប្រសិនបើមាន។

៧១. ទិន្នន័យអំពីដីដែលរងផលប៉ះពាល់ (តំបន់ និងប្រភេទ) ផ្ទះសម្បែង និងរចនាសម្ព័ន្ធសំណង់ (តំបន់ និងប្រភេទ) និងទ្រព្យសកម្មផ្សេងទៀត ស្ថានភាពកម្មសិទ្ធិ (ប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិ) ដើមឈើ និងដំណាំដែលរងផលប៉ះពាល់ និងទ្រព្យសកម្មផលិតភាពផ្សេងទៀត នឹងត្រូវបានរាប់បញ្ចូល ហើយការវាស់វែងលម្អិតនឹងត្រូវបានអនុវត្តផងដែរ។ ចំណូលចិត្តសម្រាប់ជម្រើសនៃដំណោះស្រាយផលប៉ះពាល់ នឹងត្រូវបានស្វែងរក និងលម្អិតផងដែរ នៅពេលមានតម្រូវឱ្យមានការផ្លាស់ទីជារូបវន្ត។

[11] យោងទៅលើ SOP សម្រាប់ឧបករណ៍ស្ទង់មតិ

## គ. ការកំណត់ថ្លៃដើមជំនួស

៧២. **គោលការណ៍គ្រឹះ៖** រាល់ការផ្តល់សំណងទាំងអស់ នឹងផ្អែកលើគោលការណ៍គ្រឹះនៃការចំណាយលើការជំនួសពេញលេញតាមតម្រូវការដោយស្របតាម ADB-SPS ឆ្នាំ២០០៩ [12] ។ ដើម្បីអនុវត្តការសិក្សាតម្លៃជំនួស (RCS) អគ្គនាយកដ្ឋាន GDAHP នឹងជ្រើសរើសអ្នកវាយតម្លៃឯករាជ្យម្នាក់ដែលមានជំនាញវិជ្ជាជីវៈ (RCS Consultant) បន្ទាប់ពីការរចនាប្លង់វិស្វកម្មលម្អិត និងក្នុងអំឡុងពេលអង្កេត DMS ដើម្បីកំណត់អត្រាសំណងដែលឆ្លុះបញ្ចាំងពីតម្លៃទីផ្សារបច្ចុប្បន្នសម្រាប់ (១). ដីកសិកម្ម ដីលំនៅដ្ឋាន និងដីអាជីវកម្ម, (២). ប្រភេទផ្សេងគ្នានៃរចនាសម្ព័ន្ធដែលរងផលប៉ះពាល់, និង (៣). ដំណាំ និងដើមឈើ ការខាតបង់អាជីវកម្ម ថ្លៃដឹកជញ្ជូន ប្រាក់ឧបត្ថម្ភសម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ អនុផលឈើ/របងឈើ រួមមាននៅក្រោមដំណាំ និងដើមឈើ។

៧៣. ការសិក្សាតម្លៃជំនួស (RCS) នឹងមានសុពលភាពរយៈពេលមួយឆ្នាំបន្ទាប់ពីការបញ្ចប់នៃការអង្កេតដោយវាស់វែងលម្អិត (DMS) ហើយប្រសិនបើការផ្តល់ជូនសំណង និង/ឬជំនួយមិនត្រូវបានធ្វើឡើងចំពោះអ្នកដែលត្រូវផ្លាស់ទី ឬប្រសិនបើសំណងមិនត្រូវបានផ្តល់ជូនពួកគេក្នុងរយៈពេលនេះទេនោះ ថ្លៃជំនួសនឹងត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារដែលកំពុងមាននៅពេលនោះ ដោយទីប្រឹក្សា RCS ។ លទ្ធផល RCS នឹងក្លាយជាមូលដ្ឋានសម្រាប់ការប៉ាន់ប្រមាណថវិកា សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការចំណាយសម្រាប់ការតាំងទីលំនៅឡើងវិញ។

៧៤. **ចំពោះតម្លៃជំនួសនៃដី៖** ទីប្រឹក្សា RCS នឹងសម្ភាសផ្ទាល់ជាមួយគ្រួសារដែលទើបនឹងទិញ ឬលក់ដី ដើម្បីប្រមូលភស្តុតាងនៃអត្រាប្រតិបត្តិការដីធ្លី ហើយសម្ភាសគ្រួសារដែលកំពុងស្វែងរកអចលនទ្រព្យដើម្បីលក់ ឬទិញក្នុង និងជុំវិញតំបន់អនុគម្រោង។ ទីប្រឹក្សា RCS ក៏នឹងស្វែងយល់ពីអ្នកស្រុកក្នុងតំបន់ផងដែរ ដើម្បីជាការបញ្ជាក់/កំណត់សុពលភាពតាមរយៈការកត់ត្រាផ្លូវការរបស់អាជ្ញាធរមូលដ្ឋាន ហើយតម្លៃនៃប្រភេទដីផ្សេងៗ ដែលជាកម្មវត្ថុនៃប្រតិបត្តិការក្នុងរយៈពេលប្រាំមួយ (៦) ខែ កន្លងមក ដល់មួយ (១) ឆ្នាំ នៅក្នុងសហគមន៍ ឬតំបន់ក្បែរនោះ និងតម្លៃដីប្រភេទផ្សេងៗដែលអ្នកស្រុកមានឆន្ទៈក្នុងការទិញ ឬលក់ ព្រមទាំងប្រមូលទិន្នន័យពីការិយាល័យរដ្ឋពាក់ព័ន្ធស្តីពីប្រតិបត្តិការដីធ្លីថ្មីៗ និងការវាយតម្លៃទីផ្សារដីធ្លីជាក់ស្តែង។ ដំណើរការទាំងនេះ នឹងត្រូវបានចងក្រងទុកជាឯកសារយ៉ាងត្រឹមត្រូវ និងភ្ជាប់ជាមួយផែនការ DRP ។

៧៥. **ចំពោះរចនាសម្ព័ន្ធសំណង់៖** ទីប្រឹក្សា RCS នឹងសម្ភាសម្ចាស់នៃរចនាសម្ព័ន្ធសំណង់ដើម្បីកំណត់សម្ភារៈសំណង់ដែលបានប្រើប្រាស់ជាធម្មតានៅក្នុងមូលដ្ឋានសម្រាប់ប្រភេទអគារនីមួយៗតាមប្រភេទ ឬស្តង់ដាដែលមានស្រាប់របស់រដ្ឋាភិបាល។ ប្រភពនៃសម្ភារៈសំណង់ដែលបានប្រើប្រាស់ និងតម្លៃឯកតានៃសម្ភារៈទាំងនោះ រួមទាំងថ្លៃដឹកជញ្ជូនដូចគ្នាទៅកាន់មូលដ្ឋាន ក៏ដូចជាតម្លៃពលកម្មសម្រាប់ការសាងសង់ប្រភេទអគារនីមួយៗដែលមាននៅក្នុងមូលដ្ឋាន។ នៅក្នុងការស្ទង់មតិនេះ ការសម្ភាសន៍ក៏នឹងធ្វើឡើងជាមួយអ្នកម៉ៅការសំណង់ផងដែរ ដើម្បីកំណត់តម្លៃនៃសម្ភារៈសំណង់សម្រាប់ប្រភេទសំណង់នីមួយៗនៅក្នុងតំបន់អនុគម្រោង ទៅតាមប្រភេទដែលស្រាប់របស់

រដ្ឋាភិបាល។ តម្លៃដឹកជញ្ជូនសម្ភារៈសំណង់ទៅកាន់តំបន់អនុគម្រោង (សហគមន៍) តម្លៃពលកម្មសម្រាប់ការសាងសង់ប្រភេទអគារនីមួយៗ និងតម្លៃឯកតាក្នុងមួយម៉ែត្រការ៉េនៃប្រភេទអគារនីមួយៗនៅក្នុងតំបន់គម្រោងបន្ទាប់បន្សំតាមប្រភេទដែលមានស្រាប់របស់រដ្ឋាភិបាល។ តម្លៃជំនួស នឹងផ្អែកលើអត្រាចុងក្រោយបំផុតចំពោះការសាងសង់នៅក្នុងរង្វង់តំបន់អនុគម្រោង។

៧៦. **ចំពោះដំណាំ និងដើមឈើ៖** ការសម្ភាសនឹងធ្វើឡើងជាមួយម្ចាស់ អាជីវករផ្សារ និងអ្នកផ្គត់ផ្គង់ដំណាំកូនឈើ ដើម្បីកំណត់តម្លៃចម្ការលក់បច្ចុប្បន្ននៃផ្លែឈើ ឬដំណាំនៅក្នុងតំបន់ និងផ្តល់សំណងទៅតាមការរៀបរាប់ខាងលើ។ ការស្ទង់មតិ RCS នឹងប្រមូលទិន្នន័យពីការិយាល័យស្ថិតិអំពីទិន្នផលជាមធ្យមក្នុងមួយប្រភេទដំណាំ និង/ឬដើមឈើដែលបានកំណត់ក្នុងអំឡុងពេល DMS ។

## ឃ. ការរៀបចំ និងការដាក់បញ្ជូនសេចក្តីព្រាង និងផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP)

៧៧. ព័ត៌មាន និងទិន្នន័យដែលប្រមូលបានតាមរយៈ DMS នឹងត្រូវបានប្រើដើម្បីរៀបចំ DRP ស្របតាម ADB-SPS (ឆ្នាំ២០០៩) និងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជាសម្រាប់អនុគម្រោងនីមួយៗ ឬសម្រាប់អនុគម្រោងទាំងអស់នៅក្នុងក្រុងណាមួយ ដោយផ្អែកលើស្ថានភាពនៃករណីបរាជ័យក្នុងការចរចាដែលឈានទៅដល់ការដកហូត។ ទិន្នន័យសេដ្ឋកិច្ចសង្គមដែលប្រមូលបាននៅដំណាក់កាល DMS នឹងបង្កើតជាសូចនាករសំខាន់ៗជាមូលដ្ឋានសម្រាប់គោលបំណងត្រួតពិនិត្យ និងវាយតម្លៃតាមការចាំបាច់។ ម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន នឹងត្រូវបានធ្វើបច្ចុប្បន្នកម្មសម្រាប់អនុគម្រោង/ក្រុមនៃអនុគម្រោងនីមួយៗក្នុងក្រុងនីមួយៗដោយផ្អែកលើប្រភេទនៃការខាតបង់ពិតប្រាកដ និងត្រូវរួមបញ្ចូលក្នុងផែនការ DRP ។

៧៨. តម្លៃឯកតាដែលកំណត់ដោយ RCS នឹងត្រូវបានប្រើដើម្បីគណនាសំណងសម្រាប់អ្នកដែលត្រូវផ្លាស់ទីនីមួយៗ ដោយផ្អែកលើការបាត់បង់ទ្រព្យសម្បត្តិដែលបានវាស់វែង។ លើសពីនេះទៀត ការចំណាយលើជំនួយសម្រាប់ការតាំងទីលំនៅឡើងវិញ សម្រាប់ការបាត់បង់ប្រាក់ចំណូលអន្តរកាល និងប្រាក់ឧបត្ថម្ភដែលអាចអនុវត្តបានផ្សេងទៀត និងកម្មវិធីស្តារជីវភាពរស់នៅឡើងវិញ ប្រសិនបើមាន នឹងត្រូវបានគណនាផងដែរ។ ថវិកាសម្រាប់ការចំណាយលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) នឹងត្រូវដាក់បញ្ចូលនៅក្នុងផែនការ DRP ។ ផែនការ DRP នឹងត្រូវបានរៀបចំដោយអគ្គនាយកដ្ឋាន GDR និងដាក់ជូន IRC សម្រាប់ការអនុម័តជាផ្លូវការ មុនពេលដាក់ជូនទៅកាន់ ADB សម្រាប់ជម្រះ។

# V. ការពិគ្រោះយោបល់ ការចូលរួម និងការបញ្ចេញព័ត៌មាន

## ក. ការពិគ្រោះយោបល់ និងការចូលរួម

៧៩. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) រួមជាមួយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR) នឹងធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយអ្នកដែលត្រូវផ្លាស់ទីសហគមន៍ម្ចាស់ស្រុក និងអង្គការសង្គមស៊ីវិលសម្រាប់អនុគម្រោងនីមួយៗ ក្រោមក្របខ័ណ្ឌគម្រោងដែលបានកំណត់ឃើញផលប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ ការពិគ្រោះយោបល់ក៏នឹងមានរាប់បញ្ចូលទាំងការពិភាក្សាជាក្រុមជាមួយអ្នកដែលរងផលប៉ះពាល់ទាំងអស់ រួមទាំងក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ និងការពិគ្រោះយោបល់ជាលក្ខណៈបុគ្គលមួយទល់នឹងមួយដែលបានធ្វើឡើងក្នុងអំឡុងពេលជំរឿន និងអំឡុងពេលស្ទង់មតិសេដ្ឋកិច្ចសង្គម (SES)។ ដំណើរការពិគ្រោះយោបល់ នឹងចាប់ផ្តើមដំបូងក្នុងដំណាក់កាលរៀបចំគម្រោង ហើយនឹងបន្តពេញមួយវដ្តនៃគម្រោង។ អ្នកដែលត្រូវផ្លាស់ទី នឹងត្រូវបានពិគ្រោះយោបល់យ៉ាងពេញលេញ និងផ្តល់ឱកាសដើម្បីចូលរួមក្នុងការធ្វើផែនការ និងការអនុវត្តលទ្ធកម្មដីធកលី និងការតាំងទីលំនៅឡើងវិញ។ ពួកគេនឹងត្រូវបានជូនដំណឹងក្នុង
លក្ខណៈសមស្រប និងទាន់ពេលវេលាអំពីលទ្ធផលនៃដំណើរការរៀបចំផែនការ ក៏ដូចជាកាលវិភាគ និងនីតិវិធីសម្រាប់ការអនុវត្តផែនការ DRP ។

៨០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) រួមជាមួយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR) នឹងធានាថាការពិគ្រោះយោបល់គឺរួមបញ្ចូលបញ្ហាយេនឌ័រ ហើយការយកចិត្តទុកដាក់ជាពិសេសត្រូវបានធ្វើឡើងដើម្បីធានាឱ្យមានការចូលរួមរបស់ស្ត្រី និងក្រុមងាយរងគ្រោះក្នុងចំណោមអ្នកដែលរងផលប៉ះពាល់ តាមដែលអាចធ្វើទៅបាន។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នឹងត្រូវបានធ្វើឡើងដើម្បីដាក់បញ្ចូលនូវវិធានការកាត់បន្ថយ ដើម្បីដោះស្រាយកង្វល់របស់ពួកគេ ក្នុងករណីដែលពាក់ព័ន្ធ និងអាចធ្វើទៅបាន។

៨១. រាជរដ្ឋាភិបាលបានបង្កើតដំណើរការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈដោយទូលំទូលាយ និងដោយបរិយាប័ន្ន ដែលមានចំនួនបួនជំហាន ដើម្បីអនុវត្តកិច្ចសន្ទនាប្រកបដោយអត្ថន័យជាមួយអ្នកដែលរងផលប៉ះពាល់ សហគមន៍ដែលរងផលប៉ះពាល់ និងអង្គការសង្គមស៊ីវិល។ តួនាទីរបស់ក្រសួង MAFF និងអគ្គនាយកដ្ឋាន GDR មានភាពខុសគ្នានៅជំហានផ្សេងគ្នានៃដំណើរការពិគ្រោះយោបល់ ដែលត្រូវបានពិពណ៌នាលម្អិតនៅក្នុង **ឧបសម្ព័ន្ធទី** 2 ។

## ខ. ការបញ្ចេញព័ត៌មាន

1. ៨២. សេចក្តីសង្ខេបនៃក្របខ័ណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RF) ដែលបានអនុម័ត សេចក្តីព្រាងផែនការ DRP និង DRP នឹងត្រូវបានបកប្រែជាភាសាខ្មែរ ហើយបិទផ្សាយនៅសាលាឃុំ ស្រុក និងខេត្ត ដើម្បីងាយស្រួលទទួលបានព័ត៌មាន និងដោយឥតគិតថ្លៃសម្រាប់អ្នកដែលត្រូវផ្លាស់ទី និងសហគមន៍ដែលរងផល

ប៉ះពាល់។ សម្រាប់អ្នកដែលមិនចេះអក្សរ វិធីសាស្ត្រទំនាក់ទំនងដ៏សមរម្យផ្សេងទៀតនឹងត្រូវបានប្រើដោយផ្អែកលើការពិភាក្សា និងការពិគ្រោះយោបល់ជាមួយអ្នកដែលត្រូវផ្លាស់ទី។ ក្របខ័ណ្ឌ RF និង DRP ជាភាសាខ្មែរ និងភាសាអង់គ្លេស ក៏នឹងត្រូវបានលាតត្រដាងនៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅពេលដែលត្រូវបានអនុម័តដោយ IRC និងត្រូវជម្រះដោយ ADB។ បណ្ណុំសៀវភៅព័ត៌មានគម្រោង (PIB) ចំនួនបីជុំក៏នឹងត្រូវបានរៀបចំសម្រាប់ដំណាក់កាលផ្សេងគ្នានៃកិច្ចប្រជុំពិគ្រោះយោបល់ និងកិច្ចប្រជុំដោយមានការចូលរួម ហើយផ្សព្វផ្សាយដោយផ្ទាល់ទៅកាន់ អ្នកដែលត្រូវផ្លាស់ទី ក៏ដូចជាបិទផ្សាយនៅសាលាឃុំ និងភូមិ។ អនុគម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តរបស់ជនជាតិដើមភាគតិច នឹងមិនត្រូវបានផ្តល់ហិរញ្ញប្បទានក្រោមក្របខ័ណ្ឌគម្រោងនេះទេ។ កង្វល់ និងបញ្ហាយេនឌ័រ នឹងត្រូវបានគិតគូពិចារណាក្នុងការរៀបចំផែនការ និងការអនុវត្តការដោះស្រាយផលប៉ះពាល់។ វិធានការចែករំលែកអត្ថប្រយោជន៍ដែលបែងចែកតាមយេនឌ័រ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការ DRPs ដើម្បីធានាថាស្ត្រី និងបុរសក្នុងគ្រួសារត្រូវបានយកចិត្តទុកដាក់ដោយស្មើភាពគ្នា។ ព័ត៌មានទាក់ទងនឹងជនជាតិដើមភាគតិច និងបញ្ហាយេនឌ័រ នឹងត្រូវបង្ហាញដល់ក្រុមទាំងពីរ ដើម្បីឱ្យពួកគេបានដឹងពីគោលនយោបាយការពាររបស់ ADB និងរបស់គម្រោងទាំងសម្រាប់ជនជាតិដើមភាគតិច និងស្ត្រី។

៨៣. អគ្គនាយកដ្ឋាន GDR នឹងដាក់បញ្ជូនឯកសារខាងក្រោមនេះទៅកាន់ ADB ដើម្បីលាតត្រដាងនៅលើគេហទំព័ររបស់ ADB បន្ទាប់ពីមានការយល់ព្រមពី IRC និងជម្រះដោយ ADB៖

(១). ក្របខ័ណ្ឌ RF និងសេចក្តីព្រាង RPs ដែលរៀបចំសម្រាប់អនុគម្រោង ក្នុងអំឡុងពេលរៀបចំគម្រោង មុនពេលបញ្ចប់ការវាយតម្លៃគម្រោង (នៅកិច្ចប្រជុំថ្នាក់ដឹកនាំ ឬកិច្ចប្រជុំត្រួតពិនិត្យបុគ្គលិករបស់ ADB) និងក្របខ័ណ្ឌ RF នេះត្រូវបានអនុម័តដោយ IRC និងគាំទ្រដោយ ADB មុនពេលការវាយតម្លៃគម្រោង។

(២). សេចក្តីព្រាង DRP ដែលបានរៀបចំសម្រាប់អនុគម្រោង បន្ទាប់ពីបានការអនុម័តគម្រោងដោយ ADB DRPs ដែលត្រូវបានអនុម័តដោយ IRC និងគាំទ្រដោយ ADB។

(៣). DRPs នៃអនុគម្រោង និងការធ្វើបច្ចុប្បន្នកម្ម ប្រសិនបើមាន និង DRP ថ្មី និង DRP ដែលបានធ្វើបច្ចុប្បន្នកម្ម និងផែនការសកម្មភាពកែតម្រូវដែលបានរៀបចំក្នុងអំឡុងពេលអនុវត្តគម្រោង ប្រសិនបើមាន។

(៤). របាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមពាក់កណ្តាលប្រចាំឆ្នាំរបស់ LAR ឬរបាយការណ៍ត្រួតពិនិត្យការដោះស្រាយផលប៉ះពាល់។

# VI. ការផ្តល់សំណង ការស្តារប្រាក់ចំណូលឡើងវិញ និងការផ្លាស់ទី

## ក. វិធានការផ្តល់សំណង

៨៤. គោលបំណងរួមនៃគោលនយោបាយទាក់ទងនឹងលទ្ធកម្មដីធ្លី និងការតាំងទៅលំនៅឡើងវិញ (LAR) នៃគម្រោងគឺដើម្បីធានាថាអ្នករងផលប៉ះពាល់ទាំងអស់នឹងអាចរក្សាបាននូវកម្រិតជីវភាពរបស់ខ្លួន បើយ៉ាងហោចណាស់ក៏ក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោង ហើយបើបានល្អជាងមុន ក៏ជាការប្រសើរបំផុត ក៏ដូចជាសមត្ថភាពរកប្រាក់ចំណូលតាមរយៈការផ្តល់សំណងសម្រាប់ការខាតបង់ទ្រព្យសម្បត្តិជារូបវន្ត និងមិនមែនជារូបវន្ត និងតម្រូវឱ្យផ្តល់ជំនួយ និងវិធានការស្តារនីតិសម្បទា ដើម្បីកសាងឡើងវិញនូវជីវភាពដែលរងផលប៉ះពាល់។

៨៥. ម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន (**តារាងទី 3**) ត្រូវបានបង្កើតឡើងសម្រាប់គម្រោង ដោយពិចារណាលើផលប៉ះពាល់ទាំងអស់ដែលអាចកើតមានដោយសារគម្រោង។ ម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន ត្រូវបានរាប់បញ្ចូលកញ្ចប់ពេញលេញសម្រាប់សំណងលើការបាត់បង់ដី និងទ្រព្យសកម្មមិនមែនដី ជំនួយសម្រាប់ការតាំងទីលំនៅឡើងវិញ (ការបាត់បង់ប្រាក់ចំណូល ការរំខាន និងប្រាក់ឧបត្ថម្ភសម្រាប់ការដឹកជញ្ជូន) និងកម្មវិធីស្តារ/គាំទ្រមុខរបរចិញ្ចឹមជីវិត រួមជាមួយនឹងការគាំទ្រ/វិធានការបន្ថែមសម្រាប់ក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះ។ ដោយអនុលោមតាមគោលការណ៍ និងគោលនយោបាយដោះស្រាយផលប៉ះពាល់ជាក់លាក់របស់គម្រោង សំណងដែលត្រូវទូទាត់សងសម្រាប់ទ្រព្យសកម្មដែលរងផលប៉ះពាល់ដោយផ្អែកលើការតម្លៃជំនួស ដោយគ្មានការកាត់សម្រាប់បង់ពន្ធ និង/ឬការចំណាយលើប្រតិបត្តិការ។ ម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាននេះ នឹងណែនាំដល់ការរៀបចំ DRP និងផ្អែកលើច្បាប់របស់ប្រទេសកម្ពុជា និងលក្ខខណ្ឌតម្រូវរបស់ ADB-SPS (ឆ្នាំ២០០៩)។ សិទ្ធិទទួលបានក្នុងម៉ាទ្រិចក្នុងតារាងទី ៣ ប្រហែលជាមិនបានគ្របដណ្តប់គ្រប់ប្រភេទនៃផលប៉ះពាល់នោះទេ ហើយនឹងត្រូវបានកែលម្អ ឬធ្វើឱ្យប្រសើរនៅក្នុង ផែនការ DRP ដោយផ្អែកលើលទ្ធផលរកឃើញតាមរយៈ DMS, SES និង RCS អំឡុងពេលអនុវត្តគម្រោង ប៉ុន្តែនឹងមិនអាចទម្លាក់ចំណាត់ថ្នាក់បានទេក្នុងករណីដែលនឹងមានផលប៉ះពាល់ទាក់ទងនឹង LAR ត្រូវបានរកឃើញក្នុងដំណាក់កាលអនុវត្តគម្រោង។

៨៦. សម្រាប់តែអ្នកដែលត្រូវផ្លាស់ទី ហើយដែលបានបញ្ជាក់ថាកំពុងរស់នៅក្នុង កំពុងធ្វើអាជីវកម្ម ឬដីដាំដុះ ឬមានសិទ្ធិលើធនធាននៅក្នុងទីតាំងអនុគម្រោង ឬដីដែលត្រូវធ្វើលទ្ធកម្ម ឬត្រូវប្រើប្រាស់សម្រាប់អនុគម្រោងមុនកាលកាលបរិច្ឆេទឱសានវាទតែប៉ុណ្ណោះ ដែលនឹងមានសិទ្ធិទទួលបានសំណងសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិ និងជំនួយសម្រាប់ការតាំងទីលំនៅឡើងវិញ។ សុពលភាពនៃសិទ្ធិទទួលបានរបស់អ្នកដែលត្រូវផ្លាស់ទី នឹងត្រូវបានកំណត់ក្នុងដំណាក់កាល DMS ។ ថវិកាសម្រាប់សំណង និងជំនួយផ្សេងទៀតសម្រាប់ការតាំងទីលំនៅឡើងវិញ នឹងត្រូវបញ្ចូលទៅក្នុងផែនការ DRP និងការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដែលចង់បានបន្ទាប់ពីការអនុម័តជាផ្លូវការលើផែនការ DRP ដោយ ADB ។

## ខ. កម្មវិធីស្តារប្រាក់ចំណូលឡើងវិញ (IRP)

៨៧. អ្នកដែលត្រូវផ្លាស់ទី និងដែលបាត់បង់មធ្យោបាយចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ នឹងត្រូវបានផ្តល់ការគាំទ្រ ដើម្បីបង្កើតមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេឡើងវិញ។ ការគាំទ្រនេះអាចធ្វើឡើងជាទម្រង់នៃការផ្តល់ជំនួយជាសាច់ប្រាក់សម្រាប់ពួកគេក្នុងការស្វែងរកជាថ្មី ឬលើកកម្ពស់ជំនាញរបស់ពួកគេ ឬតាមរយៈកម្មវិធីគាំទ្រប្រាក់ចំណូល (ដោយពឹងអាស្រ័យលើដី មូលដ្ឋានការងារ ឬមូលដ្ឋានអាជីវកម្ម) អាស្រ័យលើជម្រើសរបស់អ្នកដែលត្រូវផ្លាស់ទី និងដូចដែលបានរាយក្នុងតារាងខាងក្រោម។

៨៨. កម្មវិធីស្តារប្រាក់ចំណូលឡើងវិញ (IRP) នឹងត្រូវបានរៀបចំឡើងនៅក្នុងការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ និងការចូលរួមយ៉ាងសកម្មជាមួយអ្នកដែលត្រូវផ្លាស់ទី។ កម្មវិធី IRP នឹងរួមមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬជំនាញសម្រាប់អ្នកដែលត្រូវផ្លាស់ទី និងដែលមានសិទ្ធិទទួលបាន។ ព័ត៌មានលម្អិតនៃ IRP ដូចជាប្រភេទនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ/ជំនាញ ចំនួនអ្នកដែលត្រូវផ្លាស់ទី ហើយដែលមានសិទ្ធិទទួលបានសម្រាប់កម្មវិធី IRP ការរៀបចំស្ថាប័ន នីតិវិធីចុះឈ្មោះជាដើម ក៏ដូចជាថវិកានឹងត្រូវបានពិពណ៌នានៅក្នុងផែនការ DRP ។ អ្នកដែលត្រូវផ្លាស់ទីទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាជនក្រីក្រ និងជនងាយរងគ្រោះតាមប្រភេទដែលមានចែងក្នុងនិយមន័យនៃក្រុមដែលងាយរងគ្រោះ ហើយកាន់ប័ណ្ណក្រីក្រ ក៏នឹងត្រូវបានផ្តល់ជំនួយបន្ថែមផងដែរ ដើម្បីលើកកម្ពស់ស្ថានភាពរស់នៅរបស់ពួកគេ។

៨៩. **កម្មវិធីស្តារជីវភាពរស់នៅដែលពឹងអាស្រ័យលើដី៖** កម្មវិធីនេះរួមបញ្ចូល (១). លទ្ធភាពទទួលបានប្រភពចំណូលដែលពឹងអាស្រ័យលើដីផ្សេងទៀត ដូចជាការដាំបន្លែ ដើមឈើហូបផ្លែ និងការចិញ្ចឹមសត្វ ប្រសិនបើជាដីកសិកម្មដែលមានតម្លៃសមរម្យអាចជំនួសបាន។ គម្រោងនឹងមិនផ្តល់ដីឱ្យទេ លើកលែងតែករណីដោះដូរដី។ អ្នកដែលត្រូវផ្លាស់ទី នឹងត្រូវទទួលបានដីដោយចំណាយផ្ទាល់ខ្លួន។ ជាពិសេស ការបណ្តុះបណ្តាលជំនាញដែលបានរចនាឡើងក្នុងវិស័យកសិកម្ម និងការចិញ្ចឹមសត្វ នឹងត្រូវបានផ្តល់ជូនដល់អ្នកដែលត្រូវផ្លាស់ទី, និង (២). ជំនួយហិរញ្ញវត្ថុក្នុងទម្រង់ជាកញ្ចប់សាច់ប្រាក់សរុប ២០០ ដុល្លារអាមេរិក ដើម្បីជួយក្នុងការស្តារមុខរបរចិញ្ចឹមជីវិតនៅឡើងវិញ។

៩០. ក្នុងករណីដែលគ្មានដីកសិកម្មសម្រាប់ជំនួស អ្នកដែលត្រូវផ្លាស់ទីទាំងនេះនឹងត្រូវទទួលបានជម្រើសក្នុងការទទួលយកឱ្យចូលរួមកម្មវិធីស្តារជីវភាពរស់នៅដោយពឹងអាស្រ័យលើការងារក៏បាន ឬដោយពឹងអាស្រ័យលើអាជីវកម្មក៏បាន។

៩១. **កម្មវិធីស្តារជីវភាពរស់នៅដែលពឹងអាស្រ័យលើការងារ៖** កម្មវិធីរួមមាន (១). ការផ្តល់ការបណ្តុះបណ្តាលជំនាញការងារ។ ការស្ទង់មតិអំពីឱកាសការងារដែលនៅជិតកន្លែងផ្លាស់ទី នឹងត្រូវធ្វើឡើងជាផ្នែកមួយនៃការរៀបចំផែនការ DRP ដែលត្រូវធ្វើការវិភាគដើម្បីកំណត់ប្រភេទការងារដែលមាន និងតម្រូវការជំនាញ។ កម្មវិធីបណ្តុះបណ្តាលនេះ នឹងត្រូវបង្កើតឡើងដោយមានការសម្របសម្រួលជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងតំបន់គម្រោងដើម្បីជួយកសាងជំនាញទាំងនេះសម្រាប់អ្នកដែលត្រូវផ្លាស់ទី។ ការចំណាយនឹងត្រូវបានដាក់បញ្ចូល

ទៅក្នុងថវិកានៃផែនការ DRP, (២). ជំនួយហិរញ្ញវត្ថុក្នុងទម្រង់ជាសាច់ប្រាក់ ស្មើនឹងប្រាក់ចំណូលរយៈពេល ៣ ខែ ដោយផ្អែកលើអត្រាភាពក្រីក្រផ្លូវការដែលកំណត់ដោយរដ្ឋាភិបាល ដើម្បីគាំទ្រដល់អ្នកដែលត្រូវផ្លាស់ទីក្នុងអំឡុងពេលបណ្តុះ
បណ្តាល។ ចំនួននេះ ត្រូវគណនាដោយយកអត្រានៃភាពក្រីក្រប្រចាំខែ x ចំនួនសមាជិកក្នុងគ្រួសារដែលត្រូវផ្លាស់ទី x 3, និង (៣). លទ្ធភាពទទួលបានឱកាសការងារបណ្តោះអាសន្ននៅការដ្ឋានសាងសង់ នៅការិយាល័យ ឬកន្លែងផ្សេងទៀតដែលអាចមានក្រោមក្របខ័ណ្ឌគម្រោង។

៩២. **កម្មវិធីស្តារជីវភាពរស់នៅដែលពឹងអាស្រ័យលើអាជីវកម្ម៖** កម្មវិធីនេះរួមមាន (១). ការផ្តល់ការបណ្តុះបណ្តាលជំនាញអាជីវកម្មផ្តោតលើអាជីវកម្មខ្នាតតូច ឬតាមផ្ទះ, និង (២). ជំនួយហិរញ្ញវត្ថុក្នុងទម្រង់ជាសាច់ប្រាក់ចំនួន ២០០ ដុល្លារអាមេរិ ដើម្បីជួយក្នុងការចាប់ផ្តើម ឬបង្កើតអាជីវកម្មខ្នាតតូច ឬតាមផ្ទះឡើងវិញ។

៩៣. **កញ្ចប់ពិសេសសម្រាប់ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ៖** ក្នុងករណីបាត់បង់មធ្យោបាយចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ដោយសារការផ្លាស់ទីជារូបវន្ត នោះអ្នកដែលត្រូវផ្លាស់ដែលត្រូវបានចាត់ថ្នាក់ជាក្រុមក្រីក្រ និងក្រុមងាយរងគ្រោះតាមប្រភេទដែលមានចែងក្នុងនិយមន័យនៃក្រុមងាយរងគ្រោះ និងកាន់ប័ណ្ណក្រីក្រអាចចូលរួមនៅក្នុងកម្មវិធីណាមួយក្នុងចំណោមកម្មវិធីទាំងបី និងកម្មវិធីបណ្តុះបណ្តាលជំនាញដែលត្រូវគ្នា អាស្រ័យលើជម្រើសរបស់ពួកគេ។ លើសពីនេះ អ្នកដែលត្រូវផ្លាស់ទីប្រភេទនេះនឹងមានសិទ្ធិទទួលបាននូវៈ (១). អត្រាជំនួយទ្វេដងផ្នែកហិរញ្ញវត្ថុដែលផ្តល់ជូននៅក្នុងកម្មវិធីចិញ្ចឹមជីវិតបីផ្សេងគ្នា, និង (២). អាទិភាពក្នុងការទទួលបានឱកាសការងារក្រោមក្របខ័ណ្ឌគម្រោង។

៩៤. **ការផ្លាស់ប្តូរទីតាំង៖** គម្រោងនឹងមិនជួយគាំទ្រដល់ការផ្លាស់ប្តូរទីតាំងជារូបវន្តទនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុងពេលនៃការកែលម្អផ្សារលក់មាន់ទាខេត្តតាកែវ អាជីវករមួយចំនួនដែលរាប់បញ្ចូលទាំងអ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងសត្តឃាត និងការលក់មាន់ទា នឹងត្រូវផ្លាស់ប្តូរទីតាំងជាបណ្តោះអាសន្ន ទោះបីជានៅក្នុងទីតាំងរួមគ្នាដែលមានស្រាប់នៅផ្សារក៏ដោយ។ អនុគម្រោងដែលត្រូវកំណត់អំឡុងពេលអនុវត្ត ជាពិសេសគម្រោងដែលទាក់ទងនឹងការកែលម្អ និងពង្រីកសត្តឃាតដ្ឋាន និងផ្សារ ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយផ្អែកពីអ្នកវិនិយោគវិស័យឯកជនទៅលើរចនាសម្ព័ន្ធសំណង់បែបនេះ នឹងមិនត្រូវបានអនុម័តទេ ប្រសិនបើមានតម្រូវការសម្រាប់ទម្រង់នៃការផ្លាស់ទីតាំងជាអចិន្ត្រៃយ៍ ទោះបីជាដូចករណីដែលមានការផ្លាស់ប្តូរទីតាំងបណ្តោះអាសន្ននៃផ្សារលក់មាន់ទាខេត្តតាកែវ ក្នុងរង្វង់ទីតាំងរួមគ្នានៃរចនាសម្ព័ន្ធរូបវន្តដែលមានស្រាប់ នឹងត្រូវបានអនុញ្ញាត។ អគ្គនាយកដ្ឋាន GDAHP នៅថ្នាក់ជាតិបានយល់ច្បាស់អំពីបញ្ហានេះ ព្រោះថាបានផ្តួចផ្តើមគំនិតនេះតាំងពីគ្រាដំបូងមក។

# តារាងទី 2. ម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាន

| ប្រភេទ | ប្រភេទនៃការខាតបង់ | ការដាក់ឱ្យអនុវត្ត | ប្រភេទនៃគ្រួសារដែលត្រូវផ្លាស់ទី | សិទ្ធិទទួលបាន | ការបក្លី |
|---|---|---|---|---|---|
| | | | ការបាត់បងដី | | |
| ១ក | ការបាត់បង់ដី | ដីកសិកម្ម ដីលំនៅដ្ឋាន និងដីពាណិជ្ជកម្ម | កម្មសិទ្ធិករស្របច្បាប់ និងអ្នកកាន់កាប់សិទ្ធិពិតប្រាកដនៃដី រួមទាំងអ្នកដែលគ្រប់ដណ្តប់ដោយសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី។ | • សំណងជាសាច់ប្រាក់សម្រាប់ដីក្នុងតម្លៃជំនួសពេញលេញ ឬការដោះដូរដីក្នុងតម្លៃផលិតភាពស្មើគ្នា។<br>• ការផ្តល់ពន្ធប្រថាប់ត្រា ថ្លៃចុះបញ្ជីដីធ្លី និងពន្ធស្រដៀងគ្នាផ្សេងទៀត ប្រសិនបើអាចអនុវត្តបាន សម្រាប់ការទទួលបានសិទ្ធិស្របច្បាប់ក្នុងករណីជំនួសដី (ដីសម្រាប់ដោះដូរ)<br>• រួមបញ្ចូលជម្រើសនៃសំណងក្នុងតម្លៃជំនួសដូចគ្នា សម្រាប់ដីដែលរងផលប៉ះពាល់ដែលនៅសេសសល់បន្ទាប់ពីការទទួលបាន ប្រសិនបើដីដែលនៅសល់ក្លាយទៅជាដីមិនអាចរស់នៅបាន ឬមិនអាចប្រើប្រាស់បាន។<br>• សម្រាប់កម្មសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ដីជំនួសសម្រាប់ទ្រទ្រង់ជីវភាព និងមធ្យោបាយចិញ្ចឹមជីវិត។ ការចុះបញ្ជីដីធ្លី ការបង់ពន្ធប្រថាប់ត្រា និងកម្រៃផ្សេងៗ ដើម្បីចុះបញ្ជីកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់ នឹងត្រូវទូទាត់សងវិញតាមការចំណាយជាក់ស្តែង។ | ប្រសិនបើមានការផ្តល់ដីជូន នោះកម្មសិទ្ធិនឹងបានទៅទាំងប្តីនិងប្រពន្ធ។<br><br>អនុវត្តចំពោះការបាត់បង់ដីមួយផ្នែកប៉ុណ្ណោះ។ |
| ១ខ | ការបាត់បង់ដី | | អ្នកជួល និងអ្នកបង់រំលោះ | • គ្មានការផ្តល់សំណងសម្រាប់ម្ចាស់ដីដែលបាត់បង់ដី ដែលមិនមែនជាកម្មសិទ្ធិស្របច្បាប់ | |

| ប្រភេទ | ប្រភេទនៃការខាតបង់ | ការដាក់ឱ្យអនុវត្ត | ប្រភេទនៃគ្រួសារដែលត្រូវផ្លាស់ទី | សិទ្ធិទទួលបាន | ការបេក្ខី |
|---|---|---|---|---|---|
| ១គ | ការបាត់បង់ដី | | អ្នកកាន់កាប់ខុសច្បាប់/កាន់កាប់អ្នកចូលមករស់នៅដោយខុសច្បាប់ដោយគ្មានប័ណ្ណកម្មសិទ្ធិ ឬគ្មានសិទ្ធិកាន់ | • គ្មានការផ្តល់សំណងសម្រាប់ម្ចាស់ដីដែលបាត់បង់ដី ដែលមិនមែនជាកម្មសិទ្ធិស្របច្បាប់ | |

| ការបាត់បង់ការប្រើប្រាស់ដី | | | | | |
|---|---|---|---|---|---|
| ២ក | ការបាត់បង់ដំណាំ និងផ្លែឈើ និងដើមឈើមិនមែនប្រភេទហូបផ្លែ | ដីកសិកម្ម | គ្រួសារដែលត្រូវផ្លាស់ទីទាំងអស់ដែលប្រកបរបរកសិកម្ម | • **ចំពោះដំណាំស្រូវ/ដំណាំដាំដុះ៖**<br>**ប្រាក់ចំណូលប្រចាំឆ្នាំសុទ្ធ X 1 ឆ្នាំ**<br>លើសពីនេះគ្រួសារដែលរងផលប៉ះពាល់ អាចប្រមូលផល និងរក្សាប្រាក់ចំណូលពីដំណាំឈររបស់ខ្លួនបាន។<br>• **ចំពោះដើមឈើហូបផ្លែ៖** តម្លៃជំនួសនៃការបាត់បង់ដោយផ្អែកតាមរូបមន្តខាងក្រោម៖<br><br>**{(បរិមាណប្រមូលផលក្នុងមួយឆ្នាំ) X (តម្លៃទីផ្សារ) X (ចំនួនឆ្នាំដែលវានឹងបង្កើតផល)} + ថ្លៃដើមនៃកូនដំណាំ**<br>ដើមឈើដែលមានអាយុច្រើនឆ្នាំ ដែលមានរយៈពេលលូតលាស់លើសពី ៥ ឆ្នាំត្រូវបានចាត់ថ្នាក់ ដូចខាងក្រោម៖<br>• កូនឈើដែលមានអាយុក្រោម ១ ឆ្នាំ មិនត្រូវបានផ្តល់សំណងទេ ព្រោះអាចដាំឡើងវិញបាន។ ថ្លៃដើម ត្រូវបានផ្តល់ឱ្យ។ | RCS នឹងកំណត់បរិមាណ<br><br>តម្លៃទីផ្សារគឺផ្អែកលើតម្លៃទីផ្សារកសិដ្ឋាន (Farm-Gate)<br><br>តម្លៃពេញគឺជាចំនួនដែលគណនាពីរូបមន្តដែលបង្ហាញក្នុង [ ] ដោយមិនគិតថ្លៃដើមនៃឈើ |

| | | | | | |
|---|---|---|---|---|---|
| | | | | • ដើមឈើទើបតែដុះ (ពី ១ ទៅ ៣ ឆ្នាំ)៖ មានតម្លៃ 1/3 នៃតម្លៃពេញ ព្រោះវាអាចដាំឡើងវិញបាន បូកនឹងថ្លៃដើមនៃកូនឈើ<br>• ដើមឈើទើបដុះ (លើសពី ៣ ទៅ ៥ ឆ្នាំ) បង្កើតផលខ្លះ៖ មានតម្លៃ 2/3 នៃតម្លៃពេញ បូកនឹងតម្លៃដើមនៃកូនឈើ<br>• ដើមឈើចាស់ (លើសពី ៥ ឆ្នាំ) មានផ្លែពេញ ត្រូវផ្តល់តម្លៃពេញ បូកនឹងតម្លៃដើមនៃកូនឈើ | |
| ២៩ | ការបាត់បង់អាជីវកម្ម | ដីពាណិជ្ជកម្ម និងដីអាជីវកម្ម | គ្រួសារដែលត្រូវផ្លាស់ទីទាំងអស់ ដែលចូលរួមក្នុងសកម្មភាពអាជីវកម្ម | • សម្រាប់អាជីវកម្មដែលត្រូវផ្លាស់ប្តូរទៅកាន់ទីតាំងថ្មី ត្រូវផ្តល់ចំនួនទឹកប្រាក់ស្មើនឹងការបាត់បង់ប្រាក់ចំណូលសុទ្ធដែលបានព្យាករណ៍សម្រាប់**រយៈពេល ២ ខែ**។<br>• សម្រាប់អាជីវកម្មដែលផ្លាស់ប្តូរទីតាំងនៅនឹងកន្លែង (ផ្លាស់ទីទៅក្រោយ ឬក្នុងតំបន់ដដែល) ត្រូវផ្តល់ចំនួនទឹកប្រាក់ស្មើនឹងការបាត់បង់ប្រាក់ចំណូលសុទ្ធដែលបានព្យាករណ៍ សម្រាប់**រយៈពេលមួយខែ**។<br>• សម្រាប់ប្រតិបត្តិការអាជីវកម្មខុសច្បាប់ ដូចជាល្បែងស៊ីសង ពេស្យាចារ គ្រឿងញៀន និងប្រភេទស្រដៀងគ្នានេះ មិនត្រូវបានផ្តល់សំណងទេ។ | RCS នឹងកំណត់បរិមាណ<br><br>ទាំងអាជីវកម្មដែលបានចុះបញ្ជី និងមិនទាន់ចុះបញ្ជី ត្រូវបានផ្តល់សំណង លើកលែងតែមានលក្ខណៈជាអាជីវកម្មខុសច្បាប់។ |

| ការបាត់បង់ផ្ទះ និងរចនាសម្ព័ន្ធសំណង់ផ្សេងទៀត | | | | | |
|---|---|---|---|---|---|
| ៣ក | ការបាត់បង់ផ្ទះ និងរចនាសម្ព័ន្ធសំណង់ផ្សេងទៀត | សំណង់លំនៅដ្ឋាន សំណង់ពាណិជ្ជកម្ម និងទ្រព្យសកម្មផ្សេងទៀត។ | ម្ចាស់ផ្ទះ ម្ចាស់អគារ និងម្ចាស់រចនាសម្ព័ន្ធសំណង់ | • សំណងជាសាច់ប្រាក់ស្មើនឹងតម្លៃជំនួសនៃចំណែកដែលបាត់បង់ផ្ទះ/អគារ/រចនាសម្ព័ន្ធសំណង់។ ប្រសិនបើម្ចាស់ជួល ឬរំលោះសំណងសម្រាប់ការកែលម្អ/សំណង់ដែលធ្វើឡើងដោយអ្នកជួល/អ្នករំលោះ នឹងត្រូវកាត់ចេញពីការទូទាត់សំណងទៅឱ្យម្ចាស់។<br>• ក្នុងករណីបាត់បង់តែផ្នែកនៃផ្ទះ/អគារ/សំណង់ ហើយចំណែកដែលនៅសល់មិនអាចរស់នៅបាន ឬមិនអាចប្រើប្រាស់បាន សំណងនឹងត្រូវផ្តល់សម្រាប់រចនាសម្ព័ន្ធពេញលេញក្នុងតម្លៃជំនួសដូចដើម។<br>• ក្នុងករណីផ្ទះ/អគារត្រូវបានជួល/រំលោះ ការកែលម្អ/សំណង់ណាមួយដែលបន្ថែមដោយអ្នកជួល និងអ្នករំលោះ នឹងត្រូវបានផ្តល់សំណងក្នុងតម្លៃជំនួស និងបង់ឱ្យអ្នកជួល/អ្នករំលោះ។ ភាគីជាម្ចាស់នឹងមិនទទួលបានសំណងសម្រាប់ការកែលម្អ/ការសាងសង់បែបនេះទេ។ | RCS នឹងកំណត់តម្លៃជំនួស<br><br>ប្រសិនបើការបាត់បង់គឺមានចំនួន ៧៥% ឬច្រើនជាងនេះនៃទំហំ ឬជាន់ |
| ៣ខ | ការបាត់បង់ផ្ទះ និងរចនាសម្ព័ន្ធសំណង់ផ្សេងទៀត | សំណង់លំនៅដ្ឋាន សំណង់ពាណិជ្ជកម្ម និងទ្រព្យសកម្មផ្សេងទៀត។ | អ្នកជួល និងអ្នកបង់រំលោះ | • សំណងជាសាច់ប្រាក់ក្នុងតម្លៃជំនួសសម្រាប់ការកែលម្អ ឬការសាងសង់ណាមួយដោយអ្នកជួល ឬអ្នករំលោះ។<br>• ក្នុងករណីមិនមានការកែលម្អ ឬសាងសង់ទេ សំណងមិនត្រូវបានបង់ឱ្យទេ។<br>• ប្រាក់ឧបត្ថម្ភលើការផ្ទេរ/រុះរើ ស្មើនឹង ១ ខែនៃចំនួនជួល ឬរំលោះ។ | RCS នឹងកំណត់តម្លៃជំនួស<br><br>ត្រូវទាមទារឱ្យមានភស្តុតាងជាឯកសារ |

| | | | | | |
|---|---|---|---|---|---|
| ៣គ | ការបាត់បង់ផ្ទះ និងរចនាសម្ព័ន្ធសំណង់ផ្សេងទៀត | សំណង់លំនៅដ្ឋាន សំណង់ពាណិជ្ជកម្ម និងទ្រព្យសកម្មផ្សេងទៀត។ | អ្នកកាន់កាប់ខុសច្បាប់/អ្នកចូលមករស់នៅដោយខុសច្បាប់ | • សំណងជាសាច់ប្រាក់ស្មើនឹងតម្លៃជំនួសនៃការបាត់បង់រចនាសម្ព័ន្ធសំណង់ដែលបានសាងសង់ ដោយអ្នកកាន់កាប់ខុសច្បាប់/អ្នកចូលមករស់នៅដោយខុសច្បាប់។ | RCS នឹងកំណត់តម្លៃជំនួស |
| ៣ឃ | ការបាត់បង់ផ្ទះ និងរចនាសម្ព័ន្ធសំណង់ផ្សេងទៀត (ប្រាក់ឧបត្ថម្ភសម្រាប់ដឹកជញ្ជូន) | ប្រាក់ឧបត្ថម្ភសម្រាប់ការដឹកជញ្ជូនរបស់របរផ្ទះសម្បែង និងរបស់របរផ្ទាល់ខ្លួន | គ្រួសារដែលត្រូវផ្លាស់ទី | • ប្រាក់សរុបជាកញ្ចប់ ក្នុងមួយគ្រួសារដែលរងផលប៉ះពាល់ ដោយផ្អែកលើការចំណាយជាមធ្យមនៃការដឹកជញ្ជូនទៅកាន់កន្លែងផ្លាស់ប្តូរទីលំនៅថ្មី។<br>• ត្រឹម ៥ គីឡូម៉ែត្រ<br>• លើសពី ៥ គីឡូម៉ែត្រ | RCS នឹងកំណត់ចំនួនប្រាក់សរុបជាកញ្ចប់សម្រាប់ចំនួន ២ អត្រា។ |

| ការបាត់បង់ប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិត | | | | | |
|---|---|---|---|---|---|
| ៤ក | ការបាត់បង់ប្រាក់ចំណូលក្នុងអំឡុងពេលអន្តរកាល - **ប្រាក់ឧបត្ថម្ភជីវភាព** | បាត់បង់ប្រាក់ចំណូល | គ្រួសារដែលត្រូវផ្លាស់ទី ដែលបាត់បង់ប្រាក់ចំណូលក្នុងអំឡុងពេលអន្តរកាល | • ចំនួនទឹកប្រាក់សរុបជាកញ្ចប់ស្មើនឹង ៣ ខែ នៃប្រាក់ចំណូលដោយផ្អែកលើអត្រាភាពក្រីក្រប្រចាំខែផ្លូវការ ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។<br>**អត្រាភាពក្រីក្រតាមកាលកំណត់ X ចំនួនសមាជិកក្នុងគ្រួសារដែលត្រូវផ្លាស់ទី X 3** | អត្រាភាពក្រីក្រតាមកាលកំណត់ ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ |
| ៤ខ | ការបាត់បង់ប្រភពចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ ដោយសារតែការផ្លាស់ទីលំនៅជារូបវន្ត | ការស្តារប្រាក់ចំណូលឡើងវិញ | គ្រួសារដែលត្រូវផ្លាស់ទី ដែលបាត់បង់ប្រភពចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ | • មានសិទ្ធិចូលរួមក្នុងកម្មវិធីណាមួយក្នុងចំណោម ៣ **កម្មវិធីស្តារ/គាំទ្រជីវភាពរស់នៅឡើងវិញ៖**<br>• **ការស្តារជីវភាពរស់នៅដោយផ្អែកលើដី**សម្រាប់គ្រួសារដែលត្រូវផ្លាស់ទី ដែលចូលរួមក្នុងការចិញ្ចឹមជីវិតពឹងអាស្រ័យលើដីធ្លី៖ (១). លទ្ធភាពទទួលបានប្រភពចំណូលដែលពឹងអាស្រ័យលើដីផលិតភាពផ្សេងទៀតប្រសិនបើមានដីសម្រាប់ដាំបន្លែ ដើមឈើហូបផ្លែ និងការចិញ្ចឹមសត្វ និងប្រភពចំណូលដទៃទៀតដែលពឹងអាស្រ័យលើដីធ្លី, (២). ការផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្ម និងការចិញ្ចឹមសត្វ, និង (២). ជំនួយហិរញ្ញវត្ថុក្នុងទម្រង់ជាកញ្ចប់សាច់ប្រាក់សរុប **ចំនួន ២០០ ដុល្លារអាមេរិក** ដើម្បីចាប់ផ្តើមមុខរបរចិញ្ចឹមជីវិតឡើងវិញ។<br>• ក្នុងករណីដែលគ្មានដីកសិកម្មសម្រាប់ជំនួស អ្នកដែលត្រូវផ្លាស់ទីទាំងនេះនឹងត្រូវទទួលបានជម្រើសក្នុងការទទួលយកឱ្យចូលរួមកម្មវិធីស្តារជីវភាពរស់នៅដោយពឹងអាស្រ័យលើការងារក៏បាន ឬដោយពឹងអាស្រ័យលើអាជីវកម្មក៏បាន។<br>ឬក៏<br>• **ការស្តារឡើងវិញនូវជីវភាពរស់នៅដោយផ្អែកលើការងារ**សម្រាប់ AHs ដែលបាត់បង់ការងារជាអចិន្ត្រៃយ៍៖ (១). ការផ្តល់ការបណ្តុះបណ្តាលជំនាញការងារ។ និង (២). ជំនួយជាកញ្ចប់សាច់ប្រាក់ដែល | គ្រួសារដែលរងផលប៉ះពាល់ ដែលបាត់បង់ដីដែលពឹងអាស្រ័យលើដីសម្រាប់ជាមុខរបរចិញ្ចឹមជីវិត<br><br>គ្រួសារដែលរងផលប៉ះពាល់ ដែលបាត់បង់ការងារដែលពឹងអាស្រ័យលើដីសម្រាប់ជាមុខរបរចិញ្ចឹមជីវិត។<br><br>គ្រួសារដែលរងផលប៉ះពាល់ ដែលបាត់បង់អាជីវកម្មដែលពឹងអាស្រ័យលើដីសម្រាប់ជាមុខរបរចិញ្ចឹមជីវិត។<br><br>អាចត្រូវបានផ្តល់ជូនសម្រាប់ គ្រួសារដែលរងផលប៉ះពាល់ដែលចង់ជ្រើសជម្រើសនេះ។ |

| | | | | | |
|---|---|---|---|---|---|
| | | | | ស្មើនឹងប្រាក់ចំណូល**រយៈពេល ៣ ខែ** ដោយផ្អែកលើអត្រាភាពក្រីក្រជាផ្លូវការ ដើម្បីបន្ថែមការគាំទ្រប្រាក់ចំណូលក្នុងអំឡុងពេលបណ្តុះបណ្តាល។<br>**ឬក៏**<br>• **ការស្តារឡើងវិញនូវជីវភាពរស់នៅដោយផ្អែកលើអាជីវកម្ម**សម្រាប់ AHs ដែលបាត់បង់អាជីវកម្មជាអចិន្ត្រៃយ៍ ឬ AHs ដែលជ្រើសរើសជម្រើសនេះសម្រាប់ជាប្រភពចិញ្ចឹមជីវិតជំនួស៖ (១). ការផ្តល់ជំនាញអាជីវកម្ម; និង (២). ជំនួយជាកញ្ចប់សាច់ប្រាក់សរុប**ចំនួន ២០០ ដុល្លារអាមេរិក** ដើម្បីជួយក្នុងការចាប់ផ្តើមអាជីវកម្មខ្នាតតូចឬមុខរបរនៅផ្ទះ។ | គ្រួសារដែលរងផលប៉ះពាល់ នឹងមានសិទ្ធិជ្រើសសម្រាប់តែ**ជម្រើសមួយក្នុងចំណោមជម្រើសទាំងបី**ខាងលើប៉ុណ្ណោះ។ |
| | | | | • សម្រាប់គ្រួសារដែលរងផលប៉ះពាល់ **ដែលក្រីក្រ និងងាយរងគ្រោះ**។ បន្ថែមពីលើការបណ្តុះបណ្តាលជំនាញ (១). ជំនួយជាកញ្ចប់សាច់ប្រាក់ នឹង**កើនឡើងទ្វេដង**, និង (២). អាទិភាពក្នុងឱកាសការងារណាមួយនៅក្រោមក្របខ័ណ្ឌគម្រោង។ | ការចាត់ថ្នាក់ នឹងត្រូវបានអនុវត្តក្នុងអំឡុងពេល DMS និងអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងផ្នែកទី IV. ចំណុច ឃ នៃ SOP និងជាមួយ ប័ណ្ណក្រីក្រ។ |

| | | | | | |
|---|---|---|---|---|---|
| ៥ | **ផលប៉ះពាល់អំឡុងពេលសាងសង់** | | | • ដីដែលនៅក្រៅបន្ទាត់ព្រំ ឬច្រករបៀងនៃផលប៉ះពាល់ដែលត្រូវបាន ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារសកម្មភាពសាងសង់ នឹងត្រូវបានផ្តល់សំណងជាសាច់ប្រាក់ ឬជាសន្តានចិត្តក្នុងតម្លៃជំនួសដោយអ្នកម៉ៅការសាងសង់។ | ▪ ផលប៉ះពាល់ដោយសារការសាងសង់ (ឧ. ការខូចខាតរចនាសម្ព័ន្ធ ការរឹតត្បិតប្រភពអាជីវកម្ម/ប្រាក់ចំណូលដែលកើតចេញពីសកម្មភាពសាងសង់) និងវិធានការសំណងនឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង។<br>▪ គោលការណ៍ដែលបានអនុម័តសម្រាប់ ក្របខ័ណ្ឌ RF នេះ ត្រូវតែអនុវត្ត។ |
| ៦ | **ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តដែលមិនបានរំពឹងទុក មានផលប៉ះពាល់លើសពី 1 ដល់ 7 ខាងលើ** | | គ្រួសារថ្មីដែលរងផលប៉ះពាល់ ដែលមានសិទ្ធិ | • គ្រួសារថ្មីដែលត្រូវផ្លាស់ទី ដែលនឹងត្រូវកំណត់អត្តសញ្ញាណអាចមានសិទ្ធិទទួលបាន ដូចគ្នានឹងសិទ្ធិរបស់គ្រួសារដែលត្រូវផ្លាស់ទីផ្សេងទៀតដែរ។ | ▪ អគ្គនាយកដ្ឋាន GDR ត្រូវធានានូវការវាយតម្លៃហេតុប៉ះពាល់សង្គម និងធ្វើបច្ចុប្បន្នកម្មលើផែនការ DRP ឬបង្កើតផែនការ DRP អាស្រ័យលើវិសាលភាពនៃការផ្លាស់ប្តូរផលប៉ះពាល់ដែលគ្របដណ្តប់លើតម្រូវការដែលអាចអនុវត្តបានទាំងអស់ ដូចដែលបានបញ្ជាក់នៅក្នុងផែនការ DRP ស្របតាមលក្ខខណ្ឌតម្រូវនៃ ADB-SPS និងច្បាប់ និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា។ |

ប្រភព៖ ឧបសម្ព័ន្ធទី ៦ នៃ SOP

# VII. យន្តការដោះស្រាយការសោកស្តាយ

## ក. គោលបំណងនៃយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

៩៥. យន្តការដោះស្រាយបណ្តឹងសារទុក្ខ (GRM) ដែលមានទម្រង់ល្អ និងដំណើរការល្អ នឹងត្រូវបានបង្កើតឡើងនៅថ្នាក់មូលដ្ឋាន តាមនីតិវិធីស្តង់ដារបស់រដ្ឋាភិបាល ដើម្បីដោះស្រាយបណ្តឹង និងការទាមទារតវ៉ានានាក្នុងលក្ខណៈទាន់ពេលវេលា និងដោយពេញចិត្តតាមតម្រូវការ ក្រោមគោលការណ៍ ADB-SPS (ឆ្នាំ២០០៩)។ ច្បាប់ស្តីពីអស្សាមិករណ៍នៃរាជរដ្ឋាភិបាលកម្ពុជា អនុញ្ញាតឱ្យគណៈកម្មការដោះស្រាយបណ្តឹងសារទុក្ខ (GRC) ដើម្បីគ្រប់គ្រងពាក្យបណ្តឹងនានា ជាមួយនឹងការផ្តល់បន្ថែមដល់គ្រួសារដែលរងផលប៉ះពាល់ក្នុងការស្វែងរកដំណោះស្រាយតាមផ្លូវតុលាការ ក្នុងករណីដែលពួកគេជំទាស់នឹងការសម្រេចចិត្តរបស់ GRC ។

## ខ. ដំណើរការដោះស្រាយបណ្តឹងតវ៉ា

៩៦. គណៈកម្មការពិនិត្យ និងដោះស្រាយបណ្តឹងថ្នាក់ខេត្ត (PGRC) នឹងត្រូវបានបង្កើតឡើងក្នុងខេត្តគោលដៅនីមួយៗ ដែលអនុគម្រោងជាអ្នកកំណត់ទីតាំង និងអនុវត្ត[13] ។ PGRC ត្រូវបានផ្តល់សិទ្ធិអំណាចនៅកម្រិតរដ្ឋបាល ដើម្បីធ្វើការសម្រេចចិត្តជាចាំបាច់លើការដោះស្រាយបណ្តឹងតវ៉ានានាដែលកើតមាន។ PGRC នឹងត្រូវបានបណ្តុះបណ្តាលឱ្យ មានដំណើរការ និងអនុវត្តឱ្យបានពេញលេញនៅក្នុងខេត្តគោលដៅរបស់អនុគម្រោង មុនពេលធ្វើការអង្កេតដោយវាស់វែងលម្អិត (DMS) ។ ការបណ្តុះបណ្តាលលើដំណើរការ GRM នឹងត្រូវបានផ្តល់ដោយអគ្គនាយកដ្ឋាន GDR សម្រាប់ PGRC មុនពេលអនុវត្ត DMS ។ ព័ត៌មានអំពី PGRC នឹងត្រូវបានដាក់បញ្ចូលទៅក្នុង PIB ដែលបានធ្វើបច្ចុប្បន្នកម្មរួច ដើម្បីចែកចាយទៅគ្រួសារដែលរងផលប៉ះពាល់ មុនពេលអនុវត្ត DMS ។ គោលការណ៍ណែនាំស្តីពី GRM រួមទាំងនីតិវិធី និងទម្រង់ជាភាសាខ្មែរ នឹងត្រូវបានចែកចាយជាឯកសារភ្ជាប់ទៅកាន់ PIB ។ PGRC មានសមាសភាពតំណាងមកពីអាជ្ញាធរខេត្តដែលពាក់ព័ន្ធ និងមន្ត្រីមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម៖

(១). អភិបាលនៃគណៈអភិបាលខេត្ត - ប្រធាន
(២). ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត - ជាអនុប្រធាន
(៣). ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត - សមាជិក
(៤). ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត - សមាជិក
(៥). ប្រធានការិយាល័យនីតិកម្ម និងសន្តិសុខសាធារណៈខេត្ត - សមាជិក
(៦). អភិបាលស្រុក - សមាជិក
(៧). តំណាងអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន - សមាជិក។

---

[13] គណៈកម្មការពិនិត្យ និងដោះស្រាយបណ្តឹងថ្នាក់ខេត្ត (PGRC) ត្រូវបានបង្កើតឡើងរួចហើយ និងដំណើរការពេញលេញនៅក្នុងខេត្តមួយចំនួន ដែលអាចអនុវត្តភារកិច្ចសម្រាប់អនុគម្រោង។

៩៧.  បណ្ដឹងតវ៉ានឹងត្រូវបានដោះស្រាយតាមរយៈវិធីសាស្ត្រផ្លូវការ ៣ ជំហាន ដែលរៀបរាប់ខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ  មុនពេលឈានដល់ជំហានដំបូង  គ្រួសារដែលរងផលប៉ះពាល់អាចស្វែងរកជំនួយក្រៅផ្លូវការពីមេឃុំ ឬមនុស្សចាស់ទុំក្នុងសហគមន៍ ដើម្បីពិភាក្សានិងស្វែងរកដំណោះស្រាយប្រកបដោយភាពស្និទ្ធស្នាលចំពោះការមិនសុខចិត្ត ឬដាក់បណ្ដឹងតវ៉ារបស់គាត់ទៅកាន់ប្រធាន PRSC-WG ។ ការស្វែងរកដំណោះស្រាយនេះ អាចធ្វើឡើងដោយពាក្យសំដីផ្ទាល់មាត់ និងដោយក្រៅផ្លូវការ ហើយលើសពីនេះទៅទៀត គោលបំណងសំខាន់ គឺដើម្បីដោះស្រាយបញ្ហាដែលកើតមាន  ជៀសវាងការប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរជាផ្លូវការ។  ពាក្យបណ្ដឹងដែលបានលើកឡើងនៅគ្រប់កម្រិត  រួមទាំងនៅថ្នាក់ឃុំ  សង្កាត់  នឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស/ពាក់កណ្ដាលឆ្នាំ ដែលត្រូវដាក់ជូនទៅកាន់ ADB [14] ។ ប្រសិនបើដំណើរការប្ដឹងតវ៉ាដោយពាក្យសំដីផ្ទាល់មាត់គ្មានដំណោះស្រាយណាមួយដោយពេញចិត្តសម្រាប់គ្រួសារដែលរងផលប៉ះពាល់  នោះពួកគាត់អាចស្វែងរកលទ្ធភាពដាក់ពាក្យបណ្ដឹងតវ៉ាជាផ្លូវការ។ ការដាក់បណ្ដឹងជាផ្លូវការអាចធ្វើឡើងដោយផ្ទាល់មាត់ (ទៅកាន់មនុស្សចាស់ទុំក្នុងសហគមន៍ ឬតំណាងដែលនឹងកត់ត្រាពាក្យបណ្ដឹងនោះ) ឬធ្វើឡើងជាលាយលក្ខណ៍អក្សរ។ លើសពីនេះ អ្នកដែលរងផលប៉ះពាល់នឹងមានភាពបត់បែនក្នុងការបង្ហាញពីការមិនសុខចិត្ត  ឬកង្វល់របស់ពួកគេ  តាមរយៈការសរសេរដាក់ចូលក្នុងប្រអប់សំបុត្រតវ៉ា/សំណូមពរ  ដែលនឹងត្រូវបានដាក់នៅទីតាំងគម្រោង  ឬអាចលើកទឹកចិត្តពួកគេឱ្យហៅទូរសព្ទ (ដោយសារពួកគាត់ខ្លះមិនចេះអក្សរ) ឬធ្វើអ៊ីមែល ហើយលេខទំនាក់ទំនងទៅកាន់ GRC នឹងមានបង្ហាញនៅតាមទីតាំងរបស់គម្រោង។ ដំណើរការ GRM ដូចដែលបានរៀបរាប់លម្អិតនៅក្នុងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (SOP) មានដូចខាងក្រោម៖

(១).  **ជំហានទី ១៖** គ្រួសារដែលរងផលប៉ះពាល់ ហើយដែលមានកើតទុក្ខមិនសុខចិត្ត អាចដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅកាន់ប្រធានការិយាល័យស្រុកដែលអនុគម្រោងតាំងនៅ។  គ្រួសារដែលរងផលប៉ះពាល់ អាចនាំ**មនុស្សចាស់ទុំ ឬតំណាងសហគមន៍**មកសម្រុះសម្រួលដោះស្រាយបញ្ហានៅថ្នាក់ស្រុកបាន។ ក្រុមការងារ IRC-WG នឹងវាយតម្លៃប្រធានការិយាល័យស្រុកអំពីបញ្ហានេះ។ ការប្រជុំផ្សះផ្សាត្រូវតែធ្វើឡើង ហើយការសម្រេចចិត្តត្រូវបានធ្វើឡើង**ក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការ** គិតចាប់ពីថ្ងៃចុះក្នុងបញ្ជីពាក្យបណ្ដឹងដោយការិយាល័យស្រុក។ ប្រសិនបើពាក្យបណ្ដឹងត្រូវបានដោះស្រាយនៅត្រឹមថ្នាក់ស្រុកដោយការពេញចិត្តពីគ្រួសារដែលរងផលប៉ះពាល់ហើយនោះ  ក្រុមការងារ  IRC-WG  នឹងជូនដំណឹងដល់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ (DIMDM) របស់អគ្គនាយកដ្ឋាន GDR ដែលជាអ្នកពិនិត្យ និងស្វែងរកការយល់ព្រមពីអគ្គនាយក GDR សម្រាប់វិធានការដោះស្រាយសមស្រប។ គ្រួសារដែលរងផលប៉ះពាល់ នឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដោយអគ្គនាយកដ្ឋាន GDR អំពីការសម្រេចចិត្ត និងវិធានការដោះស្រាយដែលនឹងត្រូវធ្វើឡើង**ក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ** គិតចាប់ពីពេលបានទទួលលិខិតពីការិយាល័យស្រុក។  ប្រសិនបើពាក្យបណ្ដឹងត្រូវបានបដិសេធក្នុងដំណាក់កាលនេះ  ការិយាល័យស្រុកនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់គ្រួសារដែលរងផលប៉ះពាល់  ហើយប្រសិនបើពួកគាត់

---

[14] ឯកសារជំនួយស្មារតី កថាខ័ណ្ឌទី ១២ នៃបេសកកម្មកិច្ចសន្ទនាស្តីពីគោលនយោបាយការពារ ដែលបានធ្វើឡើងនៅថ្ងៃទី២២-២៣ ខែ សីហា ឆ្នាំ២០១៩

មិនពេញចិត្តនឹងលទ្ធផលនោះ ពួកគាត់អាចអាចអនុវត្តជំហានបន្ទាប់ ដោយបន្តដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅកាន់ GDR ដើម្បីដោះស្រាយ។

(២). **ជំហានទី ២៖** អគ្គនាយកដ្ឋាន GDR តាមរយៈ DIMDM របស់ខ្លួននឹងធ្វើការត្រួតពិនិត្យរួមលើពាក្យបណ្តឹង ហើយដាក់បញ្ជូនរបាយការណ៍ស្តីពីលទ្ធផលរកឃើញ ជាមួយនឹងអនុសាសន៍ពាក់ព័ន្ធ ប្រសិនបើមាន ទៅកាន់អគ្គនាយក GDR ដើម្បីស្នើសុំការសម្រេច។ វាក៏ជាការល្អដែរ ប្រសិនបើមានការចុះទៅដល់ទីកន្លែងជាក់ស្តែងដើម្បីជួប និងសិក្សាផ្ទាល់ជាមួយគ្រួសារដែលរងផលប៉ះពាល់ដែលកើតទុក្ខមិនសុខចិត្ត និងជួបជាមួយក្រុមការងារ IRC-WG ដើម្បីប្រមូលព័ត៌មានលម្អិតពាក់ព័ន្ធ។ របាយការណ៍ចុងក្រោយត្រូវតែបំពេញ**ក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ** រាប់ចាប់ពីថ្ងៃទទួលពាក្យបណ្តឹង ហើយដាក់ជូនអគ្គនាយកដ្ឋាន GDR ដើម្បីស្នើសុំការសម្រេចចុងក្រោយ**ក្នុងរយៈពេល ៥ ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានរបាយការណ៍ចុងក្រោយ។ ក្នុងករណីដែលការប្តឹងតវ៉ាទាមទារឱ្យមានកិច្ចអន្តរាគមន៍កម្រិតគោលនយោបាយ ដូច្នេះនឹងត្រូវបញ្ជូនទៅ IRC ដើម្បីសម្រេច**ក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការបន្ថែមទៀត** ដែលជាថ្ងៃផុតកំណត់សម្រាប់ការសម្រេចចិត្តចុងក្រោយ។

(៣). **ជំហានទី ៣៖** គ្រួសារដែលរងផលប៉ះពាល់ នឹងដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរជាមួយ PGRC តាមរយៈខុទ្ទកាល័យអភិបាលខេត្ត។ គ្រួសារដែលរងផលប៉ះពាល់ ឬតំណាងនឹងត្រូវបានផ្តល់ឱកាសឱ្យបង្ហាញករណីរបស់ខ្លួនក្នុងអំឡុងពេលកិច្ចប្រជុំ ហើយ PGRC អាចពិចារណាពីកាលៈទេសៈពិសេសណាមួយដើម្បីសម្រេចចិត្តលើដំណោះស្រាយជូនគ្រួសារដែលរងផលប៉ះពាល់។ អគ្គនាយកដ្ឋាន GDR នឹងបញ្ជូនអ្នកតំណាងម្នាក់ ក្នុងនាមជាសមាជិកមិនមែនបានពីការបោះឆ្នោត ដើម្បីផ្តល់ការពន្យល់សម្រាប់ការបដិសេធលើពាក្យបណ្តឹងនៅជំហានទីពីរដោយ GDR ។ ការសម្រេចចិត្តរបស់ PGRC ត្រូវតែធ្វើឡើងដោយផ្អែកលើការមូលមតិគ្នា លើកលែងតែនៅពេលដែលបញ្ហានោះជាប់ទាក់ទងនឹងគោលនយោបាយណាមួយរបស់រដ្ឋាភិបាល។ ការសម្រេចចិត្តលើបញ្ហាគោលនយោបាយរបស់រដ្ឋាភិបាលលើ LAR ត្រូវបានសម្រេចដោយ IRC ។ PGRC នឹងមាន**ពេល ៤០ ថ្ងៃនៃថ្ងៃធ្វើការ** គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ដើម្បីឈានទៅដល់ការសម្រេចចុងក្រោយ។ ការសម្រេចចិត្តរបស់ PGRC នឹងត្រូវដាក់បញ្ជូនទៅ IRC តាមរយៈ GDR ដើម្បីស្នើសុំការយល់ព្រម មុនពេលចាត់វិធានការដោះស្រាយណាមួយ។

៩៨. ការដោះស្រាយបណ្តឹងនៅដំណាក់កាលរដ្ឋបាល ត្រូវបញ្ចប់នៅជំហានទី ៣។ មិនមានការផ្តល់ជូនកម្រៃសេវា ឬការគិតថ្លៃចំណាយណាមួយទៅដល់គ្រួសារដែលរងផលប៉ះពាល់ សម្រាប់ការស្នាក់នៅ និងដំណើរការពាក្យបណ្តឹងក្រោមជំហានទី ១ ទី ២ និងទី ៣ នោះទេ។ ទោះយ៉ាងណាក៏ដោយ ដូចដែលមានចែងក្នុងច្បាប់ស្តីពីអស្សាមិករណ៍ គ្រួសារដែលរងផលប៉ះពាល់អាចដាក់ពាក្យបណ្តឹងនៅកាន់អយ្យការអមសាលាដំបូង (តុលាការខេត្ត/ក្រុង) តាមដែលអាចអនុវត្តបាន ដើម្បីស្វែងរកដំណោះស្រាយ។ ក្នុងដំណាក់កាលនេះ មិនមានការពាក់ព័ន្ធពី GDR, PRSC ឬ IRC-WG ទៀតទេ លុះត្រាតែមានដីកាសម្រេចពីតុលាការមានសមត្ថកិច្ច។ គ្រួសារដែរងផលប៉ះ

ពាល់ អាចដាក់ពាក្យបណ្ដឹងរបស់ពួកគេដោយមិនគិតថ្លៃ និងដោយគ្មានទណ្ឌកិច្ច ហើយមិនត្រូវរារាំងចំពោះការអនុវត្ត GRM ឬរារាំងពួកគេពីការស្វែងរកដំណោះស្រាយតាមប្រព័ន្ធតុលាការ ឬរដ្ឋបាលរបស់ប្រទេសនោះទេ។

៩៩. ប្រសិនបើគ្រួសារដែលរងផលប៉ះពាល់ នៅតែមិនពេញចិត្ត ហើយជឿថាពួកគាត់បានទទួលរងគ្រោះដោយសារការមិនអនុលោមតាមគោលការណ៍របស់ ADB ទោះបីជាពួកគាត់បានខិតខំប្រឹងប្រែងដោយស្មោះត្រង់ដើម្បីដោះស្រាយបញ្ហា ដោយបានធ្វើការសហការជាមួយក្រុមការងារគម្រោងយ៉ាងណាក្ដី ក្នុងករណីបែបនេះពួកគាត់ដាក់ពាក្យបណ្ដឹងផ្ទាល់ទៅការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសរបស់ ADB ឬការិយាល័យត្រួតពិនិត្យការអនុលោមតាមច្បាប់ ស្របតាមយន្តការគណនេយ្យភាពរបស់ ADB ។ ព័ត៌មាននេះអាចរកបាននៅ៖ www.adb.org/site/accountability-mechanism/main ។

**រូបភាពទី** 1. **គំនូសតាងលំហូរនៃដំណើរការ** GRM



# VIII. ការរៀបចំស្ថាប័ន និងការអនុវត្ត

## ក. ការរៀបចំស្ថាប័ន

១០០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) គឺជាភ្នាក់ងារប្រតិបត្តិ (EA)។ អគ្គនាយកដ្ឋាន GDAHP នឹងក្លាយជាភ្នាក់ងារអនុវត្ត (IA)។ អនុគម្រោង នឹងត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋាន GDAHP ដែលជាភ្នាក់ងារអនុវត្តគម្រោង (IA) តាមរយៈអង្គភាពគ្រប់គ្រងគម្រោង (PMU) ដែលនឹងគាំទ្រ GDAHP ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងគម្រោងទាំងមូល។ ទីប្រឹក្សាអនុវត្តគម្រោង (PIC) នឹងគាំទ្រអង្គភាពគ្រប់គ្រងគម្រោង (PMU) ដើម្បីធានាថានីតិវិធីត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយការអនុវត្តត្រូវបានគោរពតាមពេលវេលាដែលបានកំណត់។ ទោះយ៉ាងណាក៏ដោយ ចំពោះសកម្មភាពទាក់ទងនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) មិនមែនជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋាន GDAHP នោះទេ ប៉ុន្តែវាជាទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ (GDR) ដែលបានទទួលអាណត្តិអនុវត្តភារកិច្ចនេះ។ អគ្គនាយកដ្ឋាន GDAHP និងអង្គភាព PMU របស់ខ្លួន នឹងសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រុមការងារគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (IRC-WG) លើបញ្ហាទាំងអស់ដែលទាក់ទងនឹង ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ទី ២ (RD2) ។ នាយកដ្ឋាននេះត្រូវបានចាត់តាំងដោយអគ្គនាយកដ្ឋាន GDR នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដើម្បីឱ្យទទួលខុសត្រូវសម្រាប់គម្រោងនេះលើការអនុវត្ត DRPs ។

១០១. **អង្គភាពគ្រប់គ្រងគម្រោង (PMU) ក្រោមអគ្គនាយកដ្ឋាន GDAHP៖** អង្គភាព PMU នឹងត្រូវបានបង្កើតឡើងនៅក្រោមការគ្រប់គ្រងរបស់ GDAHP ដើម្បីអនុវត្តការងារប្រចាំថ្ងៃរបស់គម្រោងទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ អង្គភាពនេះមិនត្រូវបានតម្រូវឱ្យអនុវត្តសកម្មភាពដោះស្រាយលើផលប៉ះពាល់ដោយសារគម្រោងទេ ប៉ុន្តែវាជាកិច្ចការសម្របសម្រួលរបស់ GDR ក្នុងការអនុវត្ត DRP ដែលជាភ្នាក់ងារនាំមុខទទួលខុសត្រូវដោយផ្ទាល់ចំពោះសកម្មភាពលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) ទាំងអស់នៅក្នុងសិទ្ធិសាធារណៈ (ROW) ។ អង្គភាព PMU មានបុគ្គលិកបង្គោលទទួលបន្ទុកលើកិច្ចការនេះ ហើយមានភារកិច្ចដើម្បីអនុវត្តទំនួលខុសត្រូវជាក់លាក់របស់ PMU ទាក់ទងនឹង LAR និងសម្របសម្រួលជាមួយ GDR, PRSC និង PIU ក្នុងគ្រប់បញ្ហាទាក់ទងនឹងការធ្វើផែនការ និងការអនុវត្ត LAR ។ ភារកិច្ចជាក់លាក់របស់អង្គភាព PMU ទាក់ទងនឹង LAR រួមមានដូចខាងក្រោម៖

(១). ធ្វើការវាយតម្លៃផលប៉ះពាល់សង្គមនៃគម្រោង/អនុគម្រោង។

(២). រៀបចំសេចក្ដីព្រាងផែនការដោះស្រាយផលប៉ះពាល់លម្អិត (BRP) ដោយផ្អែកលើការតម្រឹម/ការកំណត់ព្រំប្រទល់នៃការរចនាប្លង់លម្អិតបឋម ការរៀបចំ DDR នៅពេលដែលគ្មានផលប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត នៅទីតាំងអនុគម្រោងសម្រាប់ការពិនិត្យ និងអនុម័តរបស់ GDR ។

(៣). កំណត់ព្រំដីដែលត្រូវការ តាមបណ្ដោយការតម្រឹមចុងក្រោយក្នុងរយៈពេលមួយខែ បន្ទាប់ពីការបញ្ចប់ការគូសវាសគំនូសប្លង់វិស្វកម្មលម្អិត (DED) ដោយមានការសម្របសម្រួលជាមួយ GDR ។

(៤). ផ្តល់ឱ្យ GDR នូវកាលវិភាគសាងសង់ដែលបានស្នើឡើងដែលកំណត់កាលវិភាគនៃការបញ្ចប់ LAR និងការប្រគល់ទីតាំងតាមផ្នែកទៅឱ្យអ្នកម៉ៅការ មុនកាលបរិច្ឆេទប្រគល់កិច្ចសន្យាដែលបានគ្រោងទុក។

(៥). ជូនដំណឹងដល់ GDR ក្នុងលក្ខណៈទាន់ពេលវេលា ប្រសិនបើវឌ្ឍនភាពនៃការសាងសង់ត្រូវបានរារាំងដោយបញ្ហាណាមួយទាក់ទងនឹង LAR ឬបញ្ហារាំងស្ទះដូចដែលបានរំពឹងទុក។

(៦). ជួយជ្រោមជ្រែង និងសហការជាមួយ GDR ក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលបានជួបប្រទះអំឡុងពេលអនុវត្តគម្រោង/អនុគម្រោង។

(៧). គោរពអញ្ជើញ GDR ឱ្យចូលរួមក្នុងបេសកកម្មត្រួតពិនិត្យ និងកិច្ចប្រជុំបូកសរុបជាមួយអ្នកដែលរងផលប៉ះពាល់ និងធានាថាមតិយោបល់របស់ GDR លើបញ្ហា LAR ត្រូវបានដាក់បញ្ចូលក្នុងឯកសារជំនួយស្មារតី អនុស្សរណៈនៃការយោគយល់ (MoU)និងកំណត់ហេតុនៃការពិភាក្សា (MoD)។

(៨). ធានាថាមិនមានការរំលោភបំពានលើសិទ្ធិសាធារណៈ (ROW) ទៀតទេ បន្ទាប់ពីការប្រគល់ភារកិច្ចបន្តដោយ GDR ចំពោះដីសម្រាប់គម្រោង/អនុគម្រោង។

(៩). ធានាថាអនុគម្រោងអនុលោមតាមលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស។

(១០). ប្រមូល វិភាគ និងរាយការណ៍ព័ត៌មានពាក់ព័ន្ធដែលទាក់ទងនឹងផលប៉ះពាល់នៃការតាំងទីលំនៅថ្មីដែលមិនបានរំពឹងទុក និង/ឬផលប៉ះពាល់ដល់ជនជាតិដើមភាគតិច ដែលបណ្តាលមកពីការអនុវត្តគម្រោង (ប្រសិនបើមាន)។

(១១). រាយការណ៍ភ្លាមៗនូវផលប៉ះពាល់ IR និង/ឬ IP ដែលមិនបានរំពឹងទុកទៅកាន់ GDR និង ADB ហើយចូលរួមក្នុងការបង្កើតវិធានការកាត់បន្ថយសម្រាប់ផលប៉ះពាល់ទាំងនោះ និងធ្វើបច្ចុប្បន្នកម្មជូន ADB លើស្ថានភាពនៃករណីបែបនេះក្នុងលក្ខណៈទាន់ពេលវេលា។

(១២). ពិនិត្យ និងបញ្ចប់ការចាត់ថ្នាក់ប្រភេទអនុគម្រោងសម្រាប់ IR និង IP ។

(១៣). ចូលរួម និងរួមចំណែកតាមតម្រូវការក្នុងការរៀបចំ RPs, DDRs, IPPs ដែលពាក់ព័ន្ធ។

(១៤). ធានាថាផែនការគាំពារសង្គមទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្ម ឬរៀបចំដោយផ្អែកលើ DED និងស្របតាមក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ និងក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដែលបានរៀបចំសម្រាប់
គម្រោង។

(១៥). ធានាថាផែនការគាំពារសង្គម ត្រូវបានបញ្ចូលក្នុងឯកសារដេញថ្លៃ និងកិច្ចសន្យាការងារសាងសង់។

(១៦). ផ្តល់ការត្រួតពិនិត្យជារួមលើទិដ្ឋភាពនៃការគ្រប់គ្រងការគាំពារសង្គមនៃអនុគម្រោង។

(១៧). ធានាឱ្យមានការលាតត្រដាងទាន់ពេលវេលានៃព័ត៌មានអំពី RPs, DDRs, IPPs ចុងក្រោយនៅតាមទីតាំង និងក្នុងទម្រង់ដែលអាចទទួលបានសម្រាប់សាធារណៈជន និងអ្នកដែលរងផលប៉ះពាល់។

(១៨). ផ្តល់ធាតុចូលដែលទាក់ទងនឹងការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យការគាំពារសង្គមទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស។

(១៩). បញ្ជូនរបាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមពាក់កណ្តាលឆ្នាំ និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទៅកាន់ ADB ។

១០២. អង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត នឹងទទួលខុសត្រូវចំពោះ៖

(១). ទទួលខុសត្រូវលើការអនុវត្តគម្រោង/អនុគម្រោងនៅថ្នាក់ខេត្ត ស្រុក និងភូមិ។
(២). ដឹកនាំគម្រោង/អនុគម្រោងថ្នាក់ខេត្ត និងការរៀបចំធ្វើផែនការ និងថវិកាប្រចាំឆ្នាំ។
(៣). ដាក់ពាក្យស្នើសុំដកប្រាក់ទៅអង្គភាព PMU រក្សាឯកសារគាំទ្រនានា ដាក់បញ្ជូនរាល់របាយការណ៍ទាំងអស់ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុ។
(៤). សម្របសម្រួលបេសកកម្មត្រួតពិនិត្យគម្រោង និងរៀបចំរបាយការណ៍វឌ្ឍនភាព។
(៥). គាំទ្រអង្គភាព PMU ដើម្បីធានាការអនុលោមតាមគោលការណ៍ការពារ ការរៀបចំឯកសារស្តីពីការអនុវត្តកាតព្វកិច្ចការពារ ការរាយការណ៍ និងការត្រួតពិនិត្យ និងការអនុវត្ត និងការគ្រប់គ្រង GRM ។
(៦). គាំទ្រអង្គភាព PMU ដើម្បីអនុវត្តការស្ទង់មតិមូលដ្ឋាន ពាក់កណ្តាលអាណត្តិ និងលទ្ធផល។
(៧). បង្កើតប្រព័ន្ធត្រួតពិនិត្យការអនុវត្តគម្រោងកម្រិតខេត្ត រួមទាំងគេហទំព័រសម្រាប់លាតត្រដាងព័ត៌មានអំពីគម្រោង។
(៨). គាំទ្រអង្គភាព PMU ដើម្បីត្រួតពិនិត្យអ្នកម៉ៅការដែលកំពុងអនុវត្តក្រោមលទ្ធផល ១, ២ និង ៣ នៅថ្នាក់ខេត្ត។
(៩). គ្រប់គ្រងការវាយតម្លៃលើសំណើអនុគម្រោងស្តីពីការបែងចែកមូលនិធិហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant ) សម្រាប់វិស័យបសុសត្វ។
(១០). គាំទ្រអគ្គនាយកដ្ឋាន GDAHP ដើម្បីអនុវត្តសាកល្បង និងដាក់ឱ្យដំណើរការប្រព័ន្ធកំណត់អត្តសញ្ញាណសត្វ និងការតាមដានសត្វ (LITS) ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ទីរពិសោធន៍ ប្រព័ន្ធព័ត៌មានផលិតកម្មសត្វ និងសុខភាពសត្វ ការអនុវត្តការគ្រប់គ្រងល្អ និងកម្មវិធីអនុវត្តការចិញ្ចឹមសត្វល្អ។
(១១). គ្រប់គ្រងការអនុវត្តផលិតកម្មចំណីសត្វ ការបង្កាត់ពូជសត្វ និងកម្មវិធីបណ្តុះបណ្តាល និងការចេញវិញ្ញាបនបត្របញ្ជាក់ទទួលស្គាល់ភ្នាក់ងារសុខភាពសត្វភូមិ (VAHW) ។

១០៣. **គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោង (IRC)៖** IRC គឺជាស្ថាប័នធ្វើការសម្រេចចិត្ត និងត្រួតពិនិត្យសម្រាប់សកម្មភាព LAR ។ ស្ថាប័ននេះមានអាណត្តិពិនិត្យ និងវាយតម្លៃផលប៉ះពាល់នៃការតាំងទីលំនៅថ្មី និងលទ្ធកម្មដីធ្លី សម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា។ IRC គឺជាអង្គភាពសមូហភាព ដែលដឹកនាំជាអចិន្ត្រៃយ៍ និងដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដែលមានសមាសភាពសមាជិកមកពីក្រសួងពាក់ព័ន្ធផ្សេងៗ។ IRC អនុវត្តតួនាទីរបស់ខ្លួនតាមរយៈក្រុមការងារ IRC-WG ដែលត្រូវបានបង្កើតឡើងដោយ MEF សម្រាប់គម្រោងវិនិយោគសាធារណៈនីមួយៗ។ ទំនួលខុសត្រូវសំខាន់ៗរបស់ IRC រួមមាន៖

(១). ផ្តល់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងធានាថា LAR អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ។
(២). ធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងក្រសួងពាក់ព័ន្ធ អាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងអគ្គនាយកដ្ឋាន GDR ក្នុងការអនុវត្ត LAR ។
(៣). ពិនិត្យ និងអនុម័តផែនការ DRP និងគាំទ្រផែនការ DRP មុនពេលដាក់ស្នើទៅកាន់ ADB ដើម្បីពិនិត្យ និងអនុម័ត។
(៤). ផ្តួចផ្តើមបង្កើត PGRC។
(៥). ផ្តល់ការណែនាំជារួមលើការអនុវត្តច្បាប់ និងបទប្បញ្ញត្តិសម្រាប់ LAR និងស្នើឱ្យធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។

១០៤. **អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR)៖** GDR គឺជាលេខាធិការដ្ឋានបច្ចេកទេសអចិន្ត្រៃយ៍នៃ IRC និងជាភ្នាក់ងារនាំមុខគេសម្រាប់ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យ និងការរាយការណ៍អំពី LAR ។ GDR នឹងអនុវត្តសកម្មភាពក្រោមអនុគម្រោងកែលម្អប្រព័ន្ធបណ្តាញលូខេត្តកំពត តាមរយៈនាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ២ (RD2) របស់ខ្លួន។ ចំពោះបញ្ហានេះ កិច្ចការលម្អិតនៃ RD2 GDR រួមមាន ៖

(១). សម្របសម្រួល និងសហការជាមួយក្រសួងពាក់ព័ន្ធ អគ្គនាយកដ្ឋាន GDAHP និងភ្នាក់ងារផ្សេងទៀតដែលពាក់ព័ន្ធនឹងសកម្មភាព LAR ។
(២). ធ្វើការពិគ្រោះយោបល់ជាសាធារណៈ និងការពិភាក្សាជាក្រុមជាមួយបុគ្គលដែលរងផលប៉ះពាល់ និងក្រុមដែលងាយរងគ្រោះ។
(៣). រៀបចំផែនការ DRP សម្រាប់អនុគម្រោង ហើយដាក់ជូនទៅកាន់ ADB ដើម្បីពិនិត្យ និងទទួលយក។
(៤). បង្កើតលក្ខខណ្ឌការងារ (ToR) និងជ្រើសរើសអ្នកស្ទាបស្ទង់តម្លៃជំនួស។
(៥). រៀបចំ និងធានាថវិកាចាំបាច់សម្រាប់ការអនុវត្តផែនការ DRP។
(៦). គណនា រៀបចំកិច្ចសន្យា និងទូទាត់សំណងសម្រាប់គ្រួសារដែលរងផលប៉ះពាល់នីមួយៗដោយផ្អែកលើម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបានដែលមាននៅក្នុងផែនការ DRP។
(៧). អនុវត្តសកម្មភាព LAR ទាំងអស់ ដោយអនុលោមតាមផែនការ DRP។
(៨). ធានាដំណើរការត្រឹមត្រូវនៃយន្តការ GRM ។
(៩). ត្រួតពិនិត្យ តាមដាន និងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការ DRP។
(១០). ធ្វើលិខិតប្រគល់ដីទៅកាន់អគ្គនាយកដ្ឋាន GDAHP ជាមួយនឹងច្បាប់ចម្លងទៅកាន់ ADB។
(១១). រៀបចំ និងដាក់ជូន ADB នូវរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងរបាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមពាក់កណ្តាលឆ្នាំ។

(១២). រៀបចំ ព្រមព្រៀងជាមួយ ADB និងអនុវត្តផែនការសកម្មភាពកែតម្រូវ ប្រសិនបើមាន អំឡុងពេល អនុវត្ត និងបញ្ជូនរបាយការណ៍អនុវត្តផែនការសកម្មភាពកែតម្រូវទៅកាន់ ADB សម្រាប់ការព្រមព្រៀង និង បញ្ចេញព័ត៌មាន។

(១៣). រៀបចំសិក្ខាសាលាផ្សព្វផ្សាយការយល់ដឹងសម្រាប់អគ្គនាយកដ្ឋាន GDAHP ក្រសួងពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងអ្នកម៉ៅការសំណង់ស្តីពីការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដូចមានចែងក្នុងផែនការ DRP ។

(១៤). បម្រើតួនាទីជាមជ្ឈមណ្ឌលធនធានចំណេះដឹងចម្បងសម្រាប់ការងារដោះស្រាយផលប៉ះពាល់ ដោយសារគម្រោង ឬអនុគម្រោង។

១០៥. លើសពីនេះទៀតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ (DIMDM) នៃ GDR ទទួលខុសត្រូវក្នុងការអនុវត្តសវនកម្មផ្ទៃក្នុងលើការអនុវត្តផែនការ DRP ការផ្ទៀងផ្ទាត់ និងការកំណត់សុពលភាពលើការអនុលោមតាមសិទ្ធិទទួលបាន និងការទូទាត់សំណងជាមួយនឹងបទប្បញ្ញត្តិនៃម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបានដែលកំណត់នៅក្នុងផែនការ DRP ។ តួនាទីរបស់អង្គភាពនេះ គឺដើម្បីពង្រីកវិសាលភាពលើការផ្ទៀងផ្ទាត់ផ្ទៃក្នុងចំពោះសកម្មភាព LAR ទាំងអស់សម្រាប់ការអនុលោមតាមបទប្បញ្ញត្តិនៅក្រោមក្របខ័ណ្ឌផែនការ DRP ដែលបានព្រមព្រៀង ហើយរាយការណ៍ដោយផ្ទាល់ទៅអគ្គនាយកនៃ GDR ។ លើសពីនេះ អង្គភាពនេះ ទទួលខុសត្រូវលើការកត់ត្រា និងពិនិត្យរាល់ពាក្យបណ្តឹង និងការទាមទារតវ៉ាដែលបានធ្វើឡើងដោយអ្នកដែលត្រូវផ្លាស់ទី ទទួលខុសត្រូវលើការស៊ើបអង្កេតករណីរបស់អ្នកដែលត្រូវផ្លាស់តីទាំងនោះ និងរៀបចំជាអនុសាសន៍ស្តីពីការអនុលោមតាម សម្រាប់ដាក់ជូនអគ្គនាយកនៃ GDR ។ បន្ទាប់ពីការទូទាត់សំណង និងសិទ្ធិទទួលបានផ្សេងទៀតត្រូវបានបញ្ចប់ អគ្គនាយកដ្ឋាន GDR នឹងរៀបចំនូវរបាយការណ៍អនុវត្តផែនការ DRP ហើយដាក់ជូន ADB ដើម្បីទទួលបានការសម្រេច "គ្មានការជំទាស់" សម្រាប់ការងារសាងសង់។ លើសពីនេះ DIMDM នឹងរៀបចំ និងបញ្ជូនរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទៅអគ្គនាយកដ្ឋាន GDAHP និងរបាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមពាក់កណ្តាលឆ្នាំទៅកាន់ ADB ដែលជារបាយការណ៍ចុងក្រោយសម្រាប់ពិនិត្យ និងលាតត្រដាង។

១០៦. **ការិយាល័យរដ្ឋបាលសុរិយោដី៖** ការិយាល័យរដ្ឋបាលសុរិយោដី (CAO) ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ទទួលខុសត្រូវក្នុងការចេញឯកសារប័ណ្ណកម្មសិទ្ធិ រួមមាន លិខិតបញ្ជាក់សិទ្ធិប្រើប្រាស់ដីធ្លី ប្លង់រឹង និងសម្បទានដីសង្គមកិច្ច ដែលជាផ្នែកមួយនៃការជានាសិទ្ធិកាន់កាប់ដីធ្លីសម្រាប់អ្នកដែលគ្មានដី និងការចេញឯកសារប័ណ្ណកម្មសិទ្ធិសម្រាប់ដីឡូតិ៍ដែលបានធ្វើលទ្ធកម្មតាមការចង់បានពីអគ្គនាយកដ្ឋាន GDAHP ។

១០៧. **អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ (ស្រុកខណ្ឌ ឃុំសង្កាត់ និងភូមិ)៖** ស្រុកខណ្ឌ ឃុំសង្កាត់ និងភូមិ ដែលមានទីតាំងអនុគម្រោង នឹងធ្វើការសម្របសម្រួល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារ PRSC-WG និង IRC លើការរៀបចំ និងការអនុវត្តផែនការ DRP ។ តួនាទី និងទំនួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានទាំងនេះ រួមមាន៖

(១). កំណត់ និងសម្របសម្រួលទីកន្លែងសម្រាប់ការប្រជុំពិគ្រោះយោបល់សាធារណៈ និងអញ្ជើញគ្រួសារដែលរងផលប៉ះពាល់ ឱ្យចូលរួមក្នុងសកម្មភាពពិគ្រោះយោបល់ដូចជា DMS, SES, RCS និងសកម្មភាពដែលទាក់ទងនឹងការតាំងទីលំនៅថ្មីផ្សេងទៀត។

(២). អនុវត្តយន្តការ GRM។

(៣). ជួយជ្រោមជ្រែងក្រុមការងារ IRC-WG, PRSC-WG និង GDR ក្នុងការបង្កើតវិធានការសមស្របដើម្បីជួយដល់គ្រួសារដែលរងផលប៉ះពាល់ និងក្រុមដែលងាយរងគ្រោះដោយសារអនុគម្រោង។

១០៨. **ក្រុមការងារនៃគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោង (IRC-WG)៖** ក្រុមការងា IRC-WG នឹងអនុវត្តសកម្មភាព LAR ប្រចាំថ្ងៃ ក្រោមគម្រោងដែលដឹកនាំដោយអគ្គនាយករង/ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនៃអគ្គនាយកដ្ឋាន GDR និងរួមមានសមាសភាពបុគ្គលិកបច្ចេកទេស PMU នៃ GDAHP, GDAHP/PMU បុគ្គលិកនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោង និងបុគ្គលិកនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រុមការងារ IRC-WG នឹងទទួលខុសត្រូវលើរាល់ការងារចុះមូលដ្ឋានទាំងអស់ ក្រោមការត្រួតពិនិត្យរបស់ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោង ក្រោមការណែនាំ និងដឹកនាំរួមរបស់អគ្គនាយកនៃអគ្គនាយកដ្ឋាន GDR ។

១០៩. **អនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងថ្នាក់ខេត្ត (PRSC)៖** អនុគណៈកម្មាធិការ PRSC នឹងត្រូវបានបង្កើតឡើងដោយអភិបាលខេត្តតាមសំណើរបស់ IRC នៅក្នុងខេត្តគោលដៅនីមួយៗរបស់អនុគម្រោងដែលមានផលប៉ះពាល់ដោយសារ LAR ។ តួនាទីរបស់ PRSC មានដូចខាងក្រោម៖

(១). សម្របសម្រួល និងគាំទ្រដល់ GDR, IRC, និង IRC-WG សម្រាប់សកម្មភាព LAR នៅកម្រិតមូលដ្ឋាន។

(២). ធានាថាអាជ្ញាធរខេត្ត និងមូលដ្ឋានពាក់ព័ន្ធទាំងអស់ផ្តល់ការគាំទ្រចាំបាច់សម្រាប់ LAR ។

(៣). គ្រប់គ្រងកិច្ចប្រជុំពិគ្រោះយោបល់សាធារណៈនៅថ្នាក់ខេត្ត។

(៤). ត្រួតពិនិត្យ និងតាមដានការអនុវត្តការងាររបស់ក្រុមការងារ PRSC-WG៕

(៥). ទទួលខុសត្រូវលើការទូទាត់ប្រកបដោយគណនេយ្យភាពចំពោះការផ្តល់សំណងនៅថ្នាក់ខេត្ត។

(៦). ជួយជ្រោមជ្រែងដល់ក្រុមការងារ IRC-WG ក្នុងការបង្កើតវិធានការដើម្បីជួយដល់គ្រួសារដែលងាយរងគ្រោះដោយសារអនុគម្រោង។

១១០. **ក្រុមការងារនៃអនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងថ្នាក់ខេត្ត (PRSC-WG)៖** ក្រុមការងារ PRSC-WG នឹងត្រូវបានបង្កើតឡើងដោយអភិបាលខេត្ត នៅក្នុងខេត្តនីមួយៗនៃអនុគម្រោងដែលមានផលប៉ះពាល់ដោយសារ LAR និងទទួលខុសត្រូវជាចម្បងចំពោះមុខងារបច្ចេកទេសរបស់ PRSC ដោយធ្វើការជាមួយក្រុមការងារ IRC-WG ក្នុងការអនុវត្តសកម្មភាព LAR នៅថ្នាក់ខេត្ត។ ក្រោមកិច្ចសហការពីក្រុមការងារថ្នាក់ខេត្ត និងស្រុក ក្រុមការងារ PRSC-WG ត្រូវទទួលខុសត្រូវលើមុខងារ ដូចខាងក្រោម៖

(១). សម្របសម្រួលយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដោយធានាថាសាធារណៈជន ជាពិសេសគ្រួសារដែលរងផលប៉ះពាល់អាចទទួលបានព័ត៌មានស្មើៗស្តីពីការអភិវឌ្ឍន៍ណាមួយទាក់ទងនឹងអនុគម្រោង និងសកម្មភាពដោះស្រាយផលប៉ះពាល់ផ្សេងៗ។

(២). ចូលរួមក្នុងដំណើរការ DMS និងការធ្វើបច្ចុប្បន្នកម្មជំរឿននៃគ្រួសារដែលរងផលប៉ះពាល់ រួមទាំងការធ្វើបច្ចុប្បន្នកម្មនៃសិទ្ធិទទួលបាន។

(៣). ដឹកនាំការជ្រើសរើស ការទិញលក់ និងការរៀបចំដីជំនួស រួមទាំងការរៀបចំកាលវិភាគសម្របសម្រួលលើការផ្តល់សំណង និងសិទ្ធិទទួលបានផ្សេងៗទៀត ការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋ ការប្រមូលផលដំណាំ និងការចាប់ផ្តើមការងារសាងសង់នៅក្នុងផ្នែកជាក់លាក់មួយលើចំណែកផ្លូវទៅកាន់ទីតាំងគម្រោង។

(៤). ដឹកនាំការផ្តល់សំណង និងសិទ្ធិទទួលបានផ្សេងទៀតដល់គ្រួសារដែលរងផលប៉ះពាល់។

(៥). ទទួល និងចាត់ការលើពាក្យបណ្តឹង និងការទាមទារតវ៉ារបស់គ្រួសារដែលរងផលប៉ះពាល់ ដោយអនុលោមតាមគោលការណ៍ដោះស្រាយរបស់គម្រោង។

(៦). កត់ត្រាការប្រជុំជាសាធារណៈទាំងអស់ បណ្តឹងតវ៉ា និងសកម្មភាពដែលបានធ្វើឡើង ដើម្បីដោះស្រាយបណ្តឹង និងការទាមទារតវ៉ា។

១១១. **ទីប្រឹក្សាអនុវត្តគម្រោង (PIC)៖** ទីប្រឹក្សា PIC នឹងជួយដល់ GDAHP ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពការងារសាងសង់ ហើយនឹងធានាថាអ្នកម៉ៅការគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យារបស់ខ្លួនទាក់ទងនឹងការបញ្ចៀស និង/ឬកាត់បន្ថយផលប៉ះពាល់នៃការតាំងទីលំនៅថ្មី។ តួនាទីរបស់ PIC គឺតិចតួចបំផុតក្នុងការអនុវត្តផែនការ DRP ហើយទាក់ទងតែទៅនឹងការចងក្រងតម្រូវការរបាយការណ៍សម្រាប់គម្រោង និងការរាយការណ៍ទៅ RD2 នៃ GDR លើបញ្ហារាំងស្ទះដែលបណ្តាលមកពីការតាំងទីលំនៅថ្មីក្នុងដំណាក់កាលសាងសង់នៃគម្រោង/អនុគម្រោង។

## ខ. ភាលវិភាគនៃការអនុវត្ត

១១២. គម្រោងនេះត្រូវបានរំពឹងថា នឹងអនុវត្តសម្រាប់រយៈពេល ៧ ឆ្នាំ ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០៣០។

១១៣. លទ្ធកម្មនៃការងារសាងសង់ អាចចាប់ផ្តើមបន្ទាប់ពីបញ្ចប់ការរចនាប្លង់វិស្វកម្មលម្អិត (DED) និងស្របពេលដែលផែនការ DRP កំពុងស្ថិតនៅក្រោមការរៀបចំដោយ GDR ។ គេរំពឹងថាការធ្វើ DMS នឹងត្រូវបញ្ចប់ក្នុងរយៈពេល ២ ខែបន្ទាប់ពីការកំណត់ព្រំដីដែលត្រូវការសម្រាប់អនុគម្រោង ឬសមាសភាគរបស់អនុគម្រោង។ ការរៀបចំផែនការ DRP និងការព្រមព្រៀងពី IRC និង ADB ត្រូវបានរំពឹងថាបញ្ចប់រួចរាល់ក្នុងរយៈពេល ៣ ខែបន្ទាប់ពីនោះ។ ការអនុវត្តផែនការ DRP នឹងមានរយៈពេលចាប់ពី ៣ ទៅ ៦ ខែ អាស្រ័យលើចំនួនអ្នកដែលត្រូវផ្លាស់ទី និងវិសាលភាពនៃផលប៉ះពាល់ដោយសារ LAR ។

១១៤. ទោះជាយ៉ាងណាក៏ដោយ ផែនការ DRP នៃអនុគម្រោងត្រូវតែអនុម័តដោយ IRC និង ADB មុនពេលទទួលបានកិច្ចសន្យាទទួលមូលនិធិណាមួយសម្រាប់ការសាងសង់ក្រោមអនុគម្រោង។ ដូច្នេះគ្មានកិច្ចសន្យាណាមួយអាចត្រូវបានចុះហត្ថលេខាសម្រាប់អនុគម្រោងណាមួយទេ លុះត្រាតែផែនការ DRP សម្រាប់អនុគម្រោងនោះ ត្រូវបានអនុម័តជាមុន។

១១៥. ការងារសាងសង់ក្រោមកិច្ចសន្យាណាមួយ អាចចាប់ផ្តើមបានលុះត្រាមុខចំណាយទូទាត់សំណងក្នុងតម្លៃជំនួសពេញលេញ និងសិទ្ធិទទួលបានផ្សេងទៀត ត្រូវបានរាយតារាងយ៉ាងត្រឹមត្រូវនៅក្នុងផែនការ DRP ចំណែកកម្មវិធីស្តារប្រាក់ចំណូលឡើងវិញត្រូវតែរៀបចំរួចរាល់ប្រកបដោយលក្ខណៈទូលំទូលាយ ជាមួយនឹងថវិកាគ្រប់គ្រាន់សម្រាប់ដោះស្រាយលើផលប៉ះពាល់ដោយសារ LAR ណាមួយ។ ក្នុងករណីដែលបុគ្គលត្រូវផ្លាស់ទីណាមួយបដិសេធការផ្តល់សំណង ឬទោះបីជាមានពាក្យបណ្តឹងដែលត្រូវបានដាក់សុំដំណោះស្រាយក្រោមយន្តការ GRM សម្រាប់អនុគម្រោងក៏ដោយ ក៏មិនអាចរារាំងចំពោះការចាប់ផ្តើមការងារសាងសង់បានដែរ។ ការងារសាងសង់ ក៏អាចចាប់ផ្តើមនៅក្នុងអនុគម្រោងណាមួយ ឬផ្នែកណាមួយដែលមិនមានផលប៉ះពាល់បែបនេះ។

# IX. ថវិកា និងការផ្តល់ហិរញ្ញប្បទាន

## ក. ថវិកា និការផ្តល់ហិរញ្ញប្បទាន

១១៦. សម្រាប់គម្រោងនេះ ការចំណាយលើលទ្ធកម្មដីធ្លី ការផ្តល់សំណង ជំនួយសម្រាប់ការតាំងលំនៅឡើងវិញ រួមទាំងការចំណាយលើការស្តារប្រាក់ចំណូល ឬកម្មវិធីជំនួយផ្សេងទៀតប្រសិនបើចាំបាច់ នឹងត្រូវបានផ្តល់ហិរញ្ញប្បទានពីថវិកាជាតិដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) ដែលជាមូលនិធិបដិភាគសម្រាប់គម្រោងនេះ។ ការចំណាយលើការរៀបចំផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) នឹងត្រូវបានឆ្លើយតបពីថវិការដ្ឋបាល និងប្រតិបត្តិការទាំងមូលរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR)។ មិនតម្រូវឱ្យមានហិរញ្ញប្បទានពីប្រាក់កម្ចី និងជំនួយឥតសំណងនៃគម្រោងដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នោះទេ។ ចំណែកថវិកាប៉ាន់ស្មាន នឹងត្រូវបានរៀបចំដោយផ្អែកលើអត្រាមុខចំណាយចុងក្រោយបំផុតនៅក្នុងតំបន់អនុគម្រោង បន្ទាប់ពីការបញ្ចប់ជំរឿនបឋម និងបញ្ជីសារពើភណ្ឌនៃទ្រព្យសកម្មដែលរងផលប៉ះពាល់ និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីព្រាងផែនការតាំងទីលំនៅជាថ្មី(RP)។ ថវិកាចុងក្រោយសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) នឹងត្រូវបានរៀបចំបន្ទាប់ពីការបញ្ចប់ការអង្កេតដោយវាស់វែងលម្អិត (DMS) សារពើភ័ណ្ឌនៃការខាតបង់ (IOL) ដែលបានធ្វើបច្ចុប្បន្នកម្ម និងការសិក្សាតម្លៃជំនួស (RCS) ដែលនឹងត្រូវដាក់បញ្ចូលនៅក្នុងផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP)។

## ខ. លំហូរនៃមូលនិធិសម្រាប់សំណង និងជំនួយសាច់ប្រាក់

១១៧. បន្ទាប់ពីព្រមព្រៀងលើផែនការ DRP និងថវិកា និងមុនពេលពិគ្រោះយោបល់ជាមួយគ្រួសារដែលរងផលប៉ះពាល់ អគ្គនាយកដ្ឋាន GDR នឹងរៀបចំផែនការសំណង និងការពិគ្រោះយោបល់ និងព្រាងកិច្ចសន្យាសម្រាប់ការទូទាត់សំណងដល់គ្រួសារដែលរងផលប៉ះពាល់ទាំងអស់។ ការទូទាត់សំណងនឹងត្រូវធ្វើឡើងយ៉ាងពេញលេញបន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខារួច ហើយការបញ្ចប់ការទូទាត់ទាំងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការអនុវត្តផែនការ DRP សម្រាប់ដាក់ជូនទៅកាន់ ADB ។

១១៨. អគ្គនាយកដ្ឋាន GDR នឹងត្រូវទទួលខុសត្រូវ និងទទួលបន្ទុកចំពោះមុខងារគ្រប់គ្រងហិរញ្ញវត្ថុទាំងអស់ដែលទាក់ទងនឹងការប្រើប្រាស់មូលនិធិដែលបានលៃទុករួចរាល់។ រាជរដ្ឋាភិបាលនឹងបង្កើតគណនីមួយ ដែលហៅថាមូលនិធិបដិភាគសម្រាប់គណនីគម្រោងនៅធនាគារជាតិនៃកម្ពុជា។ មូលនិធិសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មី (LAR) ត្រូវបានផ្តល់ជូនអគ្គនាយកដ្ឋាន GDR ចេញពីគណនីមូលនិធិបដិភាគនេះ។ ថវិកាត្រូវបានរៀបចំដោយអគ្គនាយកដ្ឋាន GDR ហើយដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដើម្បីអនុម័ត បន្ទាប់ពីផែនការ DRP ត្រូវបានអនុម័តដោយ IRC និងត្រូវបានជម្រះដោយ ADB ។ អគ្គនាយកដ្ឋាន GDR នឹងដាក់សំណើសម្រាប់ការបញ្ចេញថវិកាដែលបានបែងចែកទៅកាន់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ដែលនឹងដំណើរការសំណើ និងដាក់ជូនទៅកានអគ្គនាយកដ្ឋានរតនាគារជាតិ។ មូលនិធិនានាត្រូវបានបញ្ចេញ និងដាក់ចូលទៅក្នុងគណនីដែលកំណត់ដោយគម្រោង ដែលបង្កើតឡើងដោយអគ្គនាយកដ្ឋាន GDR សម្រាប់អនុគម្រោងនៅ

ធនាគារជាតិនៃកម្ពុជា។ មូលនិធិត្រូវបានបញ្ចេញចេញពីគណនីដែលបានកំណត់របស់គម្រោង តាមដែលចាំបាច់ និងផ្តល់ទៅឱ្យគណៈកម្មការ PRSC ដែលទទួលខុសត្រូវលើការទូទាត់ទៅឱ្យគ្រួសារដែលរងផលប៉ះពាល់។ ការទូទាត់សំណងនឹងត្រូវបានធ្វើឡើងនៅទីកន្លែងសាធារណៈ ដោយក្រុមការងារ PRSC-WG ក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារ IRC-WG។

១១៩. គម្រោងនានាដែលផ្តល់ហិរញ្ញប្បទានពីម្ចាស់ជំនួយកន្លងមក រួមទាំងពី ADB ផង មិនធ្លាប់ជួបប្រទះនូវការលំបាកណាមួយនៅក្នុងភាពអាចរកបាន និងការបញ្ចេញទាន់ពេលវេលានៃថវិកាសម្រាប់សកម្មភាព LAR ។ ចំណែកគម្រោងនេះ ក៏ទំនងជាមិនជួបការលំបាកណាមួយដែរចំពោះភាពអាចរកបានទាន់ពេលវេលា និងការបញ្ចេញនៃថវិកាសម្រាប់ការអនុវត្តសកម្មភាព LAR ។

# រូបភាពទី 2. ពីដ្យាក្រាមលំហូរមូលនិធិ



# X. ការត្រួតពិនិត្យ និងការរាយការណ៍

១២០. ស្របពេលដែលអគ្គនាយកដ្ឋាន GDAHP/PPMU នឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តរួមលើគម្រោង និងអនុគម្រោង នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ (DIMDM) នៃអគ្គនាយកដ្ឋាន GDR នឹងទទួលខុសត្រូវដោយផ្ទាល់ចំពោះការត្រួតពិនិត្យ និងរាយការណ៍លើការអនុវត្តផែនការ DRP។ ដោយសារផលប៉ះពាល់នៃគម្រោងមិនត្រូវបានគេចាត់ទុកថាសំខាន់ ដូច្នេះមិនចាំបាច់តម្រូវឱ្យមានសវនកម្មពីខាងក្រៅឡើយ។

## សវនកម្មផ្ទៃក្នុង

១២១. រាល់សវនកម្មផ្ទៃក្នុង និងការរាយការណ៍អំពីការអនុវត្តផែនការ DRP នឹងត្រូវបានធ្វើឡើងដោយ DIMDM នៃអគ្គនាយកដ្ឋាន GDR ស្របតាមគោលការណ៍ដែលបានព្រមព្រៀងនៅក្នុង LARF និង RPs នេះ និងសូចនាករត្រួតពិនិត្យ។ នាយកដ្ឋាន DIMDM នៃ GDR នឹងធ្វើការត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំ។ គោលបំណងនៃការត្រួតពិនិត្យផ្ទៃក្នុងគឺដើម្បី (១). វាយតម្លៃ និងរាយការណ៍អំពីវឌ្ឍនភាពក្នុងការរៀបចំ និងការអនុវត្តផែនការ DRP, (២). កំណត់បញ្ហា និងហានិភ័យ ប្រសិនបើមាន និងវិធានការកាត់បន្ថយ, និង (៣). វាយតម្លៃថាតើសំណង និងជំនួយសម្រាប់ស្តារនីតិសម្បទា ស្របតាមបទប្បញ្ញត្តិក្រោមផែនការ DRP ដែរឬទេ។ ការត្រួតពិនិត្យផ្ទៃក្នុងរួមនឹងលទ្ធផល នឹងត្រូវបានរាយការណ៍ទៅកាន់ IRC និង GDAHP/PMU ជាប្រចាំត្រីមាស។ ក្រុមការងារ IRC-WG និង PRSC-WG នឹងប្រមូលទិន្នន័យ និងព័ត៌មានអំពីវឌ្ឍនភាពនៃ LAR ដែលបានពីមូលដ្ឋាន ហើយរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំខែទៅកាន់ RD2 ។ នាយកដ្ឋាន RD2 នឹងចងក្រងរបាយការណ៍បានពីមូលដ្ឋាន និងរៀបចំរបាយការណ៍រួមស្តីពីការអនុវត្តផែណការ DRP ជារៀងរាល់ខែ។ របាយការណ៍នេះ នឹងត្រូវបានដាក់ជូន DIMDM ដែលនឹង (១). ពិនិត្យមើលរបាយការណ៍វឌ្ឍនភាពប្រចាំខែ រួមទាំងការដាក់បេសកកម្មចុះមូលដ្ឋាន ដើម្បីផ្ទៀងផ្ទាត់វឌ្ឍនភាព និងសុពលភាពនៃទិន្នន័យ និងព័ត៌មាន ប្រសិនបើចាត់ទុកថាចាំបាច់, និង (២). ចងក្រងរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាសសម្រាប់ដាក់ជូនទៅអគ្គនាយកនៃ GDR ។ អគ្គនាយកដ្ឋាន GDR នឹងផ្តល់ឱ្យអគ្គនាយក GDAHP នូវរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសនៅត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ចាប់ពីចុងត្រីមាសនីមួយៗ។ នាយកដ្ឋាន DIMDM នឹងចងក្រងរបាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមពាក់កណ្តាលឆ្នាំ ហើយដាក់បញ្ជូនទៅកាន់ ADB សម្រាប់ការលាតត្រដាងនៅលើគេហទំព័ររបស់ ADB នៅត្រឹមថ្ងៃទី ៣០ នៃខែបន្ទាប់ ចាប់ពីចុងត្រីមាសចុងក្រោយសម្រាប់របាយការណ៍ពាក់កណ្តាលប្រចាំឆ្នាំដែលស្ថិតក្នុងការចោទសួរ។

១២២. តារាងសូចនាករត្រួតពិនិត្យផ្ទៃក្នុង គឺមាន**នៅក្នុងឧបសម្ព័ន្ធទី 3** នៃក្របខ័ណ្ឌស្តីការដោះស្រាយផលប៉ះពាល់ដោយសារគម្រោង (RF)។ របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង សង្ខេបអំពីវឌ្ឍនភាពលើសកម្មភាដោះសាស្រាយផលប៉ះពាល់ដោយសារគម្រោង និងជូនដំណឹងដល់ ADB អំពីព្រមព្រៀងដោយ IRC-GDR អំពីការផ្លាស់ប្តូរណាមួយតាមតម្រូវការចំពោះការអនុវត្តផែនការ DRP ។ ខ្លឹមសារនៃរបាយការណ៍ រួមមានស្ថានភាពដូចខាងក្រោមៈ

(១). ការរៀបចំស្ថាប័ន

(២). ការទូទាត់សំណងសម្រាប់សិទ្ធិទទួលបាន

(៣). ការអភិវឌ្ឍន៍ទីកន្លែងសម្រាប់ការតាំងទីលំនៅថ្មី និងការរុះរើលំនៅដ្ឋាន ប្រសិនបើមាន

(៤). ការដោះស្រាយបណ្តឹងតវ៉ា

(៥). ការពិគ្រោះយោបល់ជាសាធារណៈ

(៦). ការចំណាយថវិកា

(៧). ការរៀបចំកម្មវិធីគាំទ្រមុខរបរចិញ្ចឹមជីវិត ដែលអាចអនុវត្តបាន

(៨). ការចែកចាយ/ការរៀបចំកន្លែងទុកដាក់ និងការផ្លាស់ទីជាបណ្តោះអាសន្នរបស់អាជីករអ្នកលក់ដូរចេញពីតាំងផ្សារ

(៩). របាយការណ៍ពីវឌ្ឍនភាពជារួមប្រឆាំងនឹងកាលវិភាគនៃការអនុវត្តដែលបានព្រមព្រៀង

(១០). របាយការណ៍ពីបញ្ហាប្រឈម និងឧបសគ្គសំខាន់ៗ

(១១). រៀបចំវិធានការដោះស្រាយដែលបានស្នើឡើង។

១២៣. នាយកដ្ឋាន DIMDM នឹងទទួលខុសត្រូវលើការផ្តល់សុពលភាពផងដែរថា (១). សិទ្ធិទទួលបាន និងសំណង ត្រូវបានផ្តល់ជូនដោយអនុលោមតាមម៉ាទ្រិចបង្ហាញពីសិទ្ធិទទួលបាននៅក្នុងផែនការ DRP ដែលបានអនុម័តរួច, និង (២). យន្តការ GRM បាននឹងកំពុងដំណើរការតាមការណែនាំ។ ក្នុងអំឡុងពេលត្រួតពិនិត្យជាបន្តបន្ទាប់ នាយកដ្ឋាន DIMDM នឹងពិនិត្យមើលថាតើសកម្មភាពកែតម្រូវដែលបានព្រមព្រៀងគ្នាក្នុងការដោះស្រាយបញ្ហាលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ នៅក្នុងរយៈពេលត្រួតពិនិត្យកន្លងមក (ឧ. បញ្ហាការតាំងទីលំនៅថ្មី) ត្រូវបានដោះស្រាយហើយ ឬអត់។

## ឧបសម្ព័ន្ធ 1. បញ្ជីត្រួតពិនិត្យផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត

### បញ្ជីត្រួតពិនិត្យផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត

| ផលជះដែលអាចកើតមានលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត | បាទ/ចាស៎ | ទេ | អត់ដឹង | កំណត់សម្គាល់ |
|---|---|---|---|---|
| ការទិញលក់ដីដោយមិនស្ម័គ្រចិត្ត | | | | |
| ១. តើនឹងមានការទិញលក់ដីដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់ អំពីអ្វីដែលជាសមាសភាគនៃអនុគម្រោង។<br>• ការចុះទៅមើលផ្ទាល់ដើម្បីពិនិត្យមើលថាតើមានគ្រួសារដែលត្រូវផ្លាស់ទី នៅលើតំបន់ដែលរងផលប៉ះពាល់ដែរឬទេ។ |
| ១. តើគេមានស្គាល់ទីតាំងទិញលក់ដីដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់ និងអាជ្ញាធរមូលដ្ឋានអំពីទីតាំងនៃសមាសភាគ។ |
| ៣. តើគេបានដឹងពីស្ថានភាពកម្មសិទ្ធិ និងការប្រើប្រាស់ដីបច្ចុប្បន្ន ត្រូវទទួលបានដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។ |
| ៤. តើភាពងាយស្រួលនឹងត្រូវប្រើប្រាស់ក្នុងដីចំណីផ្លូវ (ROW) ដែលមានស្រាប់ដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។ |
| ៥. តើនឹងមានការបាត់បង់ទីជម្រក និងដីលំនៅឋានដោយសារការទិញលក់ដីដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។<br>• ការវាយតម្លៃនៅមូលដ្ឋាន |

| ផលជះដែលអាចកើតមានលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត | បាទ/ចាស់ | ទេ | អត់ដឹង | កំណត់សម្គាល់ |
|---|---|---|---|---|
| ៦. តើនឹងបាត់បង់ទ្រព្យសម្បត្តិកសិកម្ម និងផលិតភាពផ្សេងទៀត ដោយសារការទិញលក់ដីដែរឬទេ ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។<br>• ការវាយតម្លៃនៅមូលដ្ឋាន |
| ៧. តើនឹងមានការខាតបង់ដំណាំ ដើមឈើ និងទ្រព្យសកម្មថេរ ដោយសារការទិញដីដែរឬទេ ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។<br>• ការវាយតម្លៃនៅមូលដ្ឋាន |
| ៨ .តើនឹងមានការបាត់បង់អាជីវកម្ម ឬសហគ្រាស ដោយសារការទិញលក់ដីដែរឬទេ ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។<br>• ការវាយតម្លៃនៅមូលដ្ឋាន |
| ៩. តើនឹងមានការបាត់បង់ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិត ដោយសារការទិញលក់ដីដែរឬទេ ? | | | | • ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។<br>• ការវាយតម្លៃនៅមូលដ្ឋាន |
| **ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬលើការចូលទៅកាន់ឧទ្យាន និងតំបន់ការពារធម្មជាតិដែលបានកំណត់ដោយស្របច្បាប់** | | | | |

| ផលជះដែលអាចកើតមានលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត | បាទ/ចាស់ | ទេ | អត់ដឹង | កំណត់សម្គាល់ |
|---|---|---|---|---|
| ១០. តើមានអ្នកណាខ្លះនឹងបាត់បង់លទ្ធភាពទទួលបានធនធានធម្មជាតិ មធ្យោបាយសហគមន៍ និងសេវាកម្មផ្សេងៗដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ការពិគ្រោះយោបល់ជាមួយសហគមន៍។<br>• ការវាយតម្លៃនៅមូលដ្ឋាន |
| ១១. ប្រសិនបើការប្រើប្រាស់ដីធ្លី ត្រូវបានផ្លាស់ប្តូរ តើវានឹងជះឥទ្ធិពលអាក្រក់ដល់សកម្មភាពសង្គម និងសេដ្ឋកិច្ចដែរឬទេ? | | | | • ការវាយតម្លៃនៅមូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយគ្រួសារដែលត្រូវផ្លាស់ទី និងអាជ្ញាធរមូលដ្ឋាន |
| ១២. តើសិទ្ធិទទួលបានដី និងធនធានដែលជាកម្មសិទ្ធិសហគមន៍ ឬដោយរដ្ឋ នឹងត្រូវរឹតត្បិតដែរឬទេ? | | | | • ការពិភាក្សាជាមួយវិស្វករគូសប្លង់។<br>• ការវាយតម្លៃនៅមូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយគ្រួសារដែលត្រូវផ្លាស់ទី និងអាជ្ញាធរមូលដ្ឋាន |
| **ព័ត៌មានអំពីអ្នកដែលត្រូវផ្លាស់ទី៖** | | | | |

| ផលជះដែលអាចកើតមានលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត | បាទ/ចាស់ | ទេ | អត់ដឹង | កំណត់សម្គាល់ |
|---|---|---|---|---|
| *តើមានការប៉ាន់ស្មានណាមួយនៃចំនួនមនុស្សដែលទំនងជានឹងត្រូវផ្លាស់ទី ដោយសារគម្រោង/អនុគម្រោង ដែរឬទេ?*<br>*[ ] គ្មាន [ ] មាន*<br>បើមាន ប្រហែលប៉ុន្មាន? ________________________<br>ប្រភេទសម្រាប់ផលប៉ះពាល់លើការតាំងទីលំនៅដោយមោនស្ម័គ្រចិត្តៈ [15] A [ ] B [ ] C [ ] | | | | |
| *ក្នុងចំណោមពួកគេ តើមានអ្នកណាខ្លះក្រីក្រ ស្ត្រីមេគ្រួសារ ឬងាយរងគ្រោះចំពោះហានិភ័យនៃភាពក្រីក្រ ដែរឬទេ?*<br>*[ ] គ្មាន [ ] មាន* | | | | |
| *ក្នុងចំណោមពួកគេ តើមានអ្នកដែលត្រូវផ្លាស់ទីគឺជាក្រុមជនជាតិដើមភាគតិច ឬជនជាតិភាគតិចដែរឬទេ?*<br>*[ ] គ្មាន [ ] មាន* | | | | |
| *តើមានដីណាខ្លះដែលអាចនឹងរងផលប៉ះពាល់ ដោយកិច្ចអន្តរាគមន៍/សមាសភាគរបស់គម្រោង/អនុគម្រោង ដែរឬទេ ?*<br>*[ ] គ្មាន [ ] មាន* | | | | |

[15] ផលប៉ះពាល់ដែលទំនងជាត្រូវបានចាត់ថ្នាក់ជាប្រភេទ A នៅពេលដែលមានមនុស្សចំនួន ២០០ នាក់ ឬច្រើនជាងនេះ ជួបប្រទះនឹងផលប៉ះពាល់នៃការតាំងទីលំនៅថ្មី តាមរយៈការផ្លាស់ទីជារូបវន្តចេញពីលំនៅដ្ឋាន ឬបាត់បង់ ១០% ឬច្រើនជាងនេះនៃផលិតភាព (ការរកប្រាក់ចំណូល) ទ្រព្យសកម្មរបស់ពួកគេ។ មិនត្រូវបានចាត់ទុកថាមានផលប៉ះពាល់សំខាន់ៗ (ឱ. ក្រៅពីប្រភេទ A) នឹងត្រូវបានចាត់ថ្នាក់ជាប្រភេទ B ។ ប្រសិនបើគ្មានផលប៉ះពាល់ណាមួយ នឹងត្រូវបានចាត់ថ្នាក់ជាប្រភេទ C

# ឧបសម្ព័ន្ធទី 2. ដំណើរការពិគ្រោះយោបល់

## ដំណើរការពិគ្រោះយោបល់

### ក. ការពិគ្រោះយោបល់លើកទី ១

១. ការប្រជុំពិគ្រោះយោបល់សាធារណៈ**លើកទី ១** ត្រូវបានធ្វើឡើងជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងអ្នកដែលត្រូវផ្លាស់ទីដែលអាចកើតមាន នៅថ្នាក់ឃុំនៅទូទាំងអនុគម្រោងដែលបានស្នើឡើង មុនពេលរៀបចំក្របខ័ណ្ឌ RF និងសេចក្តីព្រាង RPs ។ កិច្ចប្រជុំនេះធ្វើឡើងដោយ MPWT និងអាជ្ញាធរខេត្ត ដោយមានការចូលរួមពី GDR និង ADB/ទីប្រឹក្សារៀបចំគម្រោង។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីផ្តល់ជូនសហគមន៍ និងអ្នកដែលត្រូវផ្លាស់ទីនូវព័ត៌មានទូទៅអំពីគម្រោង/អនុគម្រោង អត្ថប្រយោជន៍ និងផលប៉ះពាល់ដែលអាចកើតមាន តម្រូវការដីធ្លីដែលរំពឹងទុក គោលនយោបាយផ្តល់សំណង និងសិទ្ធិទទួលបាន និងលទ្ធភាពអាចទទួលបាន និងយន្តការដោះស្រាយបណ្តឹងតវ៉ា។ ឯកសារនៃកិច្ចប្រជុំ (កំណត់ហេតុនៃកិច្ចប្រជុំ សេចក្តីសង្ខេបនៃការពិភាក្សា បញ្ជីឈ្មោះអ្នកចូលរួម និងរូបភាព) នឹងត្រូវបានផ្តល់ជូន ADB សម្រាប់ជាផ្នែកនៃតម្រូវការរាយការណ៍។

២. សៀវភៅព័ត៌មានគម្រោង (PIB) សម្រាប់គម្រោង ដែលត្រូវបានរៀបចំឡើងដោយ MPWT ដោយមានជំនួយពី ADB ដែលផ្តល់ហិរញ្ញប្បទានដល់ PPCs និងគាំទ្រដោយ GDR ត្រូវបានចែកចាយឱ្យប្រើប្រាស់នៅតាមការិយាល័យក្រុមប្រឹក្សាឃុំ/ភូមិ និងចែកចាយទៅដល់អ្នកចូលរួមទាំងអស់ក្នុងអំឡុងពេលការប្រជុំរៀបចំសេចក្តីព្រាងផែនការតាំងទីលំនៅថ្មី (RP)។

### ខ. ការពិគ្រោះយោបល់លើកទី ២

៣. ការពិគ្រោះយោបល់ជាសាធារណៈ**លើកទី ២** នឹងធ្វើឡើងមុនដំណាក់កាលការធ្វើអង្កេតដោយវាស់វែងលម្អិត (DMS) ហើយត្រូវបានអនុវត្តរួមគ្នាដោយក្រុមការងារ IRC-WG និង PRSC-WG ។ មុនពេលចាប់ផ្តើម DMS កិច្ចប្រជុំពិគ្រោះយោបល់នឹងធ្វើឡើងជាមួយសហគមន៍ដែលរងផលប៉ះពាល់នៅតាមឃុំ ឬភូមិ។ ការពិគ្រោះយោបល់ក៏នឹងរួមបញ្ចូលផងដែរនូវការពិភាក្សាជាក្រុម (FGD) ជាមួយអ្នកដែលរងផលប៉ះពាល់ទាំងអស់ រួមទាំងក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ ក៏ដូចជាការពិគ្រោះយោបល់ជាលក្ខណៈបុគ្គលមួយទល់នឹងមួយក្នុងអំឡុងពេលធ្វើជំរឿន និងធ្វើ DMS ។ សៀវភៅព័ត៌មានគម្រោង (PIB) នឹងត្រូវបានធ្វើបច្ចុប្បន្នកម្មដោយអគ្គនាយកដ្ឋាន GDR រួមនឹងព័ត៌មានអំពីសិទ្ធិទទួលបាន យន្តការ GRM កម្រិតមូលដ្ឋាន រួមទាំងអ្នកត្រូវទំនាក់ទំនង ដូចដែលបានពិពណ៌នានៅក្នុងក្របខ័ណ្ឌ RF នេះ។ គោលការណ៍ណែនាំលម្អិតអំពីយន្តការ GRM នឹងត្រូវដាក់បញ្ចូលក្នុងសៀវភៅ PIB សម្រាប់ជាឯកសារភ្ជាប់។ ទាំងសៀវភៅ PIB ដែលបានធ្វើបច្ចុប្បន្នកម្មសម្រាប់គម្រោង ឯកសារភ្ជាប់ យន្តការ GRM និងកម្រងសំណួរ DMS នឹងត្រូវផ្តល់ជូន និងពន្យល់ដល់អ្នកចូលរួមទាំងអស់។ អ្នកដែលត្រូវផ្លាស់ទីទាំងអស់ នឹងត្រូវ

បានជូនដំណឹងថាពួកគេនឹងទទួលបានប័ណ្ណសម្គាល់ដែលរៀបរាប់លម្អិតអំពីទ្រព្យសម្បត្តិ ប្រាក់ចំណូល និងដីដែលរងផលប៉ះពាល់របស់ពួកគេរៀងៗខ្លួន បន្ទាប់ពីបានធ្វើអង្កេត DMS រួច។

៤. សៀវភៅ PIB ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មរួច ក៏នឹងត្រូវបានចែកចាយ និងពន្យល់ដល់អ្នកដែលត្រូវផ្លាស់ទីម្នាក់ៗក្នុងអំឡុងពេលធ្វើអង្កេត DMS ពីផ្ទះមួយទៅផ្ទះមួយ និងការវាយតម្លៃលើការខាតបង់ដីធ្លី និងទ្រព្យសម្បត្តិនានា។ អ្នកដែលត្រូវផ្លាស់ទី នឹងទាមទារឱ្យបញ្ជាក់ពីការបាត់បង់ទ្រព្យសម្បត្តិ និងការវាស់វែង និងទទួលបានការយល់ដឹងពេញលេញអំពីមូលដ្ឋាននៃការផ្តល់សំណងសម្រាប់ទ្រព្យសម្បត្តិដែលបាត់បង់ និងសិទ្ធិទទួលបានផ្សេងទៀត។

## គ. ការពិគ្រោះយោបល់លើកទី ៣

៥. កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ**លើកទី ៣** នឹងធ្វើឡើងមុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង/កិច្ចសន្យាសម្រាប់កញ្ចប់សំណង ហើយនឹងត្រូវធ្វើឡើងរួមគ្នាដោយក្រុមការងារ IRC-WG និង PRSC-WG ។ នៅដំណាក់កាលនេះ យន្តការ GRM ចាប់ដំណើរការ ហើយ DMS និង RCS ក៏ត្រូវបញ្ចប់ កញ្ចប់សំណងសម្រាប់គ្រួសារដែលត្រូវផ្លាស់ទីនីមួយៗ ក៏បានដឹងច្បាស់ ចំណែកសេចក្តីព្រាងកិច្ចសន្យាក៏បានរៀបចំផងដែរ។ ការប្រជុំពិគ្រោះយោបល់នឹងធ្វើឡើងជាពីរផ្នែក ហើយការជូនដំណឹងជាមុននៃការជួបប្រជុំនឹងត្រូវបានផ្តល់ជូនគ្រួសារដែលត្រូវផ្លាស់ទី តាមរយៈការិយាល័យក្រុមប្រឹក្សាឃុំ/ភូមិ។ នៅក្នុងផ្នែកទីមួយ ការពិគ្រោះយោបល់នឹងធ្វើឡើងតាមរយៈការជួបប្រជុំជាសាធារណៈ ដែលនឹងធ្វើឡើងនៅថ្នាក់ឃុំ/ភូមិ សម្រាប់គ្រួសារដែលត្រូវផ្លាស់ទីទាំងអស់ និងតំណាងឃុំ/សង្កាត់។ កំណត់ហេតុនៃកិច្ចប្រជុំ រួមទាំងឯកសារគាំទ្រទាំងអស់ (បញ្ជីឈ្មោះអ្នកចូលរួម រូបភាព។ល។) នឹងត្រូវបានផ្តល់ជូន ADB សម្រាប់ជាផ្នែកនៃតម្រូវការរាយការណ៍។

៦. សៀវភៅ PIB សម្រាប់កញ្ចប់សំណងក្រោមគម្រោង នឹងត្រូវបានរៀបចំជាមុន ហើយផ្តល់ជូន និងពន្យល់ដល់អ្នកចូលរួមទាំងអស់។ ផ្នែកទីពីរនឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះ បន្ទាប់ពីបញ្ចប់ផ្នែកទីមួយ ហើយនឹងធ្វើឡើងនៅថ្ងៃតែមួយ។ គ្រួសារដែលត្រូវផ្លាស់ទីនីមួយៗនឹងត្រូវបានផ្តល់ជូនជាមួយនឹងសេចក្តីព្រាងកិច្ចសន្យា និងចំនួនសំណងដែលបានពន្យល់តាមការពេញចិត្តរបស់ពួកគេ ជាលក្ខណៈមួយទល់នឹងមួយ។ ចំពោះគ្រួសារដែលត្រូវផ្លាស់ទីទាំងឡាយណាដែលមិនអាចចូលរួមក្នុងការប្រជុំបាន កិច្ចខិតខំប្រឹងប្រែងល្អបំផុត នឹងត្រូវបានធ្វើឡើងដើម្បីចុះទៅសួរសុខទុក្ខ និងជួបសួរនាំពួកគេដល់ផ្ទះតែម្តង ឬស្វែងរកជំនួយពីការិយាល័យភូមិ ដើម្បីធ្វើទំនាក់ទំនងជាមួយពួកគេ។ អ្នកដែលត្រូវផ្លាស់ទី នឹងត្រូវបានផ្តល់ពេលមួយសប្តាហ៍ដើម្បីពិនិត្យលើកិច្ចសន្យា ផ្ទៀងផ្ទាត់វិសាលភាពផលប៉ះពាល់ និងចុះហត្ថលេខាលើកិច្ចសន្យានោះ។

### ឃ. ការពិគ្រោះយោបល់លើកទី ៤

៧. កិច្ចប្រជុំពិគ្រោះយោបល់**លើកទី ៤** នឹងធ្វើឡើងនៅពេលដែលការបញ្ចេញសាចើប្រាក់ទូទាត់សំណងរួចរាល់ ហើយត្រូវបានអនុវត្តរួមគ្នាដោយក្រុមការងារ IRC-WG និង PRSC-WG ។ កាលវិភាគសម្រាប់ការទូទាត់សំណងនឹងត្រូវបានជូនដំណឹងដល់អ្នកដែលត្រូវផ្លាស់ទីទាំងអស់ យ៉ាងហោចណាស់មួយសប្តាហ៍ជាមុន តាមរយៈថ្នាក់ឃុំ និងភូមិ។ ការជួបប្រជុំនឹងធ្វើឡើងនៅទីសាធារណៈនៅក្នុងឃុំ ឬភូមិ។

៨. មុនពេលចាប់ផ្តើមការទូទាត់សំណង គ្រួសារដែលត្រូវផ្លាស់ទីទាំងអស់ ត្រូវបានជូនដំណឹងអំពីយន្តការ GRM សម្រាប់គម្រោង **ការបង្កើតគណៈកម្មាធិការ GRM ក្នុងមូលដ្ឋាននៅក្នុងខេត្តរបស់ពួកគេ** និងនីតិវិធីដែលនឹងត្រូវបានអនុវត្តក្នុងករណីដែលពួកគេមានពាក្យបណ្តឹងតវ៉ាណាមួយ។ ភ្លាមៗបន្ទាប់ពីការពិគ្រោះយោបល់ជាសាធារណៈ ការទូទាត់សំណងនឹងត្រូវបានធ្វើឡើងជាលក្ខណៈពីគ្រួសារមួយទៅគ្រួសារមួយរៀងៗខ្លួន ហើយគ្រួសារដែលត្រូវផ្លាស់ទីនីមួយៗ នឹងត្រូវបានផ្តល់ឱកាសដើម្បីស្វែងរកការបំភ្លឺអំពីកញ្ចប់សំណង មុនពេលទទួលបានការទូទាត់ទាំងស្រុង។

## ឧបសម្ព័ន្ធទី 3. សូចនាករនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP)

### សូចនាករនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP)

| គោលបំណង | សកម្មភាព | សូចនាករត្រួតពិនិត្យ |
|---|---|---|
| ការកំណត់អត្តសញ្ញាណអ្នកទទួលសំណង | ផ្ទៀងផ្ទាត់បញ្ជីអ្នកទទួលសំណង ធៀបនឹងលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបានសំណង | ចំនួនមនុស្សក្នុងបញ្ជីអ្នកទទួលសំណង ដែលមិនបំពេញតាមលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន (រាប់បញ្ចូលដោយកំហុស) |
| | ការកំណត់អត្តសញ្ញាណមនុស្សដែលអាចទាមទារសិទ្ធិទទួលបានសំណង ប៉ុន្តែមិនត្រូវបានបញ្ចូលក្នុងបញ្ជីអ្នកទទួលសំណង។ ការផ្ទៀងផ្ទាត់ដាច់ដោយឡែក គួរតែត្រូវបានអនុវត្តលើប្រភេទសំណងនីមួយៗ | ចំនួនមនុស្សដែលបំពេញតាមលក្ខណៈវិនិច្ឆ័យ ប៉ុន្តែមិនត្រូវបានបញ្ចូលក្នុងបញ្ជីអ្នកទទួលសំណង (មិនរាប់បញ្ចូលដោយកំហុស) |
| ការផ្ទៀងផ្ទាត់តំបន់ដែលរងផលប៉ះពាល់ | ការបញ្ជាក់ពីតំបន់នៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ (រួមទាំងដីឡូតិ៍ និងអចលនទ្រព្យ) ធៀបនឹង RP | ទីតាំងដីដែលជាកម្មវត្ថុនៃការទទួលបានដែលសំណងត្រូវបានបង់ |
| | | ទីតាំងនៃរចនាសម្ព័ន្ធជាកម្មវត្ថុនៃការទទួលបានដែលសំណងត្រូវបានបង់ |
| ការផ្ទៀងផ្ទាត់ចំនួនសំណង ដំណើរការ និងការទូទាត់ | ការពិនិត្យឯកសារហិរញ្ញវត្ថុ | ចំនួនអ្នកដែលបានទទួលប្រាក់សំណងទាន់ពេលវេលានិងចំនួនពេញដែលបានបែងចែកតាមប្រភេទសំណង |
| | ការកំណត់អត្តសញ្ញាណ និងការវិភាគអំពីហេតុផលសម្រាប់សំណងដែលមិនត្រូវបានបង់ក្នុងចំនួនពេញលេញ និងទាន់ពេលវេលា។ | ចំនួនអ្នកដែលមិនបានទទួលសំណងទាន់ពេលវេលា និងចំនួនពេញលេញ ដែលបានបែងចែកតាមប្រភេទសំណង |
| | | ចំនួនថវិកាដែលបានបែងចែកសម្រាប់ការទូទាត់សំណង |
| | ការកំណត់មូលហេតុដែលមូលនិធិសម្រាប់សំណងត្រូវបានយឺតយ៉ាវ ឬចំណាយលើស | អត្រានៃការចំណាយមូលនិធិដែលបានបែងចែកសម្រាប់សំណង, % នៃចំនួនទឹកប្រាក់ដែលរំពឹងទុកនៅក្នុង RP |

| គោលបំណង | សកម្មភាព | សូចនាករត្រួតពិនិត្យ |
| --- | --- | --- |
| ការផ្ទៀងផ្ទាត់ពេលវេលាកំណត់ក្នុងទូទាត់សំណង | ការកំណត់មូលហេតុដែលការទូទាត់សំណងត្រូវបានពន្យារពេល (ឧ. ដោយសារការកាត់ក្ដីរបស់តុលាការ ឬបញ្ហាមរតក។ល។) | ចំនួនអ្នកដែលទទួលបានសំណងជាមួយនឹងការពន្យារពេល ដោយបែងចែកតាមប្រភេទសំណង និងហេតុផលនៃការពន្យារពេល។ ការផ្លាស់ប្ដូរចំនួនសំណង (ប្រសិនបើមាន) ក៏គួរត្រូវបានកត់ត្រាផងដែរ។ |
| ការផ្ទៀងផ្ទាត់ការពិគ្រោះយោបល់ និងការចូលរួម | កំណត់កម្រិតនៃការចូលរួម និងការកំណត់មូលហេតុនៃការចូលរួមមិនគ្រប់គ្រាន់ | ចំនួនអ្នកទទួលសំណងដែលបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងសម្របសម្រួលនៅដំណាក់កាលនីមួយៗនៃលទ្ធកម្មដី។ |
| | ការពិនិត្យលើករណីបណ្ដឹងតវ៉ា ការវិភាគនៃវិវាទ និងខ្លឹមសារបណ្ដឹង និងការដោះស្រាយនៃជម្លោះ | ចំនួនបណ្ដឹងដែលបានទទួល |
| | | ចំនួនបណ្ដឹងដែលបានដោះស្រាយ |